01376989



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 12-Jan-2017, 15:55
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦**

**ម៉ោង ០៩:១៣នាទី**

**សវនាការលើកទី៤៧៣**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ហាសាន អាធុរេលិយ៉ា
*(Mr. Harshan ATHURELIYA)*

កញ្ញា ជា ស៊ីវហ៊ង

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ស្រ៊ា រតនៈ

លោក ចូសេហ្វ អេនឌ្រូ បិយលើ
*(Mr. Joseph Andrew BOYLE)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ហុង គឹមសួន

លោក វ៉េន ពៅ

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំច អរុណ

លោកស្រី ស្វ សុទ្ធារី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក ចូសេហ្វ អេនឌ្រូ បិយលី | អង់គ្លេស |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក អៀង ផាន (2-TCW-1046) | ខ្មែរ |

# ខ្លឹមសារ

**ការសួរសំណួរទៅសាក្សី៖ លោក អៀង ផាន** (2-TCW-1046)


សួរដោយប្រធានអង្គជំនុំ ផ្តើមពី ............................................ ទំព័រ ២

សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី ផ្តើមពី ............................................ ទំព័រ ៥

សួរដោយលោក រ៉ិចទ័រ កូប៉េ ផ្តើមពី ............................................ ទំព័រ ៥៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:១៣:៣៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-1046។

ក្រឡាបញ្ជីសវនាការ កញ្ញា ជា ស៊ីវហ៉ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

សាក្សីដែលនឹងត្រូវមកផ្តល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះ មានរហស្សនាម 2-TCW-1046។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និង ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីបានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែក កាលពីម្សិលមិញនេះ ហើយគាត់មានមេធាវីប្រឹក្សា គឺលោក ម៉ម រិទ្ធា។

សូមអរគុណលោកប្រធាន។

[០៩:១៥:០៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី៣១ ខែ តុលា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយ

គាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះមិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និង ដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និង មានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦ ហើយមេធាវីការពារក្ដីបាន បានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិមិនអាចបកស្រាយថា ជាការលះ បង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់ បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំ ការ ពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី៣១ ខែវិច្ឆិកា*(ស៊ីក)* ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថា មានអាការៈឈឺចង្កេះជាប្រចាំ អង្គុយយូរកាន់តែឈឺ និងបានផ្ដល់អនុសាសន៍ថា សុំឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួម តាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និង យោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោម សាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។ បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

តទៅនេះ បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី ព្រមទាំងមេធាវីប្រឹក្សាសាក្សីចូលមក កាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[០៩:១៨:២៥]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកសាក្សី តើលោកឈ្មោះអី?

**លោក អៀង ផាន៖**

**ផ៖** សូម -- ដំបូងសូមគោរពលោកប្រធាន ខ្ញុំបាទឈ្មោះ អៀង ផាន។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** អរគុណលោក អៀង ផាន ហើយលោកកើតនៅថ្ងៃខែឆ្នាំណា លោកចាំដែរទេ ថ្ងៃខែឆ្នាំកំណើតរបស់លោក?

**ផ៖** ខ្ញុំកើតនៅថ្ងៃ២៨ ខែ៣ ឆ្នាំ១៩៥២។

**ស៖** បាទ អរគុណ ហើយទីកន្លែងកំណើតរបស់លោកនៅទីកន្លែងណាដែរ ស្រុកកំណើត?

**ផ៖** ស្រុកកំណើតនៅភូមិអង្គត្នោត ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ។

[០៩:១៩:១៨]

**ស៖** បាទ អរគុណ ហើយសព្វថ្ងៃនេះ លោកមានទីលំនៅ នៅទីកន្លែងណា ហើយប្រកបមុខរបរអ្វីដែរ?

**ផ៖** សព្វថ្ងៃនៅភូមិអន្លង់ -- ភូមិបេង ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង ហើយមុខរបរជាទាហាន។

**ស៖** ឪពុកបង្កើតរបស់លោកឈ្មោះអី ហើយម្ដាយបង្កើតរបស់លោកឈ្មោះអី?

**ផ៖** ឪពុកខ្ញុំបាទឈ្មោះ អៀង ផូ (ស្លាប់), ម្ដាយឈ្មោះ ផ្លុង មិត្ត (ស្លាប់)។

**ស៖** ចុះប្រពន្ធរបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ផ៖** ប្រពន្ធរបស់ខ្ញុំឈ្មោះ ទង់ អ៊ិន មានកូនប្រាំនាក់។

**ស៖** បាទ អរគុណលោក អៀង ផាន។ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះ ថាតាមសមត្ថភាពដែលលោកអាចដឹង គឺលោកមិនមានចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប លោក នួន ជា និង លោក ខៀវ សំផន ក៏ដូចជាបុគ្គលទាំងឡាយដែលបានទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងក្ដីនេះទេ ហើយថាលោកបានធ្វើសម្បថរួចហើយមុននឹងចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះ។ តើរបាយការណ៍នេះ ពិតជាត្រឹមត្រូវដែរឬទេ?

**ផ៖** ពិតជាត្រឹមត្រូវ។

**ស៖** បាទ អរគុណ។ ហើយជាបន្តទៅនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចក្នុងឋានៈលោកជាសាក្សី ដែលត្រូវផ្ដល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ។ អំពីសិទ្ធិ លោក អៀង ផាន ក្នុងឋានៈលោកជាសាក្សី នៅក្នុងកិច្ចដំណើរការសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬក៏សុំឲ្យលោកធ្វើអត្ថាធិប្បាយរៀបរាប់ណា ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួន

ឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។

[០៩:២១:០៨]

អំពីករណីយកិច្ច ក្នុងឋានៈលោកជាសាក្សី លោកត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែល ចៅក្រម ឬក៏ភាគីសួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយតបរបស់លោក ឬ សេចក្ដីធ្វើអត្ថាធិប្បាយដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងបានប្រាប់អំពីសិទ្ធិរួចហើយអម្បាញ់ មិញនេះ។ ហើយក្នុងឋានៈជាសាក្សី ត្រូវតែឆ្លើយតែការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬបានជួបប្រទះ ឬក៏បានធ្វើការសង្កេតដោយផ្ទាល់ នូវព្រឹត្តិហេតុ នូវហេតុការណ៍ ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរ ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។

ហើយលោកសាក្សី តើលោកបានផ្ដល់ ធ្លាប់ផ្ដល់កិច្ចសម្ភាសន៍ ឬផ្ដល់សក្ខីកម្មជាមួយនឹងអ្នក ស៊ើបអង្កេតនៃការិយាល័យសហចៅក្រមដែរឬទេ ក្នុងរយៈពេលកន្លងមក? ប្រសិនបើធ្វើ ធ្វើប៉ុន្មានដង ធ្វើនៅទីកន្លែងណា នៅពេលណា? លោកចាំទេ?

[០៩:២២:០៤]

**ឆ៖** ធ្វើនៅបាត់ដំបងមួយដង ហើយចូលមកកន្លែងនេះមួយដង។

**ស៖** លោកចាំទេ ធ្វើនៅបាត់ដំបងនៅពេលណាដែរ ហើយចូលមកកន្លែងនេះ មកដល់សក្ខីកម្ម នៅទីនេះ ហើយលោកចាំទេ គ្រាន់តែចាំឆ្នាំ ឬចាំខែក៏បានដែរ លោកចាំទេ? ធ្វើនៅៗពេលណា នៅបាត់ ដំបង?

**ឆ៖** ខ្ញុំដូចមិនចាំ បាត់ដំបង ដូចជា២០១០ ឬក៏២០១១ បាទ។

**ស៖** អរគុណ។ ហើយធ្វើនៅបាត់ដំបងតែមួយដងទេ ហើយមួយដងទៀតដែលលោកថា មក ផ្ដល់សក្ខីកម្មនៅទីនេះ មកផ្ដល់សក្ខីកម្មនៅទីនេះ ឬក៏ទៅផ្ដល់សក្ខីកម្មនៅបន្ទប់ផ្សេង?

**ឆ៖** នៅទីនេះ លោកប្រធាន។

**ស៖** បាទ អរគុណ។ ហើយមុននឹងចូលមកចំពោះមុខអង្គជំនុំជម្រះ តើលោកបានពិនិត្យមើល ឬបានអាននូវកំណត់ហេតុដែលលោកផ្ដល់សក្ខីកម្មកាលពីពេលមុន ជាមួយនឹងអ្នកស៊ើបអង្កេត ដែល លោកអះអាងអំមិញថា លោកបានធ្វើនៅខេត្តបាត់ដំបងនោះ ដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** ខ្ញុំបានពិនិត្យ និងពិនិត្យមើលសាចុះ សាឡើងទាំងសំណួរ ទាំងចម្លើយរបស់ខ្ញុំ បាទ។

**ស៖** ហើយបើតាមសមត្ថភាពដែលលោកអាចដឹងនិងចងចាំបាននោះ តើលោកអាចបញ្ជាក់បាន

ដែរទេថា កំណត់ហេតុដែលលោកបានៗអាន ដើម្បីរំឭកការចងចាំហ្នឹង គឺវាពិតត្រឹមត្រូវសមស្រប ស៊ីចង្វាក់គ្នាទៅនឹងសក្ខីកម្ម ឬចម្លើយដែលលោកបានផ្តល់មួយដងកាលពីនៅខេត្តបាត់ដំបង កាលពីអំឡុងដែលលោកថាឆ្នាំ២០១០ ឬ២០១១ នោះដែរឬទេ?

**ឆ៖** ចម្លើយនោះ ខ្ញុំយល់ឃើញថា សមស្របតាមសភាពការណ៍ដែលខ្ញុំយល់ ហើយខ្ញុំដឹង ខ្ញុំឃើញ បាទ។

[០៩:២៤:១៧]

**ប្រធានអង្គជំនុំ៖**

បាទ ហើយកំណត់ហេតុនុ៎ងគឺ តាមនូវកំណត់ហេតុដែលមាននុ៎ង គឺធ្វើនៅខែវិច្ឆិកា ឆ្នាំ២០០៩។ ហើយនៅពេលនេះ លោកបានទទួលជំនួយមេធាវីប្រឹក្សារបស់អង្គជំនុំជម្រះដែលបានផ្តល់ឲ្យលោក តាមរយៈអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ តាមសំណើសុំ គឺលោកមេធាវី ម៉ម រិទ្ធា រួចហើយ។ ហើយក្នុងការសួរដេញដោលសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួននៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា សួរដេញដោលសាក្សីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្តី។ សូមបញ្ជាក់ថា តំណាងសហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលសរុបបីវគ្គនៃថ្ងៃសវនាការក្នុងការសួរដេញដោលសាក្សីរូបនេះ។

សូមអរញ្ជើញ!

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។ សុំជម្រាបលោក លោកស្រីចៅក្រម ហើយនិងលោកសាក្សី។

**ស៖** ដូចដែលលោកបានយោងជម្រាបលោកប្រធាននៅពេលនេះ លោកបញ្ជាក់ថា លោកបានធ្វើសក្ខីកម្មនៅតុលាការនេះកាលពីមុនម្តងហើយ។ ហើយយើងខ្ញុំសហព្រះរាជអាជ្ញា ខ្ញុំឈ្មោះ អេនឌ្រូ ប៊ិយ ខ្ញុំនឹងសួរសំណួរចំនួនទៅលោកនៅព្រឹកនេះ ក្នុងនាមសហព្រះរាជអាជ្ញា។ គឺថាឯកសារខ្លះយើងយកមកប្រើទាក់ទងនឹងព័ត៏មានដែលលោកបាន<ផ្តល់ឲ្យ> ហើយខ្ញុំនឹងសួរសំណួរមួយចំនួន<ដើម្បីឲ្យលោកបញ្ជាក់>ពីបញ្ហានោះ ហើយនិងមានឯកសារថ្មីមួយចំនួនទៀតដែលខ្ញុំនឹងសួរទៅលោក។ ដើម្បីចាប់ផ្តើមអ៊ីចឹងយើងមើលបរិបទ។ សុំលោកជម្រាបតុលាការថា តើលោកបានចូលចលនាខ្មែរក្រហមនៅពេលណាដែរ?

[០៩:២៦:១៦]

**លោក អៀង ផាន៖**

**ផ៖** ខ្ញុំបានចូលចលនាខ្មែរក្រហមតាំងពីឆ្នាំ១៩៧០។

**ស៖** តើនៅពេលនោះ លោកមានទីកន្លែងនៅទីណាដែរ ពេលដែលចូលចលនានោះ?

**ផ៖** ខ្ញុំចូលនៅឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ។

**ស៖** សូមលោកជម្រាបដោយសង្ខេបជូនតុលាការអំពីមុខតំណែងនៅក្នុងចលនានោះ នៅពេលដែលលោកបន្តចូលរួមធ្វើការចាប់ពីពេលចូលរហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

**ផ៖** ខ្ញុំសូមជម្រាបថា ខ្ញុំបានចូលចលនាតស៊ូតាំងពីខែ៧ ឆ្នាំ១៩៧០។ បានរយៈពេលមក ខ្ញុំឡើងបានប្រហែលជាមួយខែកន្លះ ខ្ញុំបានឡើងពីយោធាឃុំ មកយោធាស្រុក ហើយបានមួយឆ្នាំជាងមក ខ្ញុំបានឡើងមកយោធាខេត្តៗតាកែវ។ ចាប់ពីពេលនោះមកគឺថា ខ្ញុំបានឡើងមុខនាទី មុខតំណែងជាបន្តបន្ទាប់រហូតដល់ទៅជាទ័ពស្រួចរបស់យោធភូមិភាគនិរតី។ ខ្ញុំបានឆ្លងកាត់ធ្វើមេតាំងពីធ្វើប្រធានពួក ប្រធានអនុសេនាតូច មេបញ្ជាការរងអនុសេនាធំ មេបញ្ជាការអនុសេនាធំ មេបញ្ជាការរងវរសេនាតូច មេបញ្ជាការវរសេនាតូច មេបញ្ជាការរងវរសេនាធំ មេបញ្ជាការវរសេនាធំ។ រហូតដល់ថ្ងៃរំដោះ ខ្ញុំបានត្រឹមតែមេបញ្ជាការវរសេនាធំ។

**ស៖** សូមអរគុណចំពោះចម្លើយរបស់លោក។ ខ្ញុំនឹងផ្ដោតអារម្មណ៍ទៅលើបញ្ហាមួយចំនួន ជាពិសេសអំពីមុខតំណែងដែលលោកកាន់នៅពេលក្រោយ។ ប៉ុន្តែពេលនេះ ខ្ញុំចង់ដឹងថា នៅពេលដែលវាយប្រហារទីក្រុងភ្នំពេញ <នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥> តើ<នៅពេលនោះ>លោកកាន់មុខតំណែង <នៅក្នុងកងវរសេនាតូចពិសេសលេខ២០៣របស់>ភូមិភាគនិរតី<មែនទេ>?

[០៩:២៩:២១]

**ផ៖** ខ្ញុំសូមជម្រាបថា ពេលវ៉ៃចូលទីក្រុងភ្នំពេញគឺ ខ្ញុំបាទជាប្រធានវរសេនាតូចកងពិសេសចំណុះឲ្យកងពលទី២របស់ភូមិភាគនិរតី។

**ស៖** តើលេខកងវរសេនា<តូច>នោះគឺ២០៣ <មែនទេ>?

**ផ៖** វរសេនាតូច ២០៣ពិសេស។

**ស៖** លោកបានបញ្ជាក់ថា នៅពេលដែលវាយប្រហារទីក្រុងភ្នំពេញ លោកជាអនុនៃវរសេនាតូចហ្នឹង ឬក៏យ៉ាងដូចម្ដេច?

**ឆ៖** ខ្ញុំជាប្រធានវរសេនាតូចទ័ពពិសេសហ្នឹងតែម្តង។

**ស៖** សូមអរគុណ។ ហើយនៅពេលដែលលោកចូលរួមនៅក្នុងការវាយប្រហារទីក្រុងភ្នំពេញកាលនោះ តើលោកបានចូលពីខាងនិរតីតម្រង់មកភ្នំពេញតាមផ្លូវជាតិលេខ៣ <និង>លេខ៤ ឬក៏ចំណុចត្រង់ណា?

**ឆ៖** ខ្ញុំសូមជម្រាបថា មុខព្រួញទ័ពពិសេសរបស់យើងខ្ញុំគឺចូលចន្លោះផ្លូវលេខ៤ និងផ្លូវលេខ៣ ត្រង់អាកាសយានដ្ឋានពោធិ៍ចិនតុង។ និយាយរួមចំអាមុខកន្ទោកនេះ កន្លែងដាក់គ្រាប់យន្តហោះ។

**ស៖** តើលោកស្ថិតនៅក្នុង<កងពលតូច>មួយណា? <តើ>វរសេនាតូច២០៣ហ្នឹង ស្ថិតនៅក្នុងកងពលតូចលេខប៉ុន្មាន លោកចាំទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា វរសេនាតូច២០៣នេះ ជាទ័ពពិសេសចំណុះឲ្យកងពលតែម្តង។ ចង់និយាយថា កងពលជាអ្នកគ្រប់គ្រងផ្ទាល់។

[០៩:៣២:០៨]

**ស៖** ខ្ញុំនឹងអានជូនលោកស្តាប់<នូវអ្វី>ដែលលោកបានធ្វើសក្ខីកម្មពីមុន គឺថា នៅ<ក្នុងប្រតិចារឹក> ឯកសារ <E1/193.1> គឺនៅៗម៉ោង ០៩:៣៥:០២ <លោកសាក្សី នេះគឺជាអ្វីដែលលោកបាននិយាយ៖>"នៅ<ឆ្នាំ១៩៧៤> ខ្ញុំបានក្លាយទៅជាប្រធានកងវរសេនាតូច២០៣ <នៅភូមិភាគនិរតី> ហើយនិងកាលនោះ គឺនៅក្នុងកងពល<តូច>លេខ២"។ តើអ៊ីចឹងត្រឹមត្រូវដែរឬទេ <គឺថាកងវរសេនាតូចលេខ២០៣ ស្ថិតនៅក្រោមកងពលតូចលេខ២>?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** ហើយសូមលោកប្រាប់តុលាការថាតើប្រធានកងពល<តូច>លេខ២ តើ<នរណាជាមេរបស់លោក>?

**ឆ៖** ប្រធានកងពលលេខ២ ជំនាន់នោះគឺលោក សំ ប៊ិត។

**ស៖** តើលោក សំ ប៊ិត បានផ្តល់ការបញ្ជាមករូបលោកដូចម្តេចដែរក្នុង<ការរៀបចំ>ធ្វើការវាយប្រហារទីក្រុងភ្នំពេញកាលនោះ?

**ឆ៖** ខ្ញុំសូមជម្រាបថា ពេលវាយប្រហារទីក្រុងភ្នំពេញពេលនោះ សម្រាប់កងពិសេសយើងខ្ញុំ គឺថាវ៉ៃរហ័ស ឈ្នះរហ័ស ហើយដកមកវិញ មិនបាននៅភ្ជុំវ៉ៃហ្នឹងទេ គឺបញ្ហាអ៊ីចឹង។ ឧបមាថាគោលដៅណាមួយទៅវ៉ៃឈ្នះហើយគឺដកមកវិញ អត់ៗនៅប្រចាំដូចទ័ពថ្មើរជើងទេ។ ហើយពេលវ៉ៃចូលទីក្រុង

ភ្នំពេញ ខ្ញុំជឿថា ការរៀបចំផែនការ មិនមែនគ្រាន់តែចង្អុលបង្ហាញ គឺច្បាស់លាស់ហើយ អ្នកណាទទួលមុខព្រួញណា អ្នកណាទទួលមុខព្រួញណា ហើយខ្ញុំដឹងតែមុខព្រួញរបស់ខ្ញុំ គឺចំកន្ទោកនេះឯង កន្លែងដាក់យន្តហោះហ្នឹង កន្លែងដាក់គ្រាប់យន្តហោះ ហើយខ្ញុំវ៉ៃបានសម្រេច។

[០៩:៣៤:១៧]

**ស៖** តើលោក សំ ប៊ិត បាន<>ប្រាប់លោកទេ <អំពីផែនការ>ជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ គួរឲ្យចាប់អារម្មណ៍ណាស់ ក៏ប៉ុន្តែគឺជាផ្នែកនៃរឿងក្តី ០០២/០១ ហើយសំណួរ<ដូចគ្នាទាំងអស់នេះត្រូវបាន>សួរទៅសាក្សីនៅពេលដែលគាត់ធ្វើសក្ខីកម្មកាលនោះ។ ខ្ញុំមិនមានបញ្ហាទេ ប៉ុន្តែសំណួរទាំងនោះមិនពាក់ព័ន្ធនៅពេលនេះទេ។

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

ប្រសិនបើមេធាវីការពារក្តីមិនជំទាស់ទេ <ខ្ញុំស្នើថា ខ្ញុំអាចសួរបាន។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

យើងចង់ដឹងពីគោលដៅរបស់លោក។

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

បាទ ខ្ញុំ<អាចសួរសំណួរបន្ទាប់។ ខ្ញុំគ្រាន់តែព្យាយាមមិនសួរសំណួរនាំមុខទេ ប៉ុន្តែខ្ញុំរីករាយនឹងសួរដោយផ្ទាល់ទៅលើចំណុចនោះ>។

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** លោកសាក្សី តើលោកបានទទួលការណែនាំអ្វីទាក់ទងទៅការសម្រិតសម្រាំងអតីតទាហានលន់នល់ ដែរឬទេ <ដែលជាមូលហេតុចម្បងនៃ>ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញកាលនោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប! អញ្ជើញលោកស្រីមេធាវី អង់តា ហ្គីសសេ!

[០៩:៣៥:៣៩]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម មកដល់វេនខ្ញុំត្រូវជំទាស់ម្តង។ គាត់បានសួរសាក្សីពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ប្រធានបទនេះត្រូវបានវិនិច្ឆ័យរួចមកហើយ ហើយមូលហេតុដែលសាក្សីត្រូវបានកោះហៅមកហ្នឹងគឺនិយាយអំពីជម្លោះប្រដាប់អាវុធជាមួយវៀតណាមទេ មិនមែននិយាយពីការជម្លៀសប្រជាជនទេ។ អ៊ីចឹងគាត់សួរចាកប្រធានហើយ អ៊ីចឹងខ្ញុំសូមជំទាស់ចំពោះការសួររបស់ព្រះរាជអាជ្ញាដែលគាត់ត្រឡប់ទៅសួរក្នុងសំណុំរឿង០០២/០១វិញហើយអ៊ីចឹងនោះ។

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលើ៖**

ខ្ញុំសូមឆ្លើយតប គឺថាចំពោះសាក្សីនានា គឺថាយើងត្រូវបានអនុញ្ញាតឱ្យសួរពីប្រធានបទ<នានាដែលពាក់ព័ន្ធ>នៅក្នុងរឿងក្តី<០០២/០២>។ ដូចជាការកំណត់មុខសញ្ញា<អតីត>ទាហានលន់ នល់<និងអ្នករដ្ឋការលន់ នល់>ជាដើម គឺជាផ្នែកដែលពាក់ព័ន្ធនឹង<សំណុំរឿង០០២/០២ នេះ>។ <សំណួរនេះគឺពាក់ព័ន្ធដោយផ្ទាល់ ហើយខ្ញុំសូមបញ្ជាក់ជូនមេធាវីការពារក្តីថា ខ្ញុំនឹងសួរពីបញ្ហាជម្លោះប្រដាប់អាវុធផងដែរ។ ខ្ញុំសូមស្នើសុំការ>អនុញ្ញាត<ឱ្យសួរសំណួរនេះ>បន្ត<ទៀត>។

[០៩:៣៦:៤៦]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមឆ្លើយតប គឺថា យើងតែងតែទទួលបានការណែនាំបន្ទោសពីតុលាការ <ប្រសិនបើ>យើងសួរសំណួរ<ច្រំដែល>បែបនេះ។ <>សហព្រះរាជអាជ្ញាសួរ<សំណួរច្រំដែល ព្រោះថាអ្វីដែលបានកើតឡើងចំពោះ>ទាហានលន់ នល់ <ក្នុងពេលជម្លៀសនោះ មិនថាតែគោលនយោបាយលន់ នល់ ទេ>គឺ<គាត់បានឆ្លើយយ៉ាងច្រើនរួចហើយនៅ>ឆ្នាំ២០១៣ ឯណោះ <អ៊ីចឹងតើបានប្រយោជន៍អី?>

**ប្រធានអង្គជំនុំ៖**

ជាការទំនងម្យ៉ាងដែរការជំទាស់ហ្នឹង ដោយសារមូលហេតុនៃដំណើរការសវនាការហ្នឹងគឺធ្វើសវនាការ០០២/០១ រួចហើយ ហើយនៅក្នុងក្រុមប្រតិចារឹកហ្នឹងគឺបានបញ្ចូលពី០០២/០១ មក ០០២/០២ ដែរ។ ហេតុដូច្នេះហើយពេលវេលាក៏មានដែនកំណត់ដែរ ដូច្នេះគប្បីវិញទៅមុខទៀតធ្វើម៉េចឱ្យជ្រៅទៅលើអង្គហេតុដែលធ្វើសវនាការទៅ។

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** លោកសាក្សីខ្ញុំសូមបន្តទៅមុខទៀត។ ក្រោយពីរំដោះបានទីក្រុងភ្នំពេញ តើលោកស្ថិតនៅ <បន្តគ្រប់គ្រង>កងវរសេនាតូច<ពិសេស>២០៣ដដែល ឬក៏យ៉ាងដូចម្ដេច?

[០៩:៣៨:១៥]

**លោក អៀង ផាន៖**

**ឆ៖** ពេលរំដោះភ្នំពេញភ្លាមគឺថា ខ្ញុំនៅតែស្ថិតនៅជាមេបញ្ជាការវរសេនាតូច២០៣ពិសេសដដែល។

**ស៖** ហើយក្រោយពីទីក្រុងភ្នំពេញធ្លាក់ទៅក្នុងដៃរបបខ្មែរក្រហម ថាតើកងវរសេនាតូចពិសេស ២០៣ របស់លោកគឺ គេចាត់តាំងឲ្យឈរជើងនៅកន្លែងណា ដូចជា១ខែ ឬ២ខែ បន្ទាប់ពីទីក្រុងភ្នំពេញបានដួលរលំទៅ?

**ឆ៖** ក្រោយពីរំដោះទីក្រុងភ្នំពេញ កងពិសេសយើងខ្ញុំគឺថា បោះនៅភូមិព្រៃស ជិតគុកព្រៃស រយៈពេល៣ខែ។ បោះហ្នឹងបោះធ្វើស្រែមិនមែនធ្វើអីទេ ធ្វើស្រែ។

**ស៖** បន្ទាប់ពីរយៈពេល៣ខែហ្នឹង ថាតើកងវរសេនាតូចពិសេសរបស់លោកគេបញ្ជូនទៅទីណាទៀត?

**ឆ៖** បន្ទាប់ពីបោះនៅភូមិព្រៃស៣ខែ គឺថាវរសេនាតូចយើងខ្ញុំបញ្ជូនទៅតាកែវវិញ ទៅខេត្តតាកែវ។

**ស៖** តើលោកបានក្លាយទៅជាបក្ខជននៃបក្សកុម្មុយនីស្តកម្ពុជានៅពេលណាមួយទេ ក្រោយពេលរំដោះបាននៅពេលនោះ?

**ឆ៖** ខ្ញុំចូលជាសមាជិកបក្សតាំងពីឆ្នាំ១៩៧៣ម្ល៉េះ។ មិនមែនចូលក្រោយរំដោះហើយទេ ចូលមុនទៀត តាំងពីឆ្នាំ១៩៧៣នោះ។

[០៩:៤០:៣២]

**ស៖** សូមអរគុណដែលលោកបានបំភ្លឺ។ លោកទើបតែបញ្ជាក់ថាគេចាត់តាំងឲ្យត្រឡប់ទៅខេត្តតាកែវវិញ។ តើកាលនោះ គេបញ្ជូនកងវរសេនាតូចរបស់លោកទៅព្រំដែន ឬក៏ទៅនៅទីក្រុងតាកែវ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ទៅដំបូងគឺថា អត់ទាន់ទៅព្រំដែនទេ គឺនៅជុំវិញតាកែវហ្នឹង។ បំណាងដែលដកទៅហ្នឹងគឺគេរៀបចំថ្មីៗ គេដកខ្ញុំហ្នឹងឲ្យ -- ផ្លាស់ខ្ញុំហ្នឹងចេញពីវរសេនាតូចពិសេសហ្នឹង ទៅជាមេបញ្ជាការរងវរសេនាធំលេខ១២ កងពលទី២វិញ។

**ស៖** នៅពេលដែលគេបញ្ជូនលោកទៅតាកែវដំបូង ថាតើកងពលតូចមានចំនួនប៉ុន្មាននៅក្នុង <យោធារបស់ភូមិភាគនិរតី> តាមដែលលោកចាំ?

**ឆ៖** ខ្ញុំចាំបានថា កងពលលេខ២ ពេលដែលខ្ញុំទៅកាន់ជាអនុប្រធានវរសេនាធំលេខ១២ហ្នឹង ហើយធ្លាប់តែងតែប្រជុំជាមួយវរសេនាធំដូចគ្នាហ្នឹង គឺថាមានបួនវរសេនាធំ កងពលលេខ២ហ្នឹង មានវរសេនាធំលេខ១១, ១២, ១៣, ១៤។

**ស៖** តើលោកអាចជម្រាបតុលាការបានទេនៅពេលដែលលោកបានធ្វើជាមេបញ្ជាការកងវរសេនាធំលេខ១២នោះ ថាតើគេដំឡើងឋានន្តរសក្ដិជាមុខងាររបស់លោកនៅពេលណា◌ុ◌ះ<>?

[០៩:៤២:៣៥]

**ឆ៖** ពេលគេរៀបចំនោះ គេប្រកាស កងពលគេប្រកាសនៅកន្លែងកងពលនៅគេហៅថាទីតាំងភ្នំខ្លែងៗផ្លូវលេខ២។ ពេលខ្ញុំទៅពីភ្នំពេញនេះទៅៗឈប់ជុំវិញតាកែវ ហើយដល់ពេលគេប្រកាសខ្ញុំប្រកាសមុខតំណែងខ្ញុំ នៅភ្នំខ្លែងហ្នឹងហ្មង កងពលអ្នកប្រកាស។

**ស៖** តើលោកចាំកាលបរិច្ឆេទដែរឬទេអំពីការប្រកាសប្រហែលជានៅក្នុងខែ ឬក៏ឆ្នាំណា?

**ឆ៖** ចុងឆ្នាំ៧៧ – ១៩៧៧។

**ស៖** ខ្ញុំអានជូនលោកស្ដាប់នៅក្នុងកំណត់ហេតុរបស់លោក គឺE3/419 ចម្លើយទី១ លោកបាននិយាយថា "នៅក្នុងខែតុលា ឆ្នាំ១៩៧៦ ខ្ញុំបានធ្វើជាមេបញ្ជាការកងវរសេនាធំលេខ១២ ដែលនៅចំណុះឲ្យកងពល<តូច>លេខ២"។ អ៊ីចឹងតើត្រឹមត្រូវដែរឬទេកាលបរិច្ឆេទដែលលោកបញ្ជាក់នៅពេលនេះ?

**ឆ៖** បញ្ជាក់ក្នុងឯកសារត្រឹមត្រូវ ប៉ុន្តែខ្ញុំមិនបានចាំច្បាស់ បាទ។ គ្រាន់តែប្រហែលៗ ប៉ុន្តែឯកសារនេះច្បាស់ហើយ ៧៦ ចុង៧៦ បាទ។

**ស៖** តើនៅពេលណាដែលគេបញ្ជូនឲ្យទៅឈរជើង<ដំបូង>នៅព្រំដែន នឹងប្រទេសវៀតណាមនៅខេត្តតាកែវនៅកាលនោះ តើលោកចាំទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា ពេលដែលខ្ញុំទៅកាន់វរសេនាធំលេខ១២ហ្នឹង គឺវរសេនាធំហ្នឹងនៅតាមព្រំដែនហើយរួចស្រេចទៅហើយ។ ខ្ញុំសូមជម្រាបថា វរសេនាធំហ្នឹង ពង្រាយតាមព្រំដែនរួចស្រេចទៅ

ហើយ គ្រាន់តែខ្ញុំទៅធ្វើជាមេទេ។

**ស៖** តើលោកនៅចាំដែរឬទេ តើកងវរសេនាធំលេខ១២ហ្នឹង <>ត្រូវបានបញ្ជូន<ជាលើកដំបូង>ទៅតាមព្រំដែននៅពេលណា ទោះបីជាការបញ្ជូននោះមុនលោកក្លាយជាមេបញ្ជាការក៏ដោយតើលោកដឹងទេ?

[០៩:៤៥:២៧]

**ឆ៖** ខ្ញុំសូមជម្រាបផងដែរថា កងពលលេខ២នេះ មានវរសេនាធំលេខ១១, ១២, ១៤ហ្នឹង គឺក្រោយរំដោះភ្នំពេញហ្នឹង គឺទៅឈរព្រំដែនហើយ រួចស្រេចទៅហើយបាទ។ អត់មាននៅភ្នំពេញទៀតទេ ទៅព្រំដែនវៀតណាមទាំងអស់ ពិសេសនៅក្នុងឆ្នាំ៧៦-៧៧ហ្នឹង គឺទៅព្រំដែនអស់ហើយ។

**ស៖** តើរចនាសម្ព័ន្ធយោធានៅកង -- នៅភូមិភាគនិរតីហ្នឹង គឺត្រូវបានប្តូរដែរឬទេ នៅក្នុងឆ្នាំ១៩៧៦ រហូតដល់ឆ្នាំ១៩៧៧ ចាប់ពីកងពលតូច <និង>វរសេនាធំជាដើមហ្នឹង តាមដែលលោកដឹងមានការកែប្រែអ្វីដែរខ្លះ?

**ឆ៖** ខ្ញុំសូមជម្រាបថា ឯកសារខ្ញុំបានផ្តល់នោះ គឺថានៅដើមឆ្នាំ៧៧ហ្នឹង គឺថានៅភូមិភាគនិរតីហ្នឹងបានកែប្រែលេខកងពលអស់ហើយបាទ អត់មានកងពលលេខ២ទៀតទេ មានកងពល២១០ ២២០ -- អ៎! ២១០, ២៣០, ២៥០, ២៧០ កងពលតូច។ រៀបទៅជាបួនកងពលតូចវិញ។

**ស៖** នៅក្នុងការបកប្រែ ខ្ញុំឮថានៅចុងឆ្នាំ៧៧ ប៉ុន្តែចម្លើយរបស់លោកពីមុន នៅចម្លើយទី៤ លោកថា នៅដើម -- នៅចុងឆ្នាំ១៩៧៦ ឬដើម១៩៧៧ តើចម្លើយណាដែលលោកជឿថា វាប្រាកដថាត្រូវជាងក្នុងពេលវេលានេះ?

**ឆ៖** ចុង៧៦ ដើម៧៧ ហ្នឹងបាទ ព្រោះការរៀបចំមិនមែន ១ខែ ឬ២ខែអីណា ត្រូវរៀបចំម្តងបន្តិចៗ ត្រូវប្រើពេលវេលាដែរបាទ។ ៧៦ ចុង៧៦ ដើម៧៧ ហ្នឹងរៀបចំបាទ។

[០៩:៤៨:១១]

**ស៖** តើកងវរសេនាធំ១២ហ្នឹង គឺថាត្រូវស្ថិតនៅក្នុងកងពល<ថ្មី២១០ ក្រោយការផ្លាស់ប្តូរនោះ>មែនទេ?

**ឆ៖** វរសេនាធំលេខ១២ វរសេនាដដែល ប៉ុន្តែលេខកងពលត្រូវដូរ មិនដាក់កងពលទី២ទៀតទេ គឺ២១០ កងពលតូច២១០វិញ។ វរសេនាធំលេខ១២របស់ខ្ញុំហ្នឹង ចំណុះឲ្យកងពលដែលដាក់លេខថ្មី២១០វិញ។

01377005



**ស៖** តើកងពលតូច<ថ្មី>ទាំងបួនហ្នឹង <>ត្រូវបានពង្រាយឲ្យមានមូលដ្ឋាននៅតាមព្រំដែននៅខេត្តតាកែវ ទាំងអស់ដែរឬទេ?

**ឆ៖** តាមខ្ញុំចាំបាន គឺថាកងពលទាំងបួនហ្នឹងគឺពង្រាយតាមព្រំដែន។ ខ្ញុំគ្រាន់តែឲ្យចំណុចត្រួសៗទេ គ្រាន់ថា ខ្ញុំដឹងជារួម ពីព្រោះខ្ញុំដឹងតែក្របខ័ណ្ឌវរសេនាធំខ្ញុំទេ ច្បាស់ ប៉ុន្តែខ្ញុំអាចដឹងជារួមថាកងពលទាំងបួនហ្នឹងពង្រាយតាមព្រំដែន។ កងពល២៧០ហ្នឹងគឺថាដាក់នៅយើងទន្លេបាសាក់ ព្រំដែនវៀតណាមបាទ។ ហើយ២១០ហ្នឹង ទល់ព្រែកជីកវិញតេ ម្តុំមាត់ជ្រូក ចូវដុកនេះ។ ហើយកងពល២៥០ហ្នឹង ម្តុំគេហៅជាប់ព្រំដែនកំពតហ្នឹង គេហៅសំបុកមាន់ហ្នឹង បាទ គឺពង្រាយតាមព្រំដែន អត់មាននៅៗខាងនេះទេបាទ។ អត់នៅខាងក្នុងទេ។ ចែកបរិវេណគ្នាទទួលខុសត្រូវអ៊ីចឹង។

**ស៖** សូមលោកជម្រាបតុលាការ ដោយការប៉ាន់ប្រមាណ ថាតើក្នុងកងពលតូចនីមួយៗហ្នឹង តើមានកម្លាំងចំនួនប៉ុន្មានដែរ តាមដែលលោកចាំ?

**ឆ៖** ខ្ញុំមិនយល់ថា កងពលផ្សេងមានចំនួនប៉ុន្មានទេ ប៉ុន្តែដោយឡែក កងពល២១០ដែលខ្ញុំកាន់វរសេនាធំលេខ១១២ហ្នឹង មាន១៨០០ ទៅ២០០០នោះ ជំនាន់ហ្នឹង។

**ស៖** តើលោកដឹងពីមូលហេតុដែរឬទេ ហេតុអ្វីបានជាគេបញ្ជូនកងពលតូចទាំងអស់នេះ ឲ្យទៅឈរជើងនៅតាមព្រំដែនវៀតណាម?

**ឆ៖** ហេតុផលនេះ ខ្ញុំមិនច្បាស់លាស់យ៉ាងណានោះទេ គ្រាន់ថា ភារកិច្ចរបស់កងទ័ពពេលនោះគឺថាការពារបូរណភាពទឹកដី។ អ៊ីចឹងថ្នាក់លើគ្រាន់តែណែនាំថា អង្គភាពអស់លោកត្រូវតែឈរនៅនេះៗដើម្បីការពារទឹកដីប៉ុណ្ណឹងទេ។ ឯហេតុផលផ្សេងទៀត អត់ទាន់បានដឹងទេ។

[០៩:៥២:០៥]

**ស៖** ចាតើលោកបានទទួលការណែនាំបែបនេះមកពីណា ដែលថាដើម្បីទៅតាមព្រំដែន ដើម្បីការពារប្រទេសហ្នឹង តើអ្នកណាជាអ្នកផ្តល់ការណែនាំ?

**ឆ៖** ខ្ញុំសូមជម្រាបផងដែរថា ការណែនាំនេះ គឺកងពលជាអ្នកណែនាំ ពីព្រោះខ្ញុំវរសេនាធំហើយជារួមប្រទេសនីមួយៗសុទ្ធតែមានកម្លាំងនៅតាមព្រំដែនដូចគ្នា។ វៀតណាមក៏មាន ផ្នែកកម្ពុជាក៏មានបាទ។ ពង្រាយដូចគ្នា។

**ស៖** នៅក្នុងពេលដែលលោកនៅខេត្តតាកែវនៅពេលនោះ ថាតើមានជម្លោះ ឬក៏ថាការច្បាំងគ្នារវាងកម្ពុជា និងប្រទេសវៀតណាមឬទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** នៅពាក់កណ្តាលឆ្នាំ៧៧ ដូចជាមានជម្លោះនៅខាងតាកែវហើយ បាទ រវាងវៀតណាម និងកម្ពុជា ចាប់ផ្តើមតិចៗហើយ។

**ស៖** នៅពេលដែលលោកនិយាយពីជម្លោះនេះ តើលោកនិយាយពីកងទ័ពច្បាំងគ្នាជាមួយនឹងភាគីម្ខាងទៀតដោយប្រើអាវុធ។ តើលោកមានន័យដូច្នេះ ឬដូចម្តេច?

**ឆ៖** មានន័យថា ឆ្នាំ៧៧ហ្នឹង រវាងកម្ពុជានិងវៀតណាមចាប់ផ្តើមបាញ់គ្នាបណ្តើរៗហើយ និយាយឲ្យចំទៅថាបាញ់គ្នាហើយ។ ហើយបាញ់គ្នា ទាក់ទងនឹងបូរណភាពទឹកដីបន្តិចៗហ្នឹង បាទ។

[០៩:៥៤:១២]

**ស៖** តើវរសេនាធំ១២នេះ តើធ្លាប់បានបោះទីតាំងមូលដ្ឋាននៅអង្គរបុរី ដែលថានៅជិតព្រំដែនខ្មែរ-វៀតណាមនៅពេលនោះដែរឬទេ?

**ឆ៖** វរសេនាធំ១២នេះ មិនមែនបោះនៅអង្គរបុរីទេ។ បើទ័ពពិសេស ២០៣ហ្នឹង បានបោះនៅភ្នំបុរី ក្រោយមកទៅបោះនៅហ្នឹង ប៉ុន្តែខ្ញុំចេញពីហ្នឹងហើយ។ ឯវរសេនាធំលេខ១២នេះ គឺបោះភ្នំដិនព្រែកជីកវិញតែនេះទេ។

**ស៖** តើវរសេនាធំរបស់លោកបានធ្វើការវាយប្រហារតទល់ជាមួយទ័ពខាងវៀតណាមដែរឬទេ?

**ឆ៖** វរសេនាធំខ្ញុំគឺថាធ្លាប់វ៉ៃប្រហារជាមួយវៀតណាមនៅព្រែកជីកវិញតេហ្នឹងហ្នុង ព្រំដែនហ្នឹងហ្នុង បាទ បាញ់ទៅបាញ់មកនឹងព្រំដែនហ្នឹងហ្នុង។ ហើយទាក់ទងអី ទាក់ទងនឹងជម្លោះហ្នឹងដំបូងទាក់ទងនឹងបញ្ហាដីតិចតួចៗហ្នឹង។

**ស៖** សុំលោករៀបរាប់ជូនតុលាការអំពីការវាយប្រហារកងវរសេនាធំលេខ១២របស់លោកហ្នឹងដែលថា វាយតទល់គ្នាជាមួយវៀតណាមកាលនោះមានស្ថានភាពដូចម្តេចដែរ?

**ឆ៖** ខ្ញុំសុំជម្រាបថានៅឆ្នាំ១៩៧៧នេះ ការវាយប្រហាររវាងកម្ពុជានិងវៀតណាមនេះមិនទាន់អីខ្លាំងក្លាទេ មានសភាពតិចតួចៗ គេហៅថាផ្ទុះៗអាវុធតាមកន្លែង តាមដុបៗទេ អត់ទាន់មានបង្កហេតុអីឲ្យធំដុំទេ បាទ។ ខ្ញុំសុំជម្រាបអ៊ីចឹង។

[០៩:៥៦:៤១]

**ស៖** នៅក្នុងពេលនោះ តើកងទ័ពវៀតណាមបានវាយ បានចូលមកក្នុងទឹកដីរបស់ខ្មែរដែរឬទេនៅពេល អំឡុងពេលវាយប្រហារគ្នានោះ?

**ឆ៖** ខ្ញុំចាំបានថា នៅចុងឆ្នាំ៧៧ កងទ័ពវៀតណាមបានវ៉ៃប្រហារចូលមកៗដល់ជិតទីរួមខេត្តតាកែវនេះ បាទ ចម្ងាយពីព្រំដែនឆ្ងាយណាស់ បាទ ម៉ាចុង៧៧ ម៉ាក្លួងហ្នឹង គឺមកឆ្ងាយមែនទែន បាទ។ ខ្ញុំសុំជម្រាបអ៊ីចឹង។

**ស៖** ខ្ញុំអានជូនលោកអំពីលោក ចម្លើយពីមុនរបស់លោកគឺក្នុងឯកសារ <E1/193.1> នៅម៉ោង ១៥:២៨:១១វិនាទី លោករៀបរាប់អំពីជម្លោះ៖ “នៅឆ្នាំ១៩៧៧នៅតាកែវ និងកំពត មានការវាយប្រហារខ្លាំង។ នៅដល់ពាក់កណ្ដាលឆ្នាំ១៩៧៧ កងទ័ពវៀតណាមបានវាយឈ្លានពានចូលមកតំបន់ជិតខេត្តតាកែវ ពីព្រំដែនតាកែវ។ ប៉ុន្តែកងទ័ពខ្មែរក្រហមបានវាយដេញទៅវិញ គឺបាញ់គ្នារុញទៅរុញមក គឺថាយើងពេលនោះគឺថា យើងបាញ់គ្នាទៅវិញទៅមក ដូចជាប្រទាញប្រទង់គ្នា។” ហើយលោកបន្តនិយាយថា៖ “ការវាយប្រហារនោះគឺបាញ់ទៅវិញទៅមក ជួនកាលប្រើរយៈពេលមួយខែ ឬពីរខែ ហើយយើងរុញពួកគេទៅព្រំដែន ក្រោយមកគេរុញមកវិញ។ បាទ គឺថាស្ថានភាពនេះគឺកើតមានឡើងស្រដៀងគ្នាដែរ នៅស្វាយរៀង។” នៅក្នុងសក្ខីកម្មពីមុនហ្នឹង លោកនិយាយថា ជម្លោះនោះគឺថា នៅក្នុងសេចក្ដីដកស្រង់នេះគឺថា នៅដើមឆ្នាំ១៩៧៧ឯណោះ តាំងពីដើមឆ្នាំ៧៧ មក។ តើអ៊ីចឹងត្រូវឬទេ?

**ឆ៖** ចាប់ផ្ដើមពីដើមឆ្នាំ៧៧ ប៉ុន្តែដែលវ៉ៃគ្នាខ្លាំងគឺពាក់កណ្ដាល៧៧ហើយ បាទ។ រុញទៅរុញមកហ្នឹង ពីដើមឆ្នាំ៧៧ ដល់ពាក់កណ្ដាល៧៧ហ្នឹង រុញទៅរុញមកដូចគ្នា។ ប៉ុន្តែកម្ពុជារុញបានត្រឹមព្រែកជីកវិញតេទេ ព្រំដែនទេ។ ដល់វៀតណាមរុញមកវិញ គឺជិតដល់តាកែវឯណោះបាទ។ អាហ្នឹងសុំជម្រាបអ៊ីចឹង។

[០៩:៥៩:៣៣]

**ស៖** នៅក្នុងសេចក្ដីដកស្រង់ដែលខ្ញុំបានអានជូនលោកនោះ លោកនិយាយថា មានការវាយប្រហារយ៉ាងឃោរឃៅ ឬក៏យ៉ាងខ្លាំងក្លា ក៏កើតឡើងនៅខេត្តកំពតផងដែរ។ តើលោក<ក៏បានឈរជើងនៅចំណុចមួយចំនួន ក្នុង>ខេត្តកំពតដែរ ឬ<>?

**ឆ៖** ខ្ញុំអត់បានទៅដល់ខេត្តកំពតទេ ប៉ុន្តែអង្គភាពដែលចាប់ដៃគ្នាតាមព្រំដែនហ្នឹងគឺ ឲ្យព័ត៌មានមក។ ធម្មតាចាប់ដៃគ្នាទៅប្រយុទ្ធ។ អ៊ីចឹងអង្គភាពដែលចាប់ដៃហ្នឹង គឺផ្ដល់ព័ត៌មានថាមានការប្រយុទ្ធគ្នានៅព្រំដែនខាងកំពតដែរបាទ។

**ស៖** នៅពេលដែលប្រយុទ្ធជាមួយវៀតណាមក្នុងឆ្នាំ៧៧ លោកមានបានរងរបួសដែរទេ?

**ឆ៖** ខ្ញុំបានត្រូវរបួសនៅព្រែកជីកវិញតេហ្នឹង ត្រូវដៃ នៅក្រវ៉េរដល់ឥឡូវហ្នឹង រងរបួស។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សៈ** លោករងរបួសដោយរបៀបណាដែរ?

**ឆៈ** ត្រូវគ្រាប់បែ៤០ ត្រូវដៃ ក្រង៉ែង។

**សៈ** តើកងទ័ព នៅក្នុងកងវរសេនាធំរបស់លោកហ្នឹងមានទទួលរងរបួសច្រើននាក់ទេ នៅពេលដែលប្រយុទ្ធជាមួយវៀតណាមនោះ?

**ឆៈ** ជាធម្មតាទេ ខ្ញុំអាចជឿថាលោកប្រធាន អស់លោកទាំងអស់យល់ហើយថា ប្រទេសវៀតណាមជាប្រទេសធំ កងទ័ពច្រើន អាវុធច្រើន អ៊ីចឹងកម្ពុជាតូច អាវុធក៏តិច ហើយអាវុធក៏មិនទំនើប។ អ៊ីចឹងពេលប្រយុទ្ធជាមួយវៀតណាមម្តងៗ គឺថាការស្លាប់បាត់បង់អាយុជីវិតនិងពលិកម្មគឺរបួសច្រើនៗ។

[១០:០១:៥៣]

**សៈ** ការរងរបួស ក្រៅពីរងរបួសនេះ គឺមានអ្នកស្លាប់ផងដែរទេ?

**ឆៈ** មាន ខ្ញុំជម្រាបថា ក្រៅពីអ្នករងរបួស គឺស្លាប់ក៏ច្រើនគួរសមដែរ។

**សៈ** តើលោកអាចប៉ាន់ប្រមាណបានទេ <សមាជិក>នៅក្នុងវរ<សេនាធំ>របស់លោកនៅពេលប្រយុទ្ធជាមួយវៀតណាមក្នុងឆ្នាំ១៩៧៧ ហ្នឹង ពលីអស់ប៉ុន្មាននាក់ដែរ?

**ឆៈ** ខ្ញុំគ្រាន់ថាផ្តល់ការប្រយុទ្ធគ្នាពាក់កណ្តាលឆ្នាំ១៩៧៧ នៅព្រែកជីកវិញតេ មុខភ្នំដិនហ្នឹង។ វរសេនាតូចមួយចំណុះឱ្យវរសេនាធំរបស់យើងខ្ញុំហ្នឹង មួយវរសេនាតូចហ្នឹងស្លាប់អស់១៧០នាក់ ពេលប្រយុទ្ធម្តងទៀត វៀតណាមព័ទ្ធជាប់ ហើយរថក្រោះវៀតណាម យន្តហោះ ស្លាប់អស់១៧០នាក់ ភ្លាមក្នុងរយៈពេល១ថ្ងៃ១យប់។ ឯកងពល ឬវរសេនាធំផ្សេងទៀត ខ្ញុំមិនបានដឹងទេ ប៉ុនដោយឡែកតែវរសេនាធំខ្ញុំស្លាប់ប៉ុណ្ណឹង ប្រយុទ្ធធំហើយហ្នឹង ១ថ្ងៃ១យប់ពេញតែម្តង។

**សៈ** លោកទើបតែលើកឡើងអំពីការទម្លាក់គ្រាប់បែកពីសំណាក់កប៉ាល់ហោះ និងការប្រើប្រាស់រថក្រោះ គឺវៀតណាមប្រើប្រាស់យន្តហោះ ដើម្បីទម្លាក់គ្រាប់មកលើទីតាំងរបស់កងទ័ពលោក តើអ៊ីចឹងមែនទេ?

**ឆៈ** ពេលនោះមិនទាន់មានយន្តហោះអីទម្លាក់អីធំទេ មានយន្តហោះបាញ់រ៉ុក្កែតហ្នឹង បាញ់រ៉ុក្កែតអាយន្តហោះទម្លាក់គ្រាប់ធំៗអត់មានទេ ក្នុងពាក់កណ្តាល៧៧ហ្នឹង ប៉ុនបើរថក្រោះ កាំភ្លើងធំ គឺសំបូរបែបតែម្តង។

[១០:០៤:១១]

**សៈ** ចុះខាងកងទ័ពលោកវិញនោះ តើប្រើប្រាស់អាវុធប្រភេទណាដែរ ដើម្បីវាយបកទៅវៀត-

ណាមវិញ?

**ឆ៖** សម្រាប់ខាងកម្ពុជាវិញ ក៏មានរថក្រោះ ហើយក៏មានកាំភ្លើងធំ ប៉ុន្តែចំនួនគ្រាប់អីនោះវាតិច ការប្រើប្រាស់អីចំនួនតិចណាស់ តិច ប៉ុន្តែមានរថក្រោះក៏មាន កាំភ្លើងធំក៏មាន។

**ស៖** តើក្នុងពេលប្រយុទ្ធគ្នាហ្នឹង វរ<សេនាធំ>របស់លោកហ្នឹងមានបានសម្លាប់កងទ័ពវៀត-ណាមខ្លះដែរទេ?

**ឆ៖** ខ្ញុំយល់ឃើញថាសមរភូមិវៀតណាមមានប្រៀបជាង។ បើវៀតណាមមានប្រៀបជាងយើងមិនអាចដឹងថាវៀតណាមស្លាប់ប៉ុន្មាន របួសប៉ុន្មានទេ ប៉ុន្តែការប្រយុទ្ធគ្នាពិតជាមានហើយ ប៉ុន្តែខាងខ្ញុំមិនដឹងចំនួនបាទ អត់ដឹងចំនួនទេ ពីព្រោះយើងមិនបានៗដឹងទេ ខាងវៀតណាមបាទ។

**ស៖** តើលោកចាកចេញពីខេត្តតាកែវនៅពេលណាដែរ?

**ឆ៖** ខ្ញុំចេញពីខេត្តតាកែវទៅខេត្តស្វាយរៀងនៅពាក់កណ្តាលឆ្នាំ៧៨។ ខាងថ្នាក់លើតម្រូវឲ្យខ្ញុំចេញពីតាកែវទៅខេត្តស្វាយរៀងវិញ។ គេរៀបចំពីចុង៧៧ហ្នឹង ហើយចេញទៅ៧៨។

**ស៖** ពិតហើយថាមានការខ្វះចន្លោះមួយ។ លោកបានប្រាប់ទៅសហចៅក្រមស៊ើបអង្កេតត្រង់ចម្លើយលេខ៥ នៃកំណត់ហេតុស្តាប់ចម្លើយរបស់លោកថា លោកបានទៅស្វាយរៀងនៅពាក់កណ្តាលឆ្នាំ៧៨ ក៏ប៉ុន្តែនៅពេលដែលលោកមកផ្តល់សក្ខីកម្មចំពោះមុខតុលាការនៅម៉ោង ១០:១៤:០៦ លោកថានៅដើមឆ្នាំ៧៨ទៅវិញ។ អ៊ីចឹងតាមដែលលោកចងចាំបានល្អបំផុតនោះ តើ<សក្ខីកម្មរបស់លោក គឺថាបើទោះបីជាការ>រៀបចំខ្លួន<សម្រាប់រូបលោក ដើម្បីផ្លាស់ទៅ នៅចុងឆ្នាំ១៩៧៧ គឺថា>លោកទៅស្វាយរៀងហ្នឹងនៅពាក់កណ្តាលដើមឆ្នាំ៧៨ុ<>?

**ឆ៖** ខ្ញុំសូមជម្រាបថា ជាគោលការណ៍ គឺទៅដើមឆ្នាំ៧៨ ប៉ុន្តែមុននឹងទៅហ្នឹង គឺគេរៀបចំឲ្យយើងខ្ញុំកាន់ជាប្រធានកងពល។ អ៊ីចឹងទៅជ្រើសរើសទ័ពពីគ្រប់បណ្តាកងពលទាំងអស់ ដែលខ្ញុំរៀបរាប់ថាមានកងពល៣១០, ៣៣០, ៣៥០, ៣៧០ អម្បាញ់មិញនេះ។ អ៊ីចឹងបីកងពលហ្នឹងគេទៅរើសមកឲ្យខ្ញុំមួយវរសេនាធំមួយកង។ អ៊ីចឹងបានបួនវរសេនាធំ បង្កើតទៅជាបាន បង្កើតទៅជាកងពលតូច២២១ អន្តរាគមន៍។ អ៊ីចឹងពាក់កណ្តាល៧៨ ទម្រាំរៀបចំហើយពាក់កណ្តាល៧៨បានចេញទៅ។

[១០:០៧:៤៩]

**ស៖** សូមអរគុណចំពោះការបំភ្លឺនេះ។ តើការ<>ប្រយុទ្ធ<គ្នាជាមួយវៀតណាម នៅតំបន់តាកែវហ្នឹង គឺនៅបន្ត>រហូតដល់ពេលលោកចាកចេញពីស្វាយរៀងតែម្តងឬ?

**ឆ៖** ខ្ញុំសូមជម្រាបលោកប្រធានអស់លោកទាំងអស់ថា ពេលដែលខ្ញុំធ្វើដំណើរពីតាកែវទៅដល់ខេត្តស្វាយរៀង ហើយហួសទីរួមខេត្តទៅបន្តិចគេហៅស្រុកប្រសូត្រ មិនទាន់បានចុះឡានផង វៀតណាមវ៉ៃហើយស្រេចទៅហើយ។ ទ័ពគ្រាន់តែដឹកទៅដល់ហ្នឹង គឺវៀតណាមស្វាគមន៍ហើយស្រេច មិនដឹងចល័តមកពីណាផង។ អ៊ីចឹងគ្រាន់ទៅដល់ហ្នឹងអស់ពីរឡានហើយស្រេចហើយ។ កងពលដែលរៀបថ្មីឱ្យខ្ញុំទៅហ្នឹង អាហ្នឹងសូមជម្រាបអ៊ីចឹង នៅត្រង់ស្រុកប្រសូត្រហ្នឹងហ្មង។

**ស៖** ខ្ញុំសូមសួរបញ្ជាក់បន្តិច តើការវាយប្រហារដែលលោករៀបរាប់កើតឡើងនៅឯស្រុកប្រសូត្រ ហ្នឹង តើនៅក្នុងខេត្តស្វាយរៀងឬក៏ប្រសូត្រនេះនៅឯតាកែវ មុនពេលដែលលោកចាកចេញទៅស្វាយរៀងទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា ខ្ញុំជម្រាបថាស្រុកប្រសូត្រអម្បាញ់មិញនេះ គឺនៅក្នុងខេត្តស្វាយរៀង។ គ្រាន់តែខ្ញុំនាំទ័ពទៅដល់ស្រុកប្រសូត្រហ្នឹង វៀតណាមវ៉ៃផេះពីរឡានហើយស្រេចហើយ។ ហើយបន្តពីហ្នឹងមកចាប់ផ្ដើមប្រយុទ្ធគ្នារហូតអត់មានឈប់ទេ បាទអត់ឈប់ទេ ទាំងយប់ទាំងថ្ងៃៗ របួសគ្រោះថ្នាក់ ហើយខ្ញុំសូមជម្រាបផងដែរថា ខ្ញុំទៅដល់ស្វាយរៀងហ្នឹង ក៏ខ្ញុំរបួសដែរ។ របួសត្រូវគ្រាប់រថក្រោះពីរគ្រាប់ ពីរអំបែងនៅភ្លៅនេះទៀត ហើយខ្ញុំមកដេកពេទ្យភ្នំពេញហ្នឹងបានជិត៣ខែបានត្រឡប់ទៅវិញ។ គ្រាន់ត្រឡប់ទៅវិញវៀតណាមមកចូលមកធំហ្នឹងបណ្ដោយ។ អាហ្នឹងសូមជម្រាបតែប៉ុណ្ណឹងបាទ។

[១០:១០:០៦]

**ស៖** នៅពេលដែលលោកចាកចេញពីតាកែវទៅស្វាយរៀង តើនៅឯតាកែវហ្នឹង ការប្រយុទ្ធជាមួយវៀតណាមនៅតែបន្តទៅមុខទៀតឬ?

**ឆ៖** សូមជម្រាបថា នៅតាកែវ នៅបន្តប្រយុទ្ធ ប៉ុន្តែមិនខ្លាំងដូចមុនទេ កម្រិតល្មមបានជាថ្នាក់ដឹកនាំកម្ពុជាប៉ានដកកម្លាំងពីតាកែវទៅស្វាយរៀងដោយមូលហេតុថាតាកែវហ្នឹងវាមានកម្រិតធម្មតាបាទ ប្រយុទ្ធហ្នឹងធម្មតា។

**ស៖** តើ<លោកដឹងថា>កងទ័ពខ្មែរក្រហម<នៅខេត្តតាកែវ>នោះ ដែលឆ្លងចូលទៅក្នុងទឹកដីវៀតណាម ដើម្បីវាយប្រយុទ្ធជាមួយវៀតណាមនៅក្នុងទឹកដីវៀតណាមដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា លោកប្រធាន អស់លោកទាំងអស់ជ្រាបហើយថា យុទ្ធសាស្ត្រសង្គ្រាមខ្ញុំជឿថាអស់លោក លោកប្រធានទាំងអស់យល់ យុទ្ធសាស្ត្រសង្គ្រាមគឺថាបើវៀតណាមវ៉ៃចូល យើងរង់ចាំទ្រវៀតណាម គឺទ្រអត់ជាប់ទេ អ៊ីចឹងយើងត្រូវតែទៅវ៉ៃពីក្រោយមកវិញដែរ ទៅវ៉ៃពីក្រោយគ្មាន

បំណងអីទៅរំដោះដីអីកម្ពុជាក្រោមអីទេ ទៅ -- មានបំណងគឺ ធ្វើម៉េចឲ្យកម្លាំងទល់មុខដកទៅទប់នៅខាងក្រោយវិញ គឺៗមាន ល្បិចនេះគឺមាន។ ហើយខ្ញុំជឿថាលើសាកលលោកមានដូចគ្នា នៅឯណាក៏មានដែរ ឲ្យតែវៃចូលគឺត្រូវតែវៃបក ឬវៃពីក្រោយវិញបានៗទប់បាន បាទ។

[១០:១១:៥៧]

**ស៖** អ៊ីចឹងវរសេនាធំរបស់លោកហ្នឹង គឺចូលទៅវាយប្រយុទ្ធវៀតណាមពីខាងក្រោយវិញដើម្បីធ្វើម៉េចឲ្យកងទ័ពវៀតណាមហ្នឹងដកចេញពីទឹកដីកម្ពុជា ដកចេញពីការវាយប្រយុទ្ធទល់មុខគ្នាវិញអ៊ីចឹងមែនទេ?

**ឆ៖** អ៊ីចឹង

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

លោកប្រធាន ខ្ញុំចាប់ផ្ដើមសួរនេះគឺថាយឺតពេល១៥នាទីមកហើយមុនពេលយើងចាប់ផ្ដើមពីព្រឹកនោះ អ៊ីចឹងតើបន្តទៅទៀត ឬក៏សម្រាកសិន?

[១០:១២:៣៥]

**ប្រធានអង្គជំនុំ៖**

លោកបន្តសួរទៅ អ្នកគ្រប់គ្រងពេលវេលានៃសវនាការ គឺប្រធានសវនាការជាអ្នកគ្រប់គ្រងសម្របសម្រួល។

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

**ស៖** លោកសាក្សី តើលោកស្គាល់ខេត្តវៀតណាមដែលនៅជាប់នឹងព្រំដែនខេត្តតាកែវទេ គឺខេត្តអានយ៉ាង?

**លោក អៀង ផាន៖**

**ឆ៖** ខ្ញុំស្គាល់តែខេត្តចូវដុក ច្រមុះជ្រូក។

**ស៖** ខ្ញុំសូមអានឯកសារមួយដែលយើងមានក្នុងសំណុំរឿងហើយ គឺឯកសារ E3/1257 ជារបាយការណ៍<សារព័ត៌មានវៀតណាម>និយាយអំពីការឈ្លានពានពីសំណាក់កងទ័ពខ្មែរក្រហមនៅ<ថ្ងៃទី១៨ ខែមករា> ក្នុងឆ្នាំ១៩៧៨។ នេះ ERN ជាភាសាអង់គ្លេស 00008675, បារាំង 0041

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

6717, ខ្មែរ 00224846។ សូមដកស្រង់៖ “នៅម៉ោងប្រាំ ថ្ងៃទី១១ ខែមករា កងវរសេនាធំលេខ១២, ១៤ <នៃកងពលធំទី២ របស់កងកម្លាំងប្រដាប់អាវុធកម្ពុជា>បានឆ្លង<ព្រំដែន ហើយ>បានវាយ<> ទៅ<លើតំបន់នៅខាងត្បូង និងព្លៃសានទិញបៀន> និងខេត្តអានយ៉ាង។ ពួកគេបានប្រព្រឹត្តឧក្រិដ្ឋកម្មជាច្រើនរួមទាំងសម្លាប់អ្នកភូមិ អ្នកស្រុក ដុតបំផ្លាញផ្ទះសម្បែង<២១៣>ខ្នង <សម្លាប់ និង>របួសជនស៊ីវិល២៣នាក់ ហើយក្នុងនោះមានរឹបអូសយកសត្វពាហនៈ<គោ និងក្របី ចំនួន៣០ក្បាល។ កងកម្លាំងរបស់យើងប្រចាំក្នុងតំបន់នោះបានវាយប្រហារតបវិញ ហើយបានសម្លាប់២១៥នាក់> ហើយគឺថាបានប្រព្រឹត្តនូវឧក្រិដ្ឋកម្មទាំងអស់នេះ ហើយធ្វើឲ្យអ្នកទាំងអស់ហ្នឹង គឺថាដកចេញពីព្រំដែនទៅវិញ។ ហើយក្រោយមក កង<>កាំភ្លើងធំ<របស់កម្ពុជាដែលបោះទីតាំងជ្រៅក្នុងទឹកដីកម្ពុជាបានបាញ់>ផ្លោងចូល<មកលើតំបន់នោះ>។”បញ្ចប់ការដកស្រង់។ លោកសាក្សី របាយការណ៍សារព័ត៌មាននេះ និយាយថា គឺកង<>វរសេនាធំលេខ១២ <នៃកងពលទី២ តើវាគឺជាកងវរសេនាធំរបស់លោក>មែនទេ?

**ឆ៖** ខ្ញុំដូចជាមិនៗមិនយល់ថា ខាងវរសេនាធំ ខ្ញុំចូលទៅវាយដល់លំនៅដ្ឋានរបស់វៀតណាម ពីព្រោះឆ្នាំដែលប្រយុទ្ធជាមួយវៀតណាមនោះ អត់ឆ្លងផុតព្រែកជីកវិញតេផងទុំង។ វៀតណាមនៅក្រាស់ឃ្មឹកដូចនេះអ៊ីចឹង។ របាយការណ៍ហ្នឹងយ៉ាងម៉េច ខ្ញុំមិនយល់ដែរបាទ។

[១០:១៥:៥៨]

**ស៖** លោកសាក្សី លោកថា មានពេលមួយលោកបានចូលទៅក្នុងទឹកដីវៀតណាមដើម្បីវាយកងទ័ពវៀតណាមពីខាងក្រោយមកវិញ។ អ៊ីចឹងវាហាក់បីដូចជា ផ្ទុយគ្នានឹងអ្វីដែលលោកទើបនឹងឆ្លើយអម្បាញ់មិញថា អត់បានទាំងចូលទៅផង ឆ្លងមិនទាំងផុត<តំបន់>ព្រែកជីក<វិញ នោះទេ នៅពេលដែលនៅតាកែវ>។ បាទ អ៊ីចឹងយ៉ាងម៉េចដែរ ម៉េចបានចម្លើយនេះវាផ្ទុយគ្នាយ៉ាងដូច្នេះ?

**ឆ៖** ខ្ញុំចង់ពន្យល់លោកថា ការប្រយុទ្ធគ្នានេះ វាមានទៅមានមក ប៉ុន្តែឲ្យសម្រាប់ខាងខ្ញុំចូលទៅជ្រៅ អត់ចូលទៅបានទេ ឧបមាថា ព្រែកជីកវិញតេ ចូលបានតែ១០០ម៉ែត្រ ២០០ម៉ែត្រទេ ត្រូវវៀតណាមវ៉ៃថយមកវិញហើយ ព្រោះវៀតណាមច្រើនណាស់ ខ្ញុំប្រយុទ្ធជាក់ស្តែងគឺចូលអត់ចុះទេ។ ខំកៀងទៅឆ្ងាយម៉េចក៏ដោយ ដូចរបាយការណ៍អម្បាញ់មិញនេះ គឺខាងខ្ញុំមិនដែលចូលទៅដល់ភូមិវៀតណាមផងហ្នឹង។ បានតែត្រឹមជើងភ្នំអ៊ី ហួសភ្នំដិនបន្តិច ជើងភ្នំឆ្លងព្រែកជីកទៅបានប្រហែលកន្លះគីឡូ ១គីឡូហ្នឹង គឺត្រូវវៀតណាមវ៉ៃឲ្យរត់មកវិញហើយ អត់ដែលបានទៅដល់ភូមិទេហ្នឹង សម្រាប់វរសេនាធំខ្ញុំ។ វរសេនាធំ១២ហ្នឹង ចូលមែន ប៉ុន្តែចូលបានកម្រិតប៉ុណ្ណឹង អត់ចូលដល់ភូមិបានទេ។ ភូមិម៉េច បើវៀតណាម

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សុទ្ធតែរថក្រោះ សុទ្ធកាំភ្លើងតូច កាំភ្លើងធំ ចូលទៅបាក់មកវិញៗ។ ហើយៗខ្ញុំជម្រាបថា ចូលទៅ មានតែចោលខ្មោចទេ ខាងខ្ញុំ អត់ដែលបានយកមកវិញទេ។ ស្លាប់អត់ដែលបានយកមកវិញទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់ ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សី មកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:១៨ នាទី ដល់ម៉ោង ១០:៣៤ នាទី)*

[១០:៣៤:២៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ផ្ដល់វេទិការជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** លោកសាក្សី មុនសម្រាកយើងបានពិភាក្សាអំពីការវាយប្រហាររបស់ខ្មែរក្រហមចូលទៅទឹកដីវៀតណាម។ លោកបានបញ្ជាក់ថា នៅពេលថាលោកមិនស្គាល់ខេត្តឈ្មោះអានយ៉ាងទេ ប៉ុន្តែលោកស្គាល់ខេត្តចូវដុកនៅប្រទេសវៀតណាម ក៏ជាខេត្តដែលនៅជិតព្រំប្រទល់ខេត្តតាកែវដែរ។ អ៊ីចឹងខ្ញុំចង់អានសេចក្ដីដកស្រង់ពីរគឺពាក់ព័ន្ធទៅនឹងខេត្តចូវដុក។ ទី១គឺចេញពីសៀវភៅរបស់ ស្ទីហ្វិន ម៉ររីស ដែលគាត់មកធ្វើសក្ខីកម្មនៅកន្លែងនេះ គឺមិនយូរប៉ុន្មានទេ គឺនៅក្នុងឯកសារ E3/7338 គឺមានតែភាសាអង់គ្លេសទេ 001001765*(ស៊ីក)* <ទំព័រ>98។ នៅក្នុងសៀវភៅរបស់គាត់ គាត់និយាយថា សុំដកស្រង់៖ “ភាគីវៀតណាម មេដឹកនាំរបស់គេ<ផ្ញើ>សារ<ដល់ដៃគូ ដើម្បីអបអរខួប>ជ័យ<ជម្នះ>។

<ប៉ុន្តែ>កាយវិការល្អ<នេះ> មិនបានផលល្អទេ<សម្រាប់វៀតណាម>។ ខ្មែរក្រហមបានជ្រើសរើស <ខួបជ័យជម្នះ>ទី២<របស់បក្សកុម្មុយនីស្តវៀតណាមទៅលើវៀតណាមខាងត្បូង ដើម្បីបន្សល់ទុកនូវស្លាកស្នាម>បង្ហូរឈាម<មួយ>។ គឺថានៅ<ថ្ងៃទី៣០ ខែមេសា> ក្នុងឆ្នាំ១៩៧៧ ខ្មែរក្រហមបានបានវាយប្រហារទៅភូមិមួយចំនួន ទីក្រុងមួយចំនួននៅអានយ៉ាង ចូវដុក នៅភូមិភាគខាងត្បូងវៀតណាម ដុតផ្ទះសម្បែង ហើយសម្លាប់ប្រជាជនស៊ីវិល<រាប់រយនាក់>។ <មេដឹកនាំ>វៀតណាមមានការរន្ធត់ដោយ<>ការវាយប្រហារ<ស្ងាត់ស្ងៀម>នេះ <ហើយមិនយល់ពីមូលហេតុនៅពីក្រោយយុទ្ធសាស្ត្រនេះ>។ នៅទីបំផុត គេក៏បានធ្វើការសងសឹកខាងយោធាប្រឡប់មកវិញ។" អ៊ីចឹងសេចក្តីដកស្រង់ទី២ ទាក់ទងនឹងខេត្តចូវដុកនោះ គឺចេញពីសៀវភៅរបស់ ប៉ែន ឃៀរនិន គឺE3/1593, អង់គ្លេស ERN <01150185> ដល់ 86, <បារាំង>គឺ 00639136 ដល់ 37 <ហើយភាសាខ្មែរ 00637903 ដល់ 04>។ នេះគឺជាអ្វីដែល ប៉ែន ឃៀរនិន គាត់បាននិយាយ៖ "នៅ<>ព្រំដែនវៀតណាម គឺបាន<ឃើញមាន>អំពើហិង្សា<គ្រោះថ្នាក់បំផុត បង្កឡើងដោយភូមិភាគនិរតីរបស់កម្ពុជាប្រជាធិបតេយ្យ យោងតាម>សេចក្តីសង្ខេបនូវព័ត៌មានមួយចំនួន<បានសង្ខេបថា> អំពីស្ថានភាពគឺកាន់តែដុនដាបខ្លាំង ចាប់ពី <ខែមីនា>ឆ្នាំ<១៩៧៧>ទៅ។ ឯកសារផ្លូវការវៀតណាម <ដែលបោះពុម្ពផ្សាយផ្លូវការ>នៅថ្ងៃទី០៦ មករា ឆ្នាំ១៩៧៨<ឲ្យដឹងថា> កងកម្លាំងខ្មែរបានវាយចូលទៅ<ខេត្តគៀនយ៉ាង និង>អានយ៉ាង<របស់វៀតណាម>នៅថ្ងៃទី១៥ <ដល់ថ្ងៃទី១៨ និងនៅថ្ងៃទី២៥ ដល់ថ្ងៃទី២៨> ខែមីនា ឆ្នាំ១៩៧៧ នៅ<តាមបណ្តោយតំបន់មួយ ដែលមានចម្ងាយជិត>១០០គីឡូម៉ែត្រពីហាទៀងទៅ<ទិញបៀន>។ ហើយកងកម្លាំង<ដ៏រឹងមាំរបស់>កម្ពុជាក៏បានវាយប្រហារ<ប៉ុស្តិ៍ទាហាន>ព្រំដែនវៀតណាម <និងភូមិនៅតាមព្រំដែនក្នុងខេត្តអានយ៉ាង រវាងថ្ងៃទី៣០> ខែមេសា <និងថ្ងៃទី១៩ ខែឧសភា ដោយសម្លាប់ជនស៊ីវិលអស់២២២នាក់> ហើយក៏បាន<បាញ់ផ្លោង>ចូលទៅដល់ចូវដុក<ដែលជាទីប្រជុំជនខេត្ត> គឺថានៅ <ថ្ងៃទី១៧> ខែឧសភា។<> របាយការណ៍នេះ <ត្រូវបញ្ជាក់ដោយពួកជនភៀសខ្លួនវៀតណាម ដែលបានទៅដល់ប្រទេសផ្សេងទៀត នៅអាស៊ី ដោយបានរាយការណ៍ឲ្យដឹងថា ប្រជាជនស៊ីវិល>បានត្រូវគេជម្លៀសចេញពីហាទៀង <នៅថ្ងៃទី១៦ ខែឧសភា> និងចូវដុក <នៅថ្ងៃបន្ទាប់ ក្រោយពីមានការ>ផ្លោងបាញ់ចូលទៅដល់<ទីក្រុងទាំងពីរ>។" ចប់សេចក្តីដកស្រង់។

[១០:៣៨:៥០]

អ៊ីចឹងសេចក្តីដកស្រង់ទាំងពីរនេះ គឺវាលើកឡើងអំពីការវាយប្រហារទៅនឹងខេត្តមួយចំនួនតាម

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

ព្រំដែន<រួមទាំង>ខេត្តចូវដុក <ដែលលោកបានស្គាល់នោះ>។ តើខ្លឹមសារនេះធ្វើឱ្យលោកនឹកឃើញដែរឬទេថា មានការវាយប្រហារដែលថា កងកម្លាំងមកពីនិរតីបានចូលរួម<វាយប្រហារ>គឺថា នៅ<ពាក់កណ្ដាល និងចុង>ឆ្នាំ១៩៧៧ <វាយចូលក្នុងខេត្តចូវដុក> ដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប! អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ នេះជាចំណុចគួរឱ្យចាប់អារម្មណ៍ណាស់ គឺថាសហព្រះរាជអាជ្ញាបានលើកពីចំណុចនេះឡើង។ ខ្ញុំសូមជំទាស់ ដោយផ្អែលលើមូលដ្ឋានមួយចំនួន លោកប្រធាន។ ចំណុចទី១ ខ្ញុំគាត់សម្គាល់ថា ចៅក្រមអន្តរជាតិពីររូបគឺថាបានសួរ<ខាងព្រះរាជអាជ្ញា>ថាតើប្រភពនៃព័ត៌មានហ្នឹងមកពីណា ដែលសរសេរនៅក្នុងសៀវភៅលោក ម៉័ររីស ហើយនិង ប៉ិន យៀវនិន ហ្នឹង <គឺជាសំណួរមួយដែល>យើង<តែងតែ>បានទទួល<>។ អ៊ីចឹងគឺថាចំណុចទី២របស់ខ្ញុំ ម៉័ររីស គាត់និយាយពីការវាយប្រហារ<ចូលទៅលើទឹកដីវៀតណាម> នៅថ្ងៃទី៣០ មេសា ឆ្នាំ១៩៧៧ គឺ ម៉័ររីស មិនបានមានប្រភពច្បាស់លាស់ គាត់<បានលើកឡើងវិញនូវអ្វីដែល> ចាន់ដា <បានសរសេរ>។ ហើយ ចាន់ដា គាត់បានផ្អែកទៅលើរបាយការណ៍ឃោសនារបស់វៀតណាម ដែលគេចុះផ្សាយនៅ<ខែមករា>ឆ្នាំ១៩៧៨ ហើយ ប៉ិន យៀវនិន ក៏បានយោងទៅលើឯកសារប្រហាក់ប្រហែលនេះដែរ តាមរបៀបស្រដៀងគ្នា។ នេះជាបញ្ហាដែលចោទ ជាពិសេសគឺទាក់ទងទៅនឹង ណាយ៉ាន់ ចាន់ដា មិនបានមកធ្វើសក្ខីកម្មជាអ្នកជំនាញទេ ដើម្បីឱ្យគាត់បញ្ជាក់ពីប្រភពព័ត៌មានដើមរបស់គាត់នោះ។

[១០:៤០:៥១]

បន្ទាប់ពីនេះទៀតគឺថា អ្វីៗដែលយើងឃើញនៅក្នុងសៀវភៅនេះគឺថាយើងនិយាយពីអង្គហេតុ ពីការវាយប្រហារនៅក្នុងទឹកដីវៀតណាម ថាតើពិតជាកើតមែនដែរឬទេ។ យើងមិនបានរកឃើញភស្តុតាងដែលស៊ីចង្វាក់នោះទេ ហើយគឺក្រៅអង្គហេតុនោះដែរ។ ក្នុងករណីដែលសហព្រះរាជអាជ្ញាអាចនឹងបង្ហាញភស្តុតាង <នៃការវាយប្រហារនៅ>ថ្ងៃទី៣០ មេសា ឆ្នាំ<១៩៧៧> នោះ ខ្ញុំនឹងគោរពតាម។

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

ខ្ញុំឆ្លើយតបទៅនឹងសក្ខីកម្ម ដែលមេធាវីការពារក្ដីបានអះអាងនោះ គឺថាប្រភពគឺគាត់ខ្លួនឯង គាត់យោងពីប្រភពរបស់ ដែលគាត់លើកឡើងហើយ ស្ទីហ្វិន ម៉័ររីស គាត់បានលើកឡើងពីប្រភពហើយ

<នៅក្នុងសៀវភៅរបស់គាត់។ ចំណែកឯ> ប៉ែន យៀរនិន ក៏បាន<លើកឡើង ប្រភព<នោះពិតជាមាន>នៅក្នុង<សម្រង់ដែលខ្ញុំបានអាន> គឺ<>បណ្ណសារ<សម័យរបស់ ឃើស៊ីង។ មេធាវីការពារក្តីមានសេរីភាពក្នុងការជំទាស់លើបញ្ហាតូចតាច ដូចជាប្រភពរបស់អ្នកជំនាញដែល>គាត់បានស្នើសុំឲ្យបុគ្គលនោះមកធ្វើសក្ខីកម្ម -- <គាត់បានស្នើសុំថាត្រូវតែកោះហៅមកផ្តល់សក្ខីកម្មដោយ>ផ្អែក<ទៅលើ ទោះបីជាមិនត្រូវពេលវេលា ឬក៏ទីកន្លែងក៏ដោយ>។ អ៊ីចឹងគឺថាពាក់ព័ន្ធទៅនឹងវិសាលភាព ពីជម្លោះប្រដាក់អាវុធនេះ គឺស្ថិតនៅក្នុងវិសាលភាពនៃរឿងក្តី ០០២/០២ នៅក្នុង១ដីកាដំណោះស្រាយ <> កថាខណ្ឌ១៥៣ <និយាយអំពីការវាយប្រហារនៅក្នុងព្រំដែនវៀតណាម ហើយវាក៏>ទាក់ទងទៅនឹង<>ទ្រឹស្តី<ដែលអះអាងដោយមេធាវីការពារ>ក្តីរបស់លោក នួន ជា <ពាក់ព័ន្ធទៅនឹង>គឺថាការវាយប្រហារដោយមិនមានការអុចអាលពីភាគីខាងវៀតណាម<មកលើកម្ពុជា>។ ដូច្នេះខ្ញុំត្រូវតែបានការអនុញ្ញាត។

[១០:៤២:៤០]

**លោក វិ៉ចទ័រ កូប៉េ៖**

អ៊ីចឹងគឺថាសហព្រះរាជអាជ្ញា បានលើកឡើង<ដោយភាន់ច្រឡំ>ពីចំណុចរបស់ខ្ញុំ<ហើយ។> <>តើលោកអាចនិយាយ<បាន>ទេ <ពីភស្តុតាងពិត ក្រៅពី>អ្វី<ដែល>ជា<>ឯកសារឃោសនារបស់វៀតណាមហ្នឹង ការវាយប្រហារនៅថ្ងៃទី៣០ ខែមេសា ៧៧ ហ្នឹង <ពិតជាបានកើតឡើងទេ>?

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

<ពិតណាស់ ភស្តុតាងគឺមាននៅក្នុងសំណុំរឿង។> គឺ<វាជាសម្រង់>ដែលខ្ញុំបានអាន<>ចេញពីអ្នកជំនាញ គឺជាអ្នកជំនាញដែលមេធាវីការពារក្តី នួន ជា បាន<ស្នើសុំឲ្យ>កោះអញ្ជើញ<គាត់មកផ្តល់សក្ខីកម្ម>។

**លោក វិ៉ចទ័រ កូប៉េ៖**

សូមអភ័យទោស នេះជាបញ្ហាដដែល ដែលយើងប្រឈមមុខ ពេលដែលយើងបានតទល់ជាមួយ ចាន់ដា<នៅពេលគាត់និយាយអំពី>កិច្ចប្រជុំមជ្ឈិមបក្សរបស់វៀតណាម<នៅពាក់កណ្តាលខែកុម្ភៈ។> នៅពេលនោះ<គេបាន>បដិសេធ<យើងចោល ហើយសួរថា "តើ> ចាន់ដា បានទទួលប្រភពនោះមកពីណា? <តើអ្វីជាប្រភពរបស់ ចាន់ដា?" ហើយពេលនេះ <លោក>យោងទៅរកតែ ណាយ៉ាន់ ចាន់ដា <ហើយអង្គជំនុំជម្រះមើលទៅដូចជាអនុញ្ញាតឲ្យលោកសួរសំណួរបែបនេះ>។

[១០:៤៣:៤០]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្ដីជំទាស់របស់មេធាវីការពារក្ដី លោក វ៉ិចទ័រ កូប៉េ សំណួរនេះអាចសួរបាន អង្គជំនុំជម្រះត្រូវការស្ដាប់ ហើយអង្គជំនុំជម្រះនឹងវាយតម្លៃលើភស្ដុតាងទាំងនេះរួមគ្នាជាមួយនឹងភស្ដុតាងដទៃទៀត។

សាក្សីឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញារងអន្តរជាតិអម្បាញ់មិញនេះ បើសិនបើលោកនៅចាំសំណួរ។

**លោក អៀង ផាន៖**

**ឆ៖** ខ្ញុំមានយោបល់ទាក់ទងនឹងរបាយការណ៍ដែលបានមកពីខាងវៀតណាមអម្បាញ់មិញ។ ខ្ញុំជឿជាក់ថារបាយការណ៍នេះ ខ្ញុំយល់ឃើញថាដូចជាមិនពិតប្រាដក ពីព្រោះខ្ញុំនៅកន្លែងជាក់ស្ដែង គឺខាងខ្ញុំមិនមានសិទ្ធិវ៉ៃចូលដល់អានយ៉ាងអីមិនមានទេ ខាងៗទ័ពនិរតីហ្នឹង ពិសេសវរសេនាធំខ្ញុំហ្នឹង គឺមិនមានសិទ្ធិវាយចូលជ្រៅម្ល៉ឹងៗ អត់ទេ។ អ៊ីចឹងរបាយការណ៍នេះ ខ្ញុំមិនយល់ថាយ៉ាងម៉េចទេ អាហ្នឹងសូមលោកប្រធានពិនិត្យឡើងវិញចុះ ប៉ុន្តែជាក់ស្ដែងគឺថា មិនមានសិទ្ធិវ៉ៃចូលដល់ជ្រៅម្ល៉ឹងទេ បានតែត្រឹមកៀកៗព្រំដែនទេ បាទសូម--។

[១០:៤៥:០៧]

**សួរដោយលោក ចូសេហ្វ អេនត្រូ ប៊ិយលី៖**

**ស៖** សូមអរគុណលោកសាក្សី។ នៅពេលដែលលោកនៅខេត្តតាកែវ ដែលធ្វើការវាយប្រហារប្រឆាំងវៀតណាម តើ<គេ>មាន<ដែលជូនដំណឹងលោកអំពី>ការចរចា<ថ្នាក់លើ>រវាង<រដ្ឋាភិបាលខ្មែរក្រហម> បក្សកុម្មុយនីស្ដកម្ពុជា ហើយនិងរដ្ឋាភិបាលរបស់វៀតណាមដែរឬទេ?

**ឆ៖** ចំណុចនេះខ្ញុំក្ដាប់អត់បានទេបាទ។ ខ្ញុំយល់តែ ខ្ញុំធ្វើយ៉ាងណាខ្ញុំនិយាយប៉ុណ្ណឹង ឯការចរចាយ៉ាងណានោះ ថ្នាក់លើខ្ញុំក្ដាប់មិនបានទេ។

**ស៖** ខ្ញុំនឹងអានជូនលោកនៅឯកសារនៅក្នុងសំណុំរឿង គឺឯកសារប្រកាសព័ត៌មានរបស់វៀតណាមនៅអង្គការសហប្រជាជាតិនៅញូវយ៉កគឺ E3/5883 គឺថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ អង់គ្លេស ERN 00419879, ខ្មែរ 00656204 ដល់ 05, បារាំង 00819087 ខ្ញុំឱ្យភាសាខ្មែរហ្នឹងគឺថា បាទគឺ <65624>*(ស៊ីក)* ដល់<25> បាទដកស្រង់៖ “នៅ<ថ្ងៃទី៧> ខែមិថុនា ឆ្នាំ១៩៧៧ គណៈ<មជ្ឈិម>

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បក្សកុម្មុយនីស្តវៀតណាម <និងរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម> បានបញ្ជូនលិខិតមួយទៅគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា <និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ> ហើយស្នើសុំឲ្យមានការប្រជុំឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន រវាងមេដឹកនាំថ្នាក់ខ្ពស់ រវាងភាគីទាំងពីរ រដ្ឋាភិបាលទាំងពីរដើម្បីដោះស្រាយបញ្ហាព្រំដែនរវាងភាគី<ទាំងពីរ។> នៅ<ក្នុង>លិខិតឆ្លើយតបមកវិញគឺថានៅ<ថ្ងៃទី១៨> ខែមិថុនា ឆ្នាំ១៩៧៧ <គណៈមជ្ឈិមបក្ស និងរដ្ឋាភិបាល>កម្ពុជាប្រជាធិបតេយ្យបានចាត់ទុកថា ការប្រជុំនេះសំខាន់ ប៉ុន្តែស្នើសុំឲ្យធ្វើការប្រជុំបន្ទាប់ពីរយៈកាលពេលវេលារហូតតែស្ថានការណ៍ហ្នឹង គឺមកជាធម្មតាវិញ ដោយគ្មានជម្លោះព្រំដែន ប៉ុន្តែជាក់លាក់នោះគឺថាកម្ពុជាបង្កើនការវាយប្រហារយោធាគឺបានវាយជ្រៀតចូលទៅព្រំដែនវៀតណាម ហើយក៏បានសម្លាប់ជនស៊ីវិលវៀតណាម ហើយនិងធ្វើវិទ្ធង្សនា<មកលើការប្រកបការងារដោយសុខក្សេមក្សាន្តរបស់ប្រជាជន>វៀតណាមនៅ<តាមបណ្តាលខេត្តជាប់ព្រំដែន ជាពិសេស គឺខេត្ត>គៀនយ៉ាង អានយ៉ាង <ដុងថាប់> ឡុងអានហើយនិងតៃនិញ។" បញ្ចប់សេចក្តីដកស្រង់។ នេះជាសេចក្តីប្រកាសព័ត៌មានរៀបរាប់ពីការវាយប្រហារដែលបានកើតឡើងនៅក្នុងខែមិថុនា ឆ្នាំ១៩៧៧ តើលោកបានដឹងថាតើមានជម្លោះប្រដាប់អាវុធស្អីនៅរវាងខែមិថុនា ឆ្នាំ១៩៧៧ ដែរឬទេ?

[១០:៤៨:៣១]

**ឆ៖** ខ្ញុំបានជម្រាបរួចស្រេចមកហើយថា ចាប់ពីដើមឆ្នាំ៧២ ពាក់កណ្តាលឆ្នាំ៧៧ ហ្នឹងគឺថាមានការប្រយុទ្ធបន្តបន្ទាប់មកហើយ រវាងកម្ពុជា-វៀតណាម។ ខ្ញុំបានបញ្ជាក់ពីខាងដើមមកហើយ។

**ស៖** គឺការពិតហើយលោកសាក្សី។ តើសេចក្តីដកស្រង់នេះធ្វើឲ្យលោកនឹកឃើញថា មាន<> ការចរចាអ្វី <បានធ្វើឡើងនៅក្នុងពេលជាមួយគ្នានៃការវាយប្រហារដែរឬទេ>?

**ឆ៖** ខ្ញុំសូមជម្រាបថា ខ្ញុំក្តាប់មិនបានបាទ ខ្ញុំមិនប៉ានថាបាទ។

**ស៖** ខ្ញុំយល់។ តើលោកធ្លាប់ទទួលការណែនាំណាមួយ ពាក់ព័ន្ធទៅនឹងថា កម្មាភិបាលខ្មែរក្រហមបានចូលទៅៗទឹកដីវៀតណាមដើម្បីចាប់ ហើយចាប់ពួកខ្មែរក្រោមយកមកកម្ពុជាប្រជាធិបតេយ្យវិញ?

**ឆ៖** ខ្ញុំជម្រាបច្បាស់លាស់ថា រឿងដែលថាទៅយកកម្ពុជាក្រោមវិញ គឺថាខ្ញុំក្តាប់មិនបានទេបាទ ខ្ញុំដឹងតែភារកិច្ចរបស់ខ្ញុំខាងលើណែនាំ គឺការពារបូរណភាពដែនដីដែលមានស្រាប់ ឯទៅយក អត់មានដែលណែនាំទេ បាទសូមជម្រាប។

**ស៖** ប្រហែលជាសំណួររបស់ខ្ញុំមិនច្បាស់។ ខ្ញុំមិននឹងនិយាយអំពីទៅយកទឹកដីខ្មែរកម្ពុជាក្រោមទេ ចង់និយាយថាៗពួកប្រជាជនខ្មែរក្រោមដែលនៅក្នុងទឹកដីវៀតណាម។ តើលោកធ្លាប់ទទួលការណែនាំណាមួយដែរឬទេថាឲ្យវាយចូល ឬក៏ចូលទៅដែនដីនោះ ហើយចាប់ប្រជាជនខ្មែរក្រោមយកមកកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** គឺមិនដែលទេ ខ្ញុំសូមជម្រាបថាអត់ដែលទេបាទ។

[១០:៥១:០០]

**ស៖** ខ្ញុំយោងទៅរកព័ត៌មាននៅក្នុងសំណុំរឿង ហើយខ្ញុំសេចក្ដីដកស្រង់ គឺថានៅក្នុងសៀវភៅប៉ែន យៀវនិន គឺE3/1593, អង់គ្លេស 01150219, បារាំង 00639212, ខ្មែរ 00637997។ នេះជាអ្វីដែលគាត់និយាយ សូមដកស្រង់៖ "នៅឆ្នាំ១៩៧៨ <ការឆ្មក់ចូលលុករបស់កម្ពុជាប្រជាធិបតេយ្យដែលចេញ>មកពីភូមិភាគនិរតីបានចាប់ខ្មែរក្រោមបានរាប់ពាន់<ពីភូមិរបស់គេនៅក្នុងប្រទេសវៀតណាម។> នៅក្នុងយុទ្ធនាការពីរសប្ដាហ៍ <ក្នុងខែមីនា> ឆ្នាំ១៩៧៨ <គឺកងពលធំមួយរបស់>កម្ពុជាប្រជាធិប-តេយ្យ បានកាន់កាប់<ស្រុកបៃនូយ នៅក្នុងខេត្ត>អានយ៉ាង<>"។ តើលោកនៅចាំទេនៅក្នុងឆ្នាំ<១៩៧៨ កងកម្លាំង>ខ្មែរក្រហមបានចូលទៅ<> ហើយក៏បានយកខ្មែរក្រោមមក ត្រឡប់មកកម្ពុជាវិញ?

**ឆ៖** ខ្ញុំបានជម្រាបហើយថា ការដែលកងទ័ពកម្ពុជាទៅវ៉ៃកាន់កាប់ភូមិវៀតណាមអីមិនមានទេ ចូលទៅអត់បានមួយម៉ោង ឬមួយម៉ោងកន្លះទេ ហើយបើទៅមុខព្រួញមួយហ្នឹង គឺត្រូវបកមកវិញភ្លាមហើយ ព្រោះវៀតណាមកាត់មកភ្លាមៗហ្នុង អត់មានទៅកាន់កាប់ភូមិបានទេ សូមជម្រាបអ៊ីចឹង។ ខ្ញុំអនុវត្តជាក់ស្ដែងនៅហ្នឹង គឺអត់មានទៅកាន់កាប់ភូមិបានទេ។

**ស៖** នៅពេលដែលលោកមានមូលដ្ឋាននៅខេត្តតាកែវ ថាតើលោកទទួលបទបញ្ជានៅតាមរបៀបណា ដែលថាបញ្ជាឲ្យពេលណាធ្វើការវាយប្រហារ? <វាយប្រហារដោយរបៀបណា?> វាយប្រហារនៅកន្លែងណាជាដើម?

[១០:៥៣:០៤]

**ឆ៖** ខ្ញុំសូមជម្រាបថាបទបញ្ជាប្រយុទ្ធនេះ លុះត្រាតែវៀតណាមចូល បើថាបទបញ្ជាឲ្យកងទ័ពកម្ពុជារុលចូលទៅទឹកដីវៀតណាមនោះកម្រមានណាស់ មិនមានហ្នុង។ ដល់វៀតណាមវ៉ៃចូលមកបានមានបទបញ្ជាទប់ទល់ ហើយវ៉ៃបកតែប៉ុណ្ណឹងទេ។ អាហ្នឹងខ្ញុំអនុវត្តជាក់ស្ដែងនៅតាមព្រំដែនឃើញអ៊ីចឹង

ពីព្រោះកងទ័ពកម្ពុជាចំនួនប៉ុន្មាន ហើយទៅវៃយកចូលទឹកដីវៀតណាម កម្រណាស់ ចូលបានមួយ ភ្លែតៗទេ ដូចខ្ញុំជម្រាបអ៊ីចឹង បើថាចូលយូរអត់បានទេ អស់រលីង។ បាទសូមជម្រាបប៉ុណ្ណឹង។

**ស៖** សំណួររបស់ខ្ញុំឃើញថាចូលទៅដល់ប្រធានបទផ្សេងបន្តិច។ ខ្ញុំបានសួរលោកគឺថា ដោយ គិតថាលោកបានទទួលបទបញ្ជា ថាតើពី សំ ប៊ិត ថាឲ្យធ្វើការវាយប្រហារ<ដោយរបៀបណា> នៅ កន្លែងណា តើអ៊ីចឹងនៅពេលដែលលោកនៅតាកែវ លោកទទួលបទបញ្ជា<យោធា>ពី សំ ប៊ិត តើអ៊ីចឹង ឬទេ?

**ឆ៖** បាទ អ៊ីចឹង ពីព្រោះ សំ ប៊ិត គាត់ប្រធានកងពលពេលនោះ។

**ស៖** ថាតើគាត់<>ផ្តល់បទបញ្ជា<ទាំងអស់នោះទៅលោក ដោយរបៀបណា?> តាមវិធីអ្វី <ចូលរួមប្រជុំ> ជានីរសារបញ្ជូនមក ជាសំបុត្រ ឬក៏តាមសារទូរលេខ ?

**ឆ៖** ខ្ញុំយល់ឃើញថាបទបញ្ជាពីកងពលណែនាំដល់យើងខ្ញុំគ្រប់គ្នានៅតាមព្រំដែននេះគឺ សំខាន់ គឺការពារបូរណភាពដែនដីឲ្យបានគង់វង្ស សំខាន់ណាស់ហ្នឹង។ រៀបចំកម្លាំងការពារបូរណភាពដែនដី ហើយតាមសារទូរលេខផង តាមការប្រជុំផង ពេលដែលមកប្រជុំ។ សូមបញ្ជាក់អ៊ីចឹង។

**ស៖** តើលោកធ្លាប់ចូលរួមប្រជុំនៅក្នុងពេលដែល តាម៉ុក ជាអ្នកធ្វើបទឧទ្ទេសនាម ហើយនិង ចេញបញ្ជាណែនាំ <នៅក្នុងភូមិភាគនិរតី>ដែរឬទេ?

[១០:៥៥:៤០]

**ឆ៖** ខ្ញុំសូមជម្រាបថា ក្នុងឋានៈខ្ញុំពេលនោះគឺប្រធានវរសេនាធំ ខ្ញុំបានចូលរួមប្រជុំជាមួយ តាម៉ុក ជាមួយ តាប៊ិត នៅតាកែវហ្នឹង បានចូលរួមប្រជុំ។ ហើយប្រជុំសំខាន់ ទិសដៅសំខាន់ គឺការពារ បូរណភាពដែនដីតែម្តង មិនដែលលើកបញ្ហាថាទៅវៃអ្នកនេះទៅវៃអ្នកនោះ បើលាក់ការណ៍យ៉ាងណា ប៉ុន្តែខ្ញុំប្រជុំ គឺថាធ្វើម៉េចការពារឲ្យបាន រង្វង់ដែលខ្ញុំទទួលខុសត្រូវប៉ុន្មានគីឡូម៉ែត្រកុំឲ្យបាត់បង់ ណែនាំ សង្កត់តែប៉ុណ្ណឹង បញ្ហាហ្នឹង។

**ស៖** នៅពេលដែល តាម៉ុក ដែលនិយាយក្នុងអង្គប្រជុំ ឬក៏បញ្ជាក់ពីការណែនាំ តើគាត់ធ្លាប់ <លើកឡើងនិយាយពី នួន ជា ថាអ្វីទាំងអស់នេះគឺ> នួន ជា <ជាអ្នកនិយាយដែរឬទេ>?

**ឆ៖** ខ្ញុំសូមជម្រាបថា ចំពោះ តាម៉ុក គាត់អត់ដែលនិយាយថ្នាក់លើ យកពាក្យថ្នាក់លើមក និយាយទេ តាម៉ុក ពីព្រោះគាត់តែងតែយកពាក្យផ្ទាល់ខ្លួនគាត់ណែនាំ ដាក់ម៉ាច់ៗតែម្តង អត់មានបង្អង់ មាត់ទេបាទ អាហ្នឹងសូមជម្រាបអ៊ីចឹង។ ហើយណែនាំភាគច្រើនដូចខ្ញុំបញ្ជាក់អ៊ីចឹង ខ្ញុំនៅក្រោមឱវាទ

ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

នេះគឺថា ឲ្យធ្វើម៉េចឲ្យការពារបូរណភាពដែនដីឲ្យបាន។ ហើយសម្រាប់កងទ័ពយើងខ្ញុំកម្រអ្នកបានមក ផ្ទះណាស់ ខ្ញុំសូមជម្រាបអ៊ីចឹង នៅត្រាំត្រែងនៅហ្នឹង។ បាទ សូមអស់។

[១០:៥៧:២២]

**ស៖** ខ្ញុំនឹងអានជូនលោក នៅពេលដែលលោកមកធ្វើសក្ខីកម្ម<លើកមុន>នៅទីនេះគឺនៅម៉ោង ១៤:៣៥:២៥វិនាទី "សំណួរសួរថា៖ តើលោកធ្លាប់ជួប នួន ជា ជាបុគ្គលទេ? ឆ្លើយ៖ នៅពេលនោះ ខ្ញុំមិនដែលជួបគាត់ទេ ខ្ញុំមិនដែលជួបថ្នាក់លើណាម្នាក់ទេ ខ្ញុំគ្រាន់តែឮឈ្មោះពួកគាត់តាមរយៈការណែនាំរបស់ តាម៉ុក។ ខ្ញុំមិនដែលជួបពួកគាត់រហូតទាល់តែថ្ងៃនេះ"។ តើនេះជាចម្លើយត្រឹមត្រូវរបស់លោកដែរ ឬទេនៅពេលដែលលោកយោងទៅរកការប្រជុំទាំងនោះនៅក្នុងភូមិភាគនិរតី ហើយលោកបានឮឈ្មោះថ្នាក់ដឹកនាំទាំងនោះ?

**ឆ៖** ខ្ញុំសូមជម្រាបអង្គជំនុំជម្រះថាកម្ពុជាប្រជាធិបតេយ្យដែលនិយមប្រើពាក្យថា "ខ្មែរក្រហម" នោះ សំខាន់សម័យនោះគឺថា គេប្រើពាក្យ "លាក់ការណ៍ដឹកនាំ" អ្នកណាទទួលខុសត្រូវអី អ្នកនោះដឹង។ អ៊ីចឹងសម្រាប់ខ្ញុំថ្នាក់តូច ដឹងរឿងថ្នាក់លើ គឺថាកម្របានណាស់ កម្រមានណាស់។ ខ្ញុំដឹងតែត្រឹមភូមិភាគហ្នឹងដល់ទៅលើទៀត ខ្ញុំអត់ដឹងទេ បាទអត់ដឹងទេ។ មិនដឹងថ្នាក់លើហ្នឹងអី ឮតែឈ្មោះអ៊ីចឹង ឮតែឈ្មោះបោះសំឡេងអ៊ីចឹង ប៉ុន្តែអត់បានជួបណែនាំផ្ទាល់អីទេ មិនដូចដែលភូមិភាគកងពលធំអីទេបាទ។ អានេះសូមជម្រាបអ៊ីចឹង។

[១០:៥៩:០០]

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលទៅដល់ពេលវេលាដែលលោកប្រចាំការ ធ្វើការនៅខេត្តស្វាយរៀង ដែលលោកបានបញ្ជាក់ខាងដើមថា គេបញ្ជូនកងលោកទៅទីនោះនៅក្នុងពាក់កណ្ដាលឆ្នាំ១៩៧៨ បន្ទាប់ពីការរៀបចំនៅក្នុងចុងឆ្នាំ១៩៧៧។ នៅពេលដែលលោកទៅដល់ខេត្តស្វាយរៀង តើកងវរសនាធំលេខ ១២របស់លោកទាំងស្រុងហ្នឹងបានទៅជាមួយលោកក្នុងពេលជាមួយគ្នាហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំបានជម្រាបសខាងដើមហើយថា ពេលរៀបចំកម្លាំងទៅស្វាយរៀងនេះ ខ្ញុំអត់នៅគ្រប់គ្រងវរសេនាធំលេខ១២ទៀតទេ។ បានន័យថា ថ្នាក់លើជ្រើសរើសពីវរៈ -- ពីកងពល២១០នុ៎ង មួយវរសេនាធំ, ២៥០ហ្នឹង មួយវរសេនាធំ, ២៣០ មួយវរសេនាធំ, ២៧០ មួយវរសេនាធំ បានបួនវរសេនាធំ។ ហើយរៀបទៅជាកងពលតូច២២១។ ហើយខ្ញុំជាអ្នកដឹកនាំ ប្រធានរួម ប្រធានកងពល អត់មានវរសេនាធំ១២ ទៅស្វាយរៀងទៀតទេ បាទ។

**ស៖** <នេះគឺជាអង្គភាពថ្មីដែលលោកទទួលខុសត្រូវ> តើមានកងទ័ពសរុបទាំងអស់ហ្នឹងចំនួនប៉ុន្មាននាក់ <ដែលលោកយកទៅជាមួយ> យកពីនិរតីទៅស្វាយរៀងនុ៎ង?

**ឆ៖** ចំនួន១.៨០០ បួនវរសេនាធំ។

[១១:០១:១០]

**ស៖** ខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់។ លោកចង់ថា មួយវរសេនាធំហ្នឹង គឺមាន<កងទ័ព លើស ១.០០០ បន្តិចបន្តួច> ឬក៏ថា សរុបទាំង<អស់ហ្នឹង មានចំនួន ១.០០០ នាក់>?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា មិនមែនមួយវរសេនាធំមួយ ១.៨០០ទេ។ ដែលខ្ញុំនិយាយអម្បាញ់មិញ គឺដកពីកងពល២១០ មួយវរសេនាធំ, ២៣០ មួយវរសេនាធំ, ២៥០ មួយវរសេនាធំ, ២៧០ មួយវរសេនាធំ វាទៅជាបួនវរសេនាធំ គិតជាកម្លាំងរួម ១.៨០០នាក់ បួនវរសេនាធំ។

**ស៖** បាទ សូមអរគុណ ខ្ញុំយល់ហើយ។ ពេលដែលលោកមកផ្តល់សក្ខីកម្មនៅមុននោះ លោកបានជម្រាបជូនតុលាការថា លោកបានចូលរួមអង្គប្រជុំមួយ ដែល តាម៉ុក ជាអ្នកដឹកនាំអង្គប្រជុំនៅចុងឆ្នាំ៧៧ ពាក់ព័ន្ធទៅនឹងការណែនាំក្រោមការរៀបចំកម្លាំងទៅស្វាយរៀង។ ខ្ញុំសួរសំណួរមួយដើម្បីបញ្ជាក់ពីសក្ខីកម្មដែលលោកបានឆ្លើយនៅពេលនោះ គឺសម្រង់ចេញពីប្រតិចារឹក E1/193.1 នៅម៉ោង <១១:៣៥:០៤វិនាទី> នេះគឺអ្វីដែលលោកបានផ្តល់សក្ខីកម្ម សូមដកស្រង់៖ “ខ្ញុំបានចូលរួមប្រជុំនៅផ្ទះតាម៉ុក ជាមួយនឹងសមមិត្ត សំ ប៊ិត។ អង្គប្រជុំនេះ រៀបចំធ្វើឡើងនៅចុងឆ្នាំ៧៧។ នៅពេលនោះ ខ្មែរក្រហមកំពុងប្រយុទ្ធគ្នាជាមួយនឹងវៀតណាមរួចទៅហើយ។ ដូច្នេះកងទ័ពខាងភូមិភាគនិរតីហ្នឹង បានបញ្ជូនទៅស្វាយរៀង ទៅភូមិភាគបូព៌ា<មុន>ខ្ញុំ<ទៅទៀត>។ ហើយអង្គប្រជុំហ្នឹង គឺមានបំណងដើម្បីរៀបចំកងកម្លាំងបញ្ជូន<>កងវរសេនាធំរបស់ខ្ញុំ <ទៅភូមិភាគបូព៌ា>។” បញ្ចប់ការដកស្រង់។

ត្រង់ចំណុចនេះ <លោកហាក់បីដូចជា>បញ្ជាក់ថា <មាន>កម្លាំងពីនិរតីបញ្ជូនទៅស្វាយរៀងខ្លះរួចទៅហើយ មុននឹងលោកទៅដល់ស្វាយរៀង <ឬក៏បញ្ជូនទៅមុនកិច្ចប្រជុំ ដែលធ្វើឡើងនៅពាក់-កណ្តាល -- សូមទោស គឺនៅចុង>ឆ្នាំ៧៧ហ្នឹង។ តើត្រឹមត្រូវដែរឬទេ ដែលថា កងទ័ពហ្នឹងត្រូវបានបញ្ជូនទៅភូមិភាគបូព៌ាហ្នឹង មុនលោកទៅដល់ទៅទៀត?

[១១:០៣:៥០]

**ឆ៖** ខ្ញុំសូមជម្រាបថា ក្នុងការសម្ភាសរបស់ខ្ញុំនៅបាត់ដំបងហ្នឹង ខ្ញុំបញ្ជាក់ថា មុននឹងខ្ញុំទៅស្វាយរៀងនេះ គឺមានកម្លាំងទៅមុនខ្ញុំមួយវគ្គហើយ ទៅមុនខ្ញុំមួយវគ្គទៀត។ ឯខ្ញុំនេះ ទៅវគ្គទី២ទេ ទៅ

វគ្គទី២ ចុងកន្ទុយក្រោយ៧៨នេះហើយទេ។ ហ្នឹងសូមជម្រាបអ៊ីចឹង។ វគ្គមុននោះ គេទៅមុនបាត់ ដែលខ្ញុំក្នុងឯកសារខ្ញុំថា ដាក់ដឹកនាំដោយលោក វ៉ែន ទៅមុនហ្នឹង ទៅពីភូមិភាគនិរតីដែរ បាទ។

**ស៖** តើកងនេះ បានទៅ<បូព៌ា>នៅពេលណា? ហើយនៅពេលហ្នឹង គឺថាកងទ័ពហ្នឹង ទៅជាមួយ វ៉ែន ហ្នឹង ចំនួនប៉ុន្មាននាក់ដែរ?

**ឆ៖** ខ្ញុំសូមជម្រាបថា ទៅជាមួយនឹង វ៉ែន ហ្នឹង ខ្ញុំក្ដាប់កម្លាំងអត់បានទេ ពីព្រោះខ្ញុំអត់បានចូលរួមប្រជុំទេ។ ខ្ញុំក្ដាប់បានតែពេលដែលប្រជុំជាមួយ តាម៉ុក ហើយរៀបចំកម្លាំងឲ្យខ្ញុំ ប្អូនវរសេនាធំទេដែលខ្ញុំក្ដាប់បាន។ ឯទៅជាមួយ វ៉ែន នោះគឺគេអត់ហៅខ្ញុំមកប្រជុំទេ។ បាទ សុំជម្រាប បាទ។

**ស៖** តើលោកដឹងទេ<តើពួកគេទៅភូមិភាគបូព៌ានៅពេលណា? តើ>វ៉ែន <>ទៅស្វាយរៀងនៅពេលណាដែរ?

**ឆ៖** គាត់ទៅតាំងពីឆ្នាំ ដើមឆ្នាំ៧៧។

**ស៖** អង្គភាពដែលលោកគ្រប់គ្រងនេះ នៅពេលដែលលោកទៅដល់ស្វាយរៀង តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ អង្គភាពដែលលោកក្ដោបក្ដាប់ហ្នឹងណ៎ា ហៅថាអង្គភាពអ្វីដែរ លេខប៉ុន្មានដែរ?

**ឆ៖** អង្គភាពដែលខ្ញុំគ្រប់គ្រងហ្នឹង លេខកងពលតូច២២១ អន្តរាគមន៍។

[១១:០៦:២៨]

**ស៖** ហើយកងពលតូចអន្តរាគមន៍លេខ២២១នេះ តើអ្នកណាជាអនុមេបញ្ជាការរបស់លោក?

**ឆ៖** អនុបញ្ជាការឈ្មោះ ឈាង ប៉ុន្តែគាត់ស្លាប់ហើយ បាទ។ គាត់ស្លាប់តាំង៧៩ហ្នឹងនោះ។

**ស៖** នៅពេលដែលលោកនិយាយថា <ឈៀន> ហ្នឹងឈ្មោះ សុខ <ឈៀន> ហ្នឹងមិន ឬក៏មិនមែនទេ?

**ឆ៖** សុខ ឈៀន ហ្នឹងមួយ ពីព្រោះវងមានពីរ សុខ ឈៀន ហ្នឹងមួយ ឈាង នោះមួយទៀត។ សុខ ឈៀន ហ្នឹងក៏ត្រូវដែរ អនុប្រធានដែរ ។

**ស៖** នៅពេលដែលលោកផ្ដល់សក្ខីកម្មកាលពីលើកមុននោះ ក៏ដូចជាថ្ងៃនេះ លោកថា រួមទាំងកងពលអន្តរាគមន៍លេខ២២១នោះ គឺថាមានទាំងអស់ មានរហូតទៅដល់ប្រាំ<កងពលតូច>ឯណោះ <ដើម្បីបង្កើតបានជាកងពលធំមួយនៅស្វាយរៀង>។ តើកងពល<ធំនោះមានលេខ> មានឈ្មោះអ្វីដែរ?

**ផ៖** លោកប្រធានចង់សួរថាម៉េច?

**ស៖** លោកបានឆ្លើយថា លោកគឺថាជាអ្នកបញ្ជាកងពលតូចអន្តរាគមន៍។ ហើយលោកមុននោះ លោកបានផ្ដល់សក្ខីកម្មថា នៅថ្ងៃទី ម៉ោង<១៣:៤១:២០វិនាទី> សុំដកស្រង់៖ “នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ មានប្រាំ<កងពលតូច>ដែលបង្កើតបានជាកងពល<ធំមួយ ហើយរួមបញ្ចូលទាំង> កងពលតូចអន្តរាគមន៍<មួយផង>”។ អ៊ីចឹងហើយបានខ្ញុំៗឆ្ងល់ថា <តើកងពលធំនេះ ដែលកងអន្តរាគមន៍របស់លោកនៅក្នុងនោះដែរនោះ តើវាមានឈ្មោះ ឬក៏មានលេខសម្គាល់ទេ>នៅពេលដែលមានទីតាំងនៅស្វាយរៀងនោះ<>?

**ប្រធានអង្គជំនុំ៖**

ប្រាំកងពលតូចឯណាទៀត ឡប់អស់ហើយ។ អានេះកងពលតូច២២១អន្តរាគមន៍។ វាមានបួន ឬក៏ប្រាំអង្គវរសេនាតូចដែលចំណុះកងពលតូច។ អ៊ីចឹងអង្គភាពតូចៗផ្សេងទៀតគឺជាចំណុះទេ។ ចំណុះឲ្យកងពលតូចអន្តរាគមន៍២២១។ ហើយទៅសួរទៅ សួរ សាក្សីសួរទៅ បែបវាមិនយល់ទេ ពីព្រោះអង្គ-ភាពតូច ទៅឲ្យធំជាង។ ទៅអាធំជាងចំណុះឲ្យអាតូចយ៉ាងម៉េច។ វាដូចជាមិនយល់ទេ។ សុំៗរៀបចំសំណួរឡើងវិញ ហើយអ្នកបកប្រែ បក -- ស្ដាប់ឲ្យយល់ពីបញ្ហានេះ យល់ផង ហើយនិយាយប្រើភាសាឲ្យចំ ខំស្ដាប់អត់បានទេ។

**សួរដោយលោក ចូសេហ្វ អេនទ្រូ ប៉ិយលី៖**

**ស៖** ខ្ញុំគិតថានេះជាកំហុសរបស់ខ្ញុំហើយ។ ឥឡូវខ្ញុំសុំបញ្ជាក់ម្ដងទៀត។ លោកសាក្សីនៅពេលដែលលោកផ្ដល់សក្ខីកម្មពីលើកមុននេះ លោកនិយាយថា នៅពេលដែលលោកក្លាយទៅជាមេបញ្ជាការកងពលអន្តរាគមន៍២២១ហ្នឹង គឺមាន<កងពលតូច>បួន<>ផ្សេងទៀត ដើម្បីមកបង្កើតបានជាកងពល<ធំ>មួយនេះ<នៅស្វាយរៀង។ សូមដកស្រង់ លោកនិយាយនៅម៉ោង ១៣:៣៩:៤១ វិនាទី៖ “ក្រោយមកទៀត វាត្រូវបានគេពង្រីកទៅជា>កងពលតូច<ចំនួនបួន ហើយ>នៅស្វាយរៀងនោះ គឺមាន<>កងពលតូច<ចំនួនប្រាំ ដែលបង្កើតបានជាកងពលធំមួយ។” អ្វីដែលខ្ញុំព្យាយាមចង់បញ្ជាក់នោះគឺ តើកងពលធំនោះ ដែលមាន>ប្រាំកងពលតូចនេះ <តើ>កងពលធំ<នេះ មានលេខសម្គាល់ ឬក៏ឈ្មោះ>ស្អីដែរ ឬទេ <នៅពេលវាមានមូលដ្ឋាននៅស្វាយរៀង>?

[១១:១០:៤០]

**លោក អៀង ផាន៖**

**ឆ៖** ខ្ញុំយល់សំណួរបាទ ព្រោះសួរអម្បាញ់មិញ សូមអធ្យាស្រ័យថា ទាក់ទិននឹងវរៈកងពលផង វរសេនាធំផង។ បើសួរខ្ញុំថានៅស្វាយរៀងក្រោយពីខ្ញុំទៅដល់នេះ គឺមានប្រាំកងពលតូច អាហ្នឹងងាយបំភ្លឺបំផុតហើយ។ គឺថានៅស្វាយរៀង ក្រោយខ្ញុំទៅដល់ហ្នឹង គេរៀបទៅជាប្រាំកងពល បាទប្រាំកងពលខ្ញុំសូមជម្រាបអ៊ីចឹង ហើយទៅជាកងពលធំ។ កងពលធំហ្នឹងដឹកនាំដោយលោក រ៉ែន ដែលខ្ញុំជម្រាបថាទៅមុនខ្ញុំនោះ។ ហើយមានកងពលអន្តរាគមន៍២២១ហ្នឹង មួយកងពល, កងពល៤៦០ មួយកងពល, កងពល៧០៣ មួយកងពល, កងពល៨០៥ មួយកងពល។ ទាំងអស់ប្រាំកងពល ក្នុងឯកសារដែលខ្ញុំបំភ្លឺសម្ភាសមុន គឺខ្ញុំបានជម្រាបហើយ។

**ស៖** លោកទើបតែលើកឡើងថា កងពលតូចដទៃទៀតហ្នឹង គឺជាចំណុះឲ្យកងពលធំមួយហ្នឹង <ខ្ញុំនឹងសួរសំណួរលោកមួយចំនួន ថាតើនរណាជាអ្នកគ្រប់គ្រងកងពលតូចទាំងអស់នោះ។ ប៉ុន្តែដំបូងខ្ញុំសូមសួរលោកថា> បន្ថែមទៅលើកងពលតូចទាំងប្រាំ <ដែលលោកបានលើកឡើង> តើមានកងរថក្រោះ <និង>កាំភ្លើងធំ<មួយដាច់ដោយឡែកនៅ>អមជាមួយនឹងកងពល<ធំរបស់លោក នៅស្វាយរៀង ដែរឬទេ>?

[១១:១២:៣០]

**ឆ៖** ខ្ញុំសូមជម្រាបថា កងពលធំរួម ដឹកនាំរួមគឺលោក រ៉ែន ហើយមានកងពលតូចប្រាំទៀត ក្នុងហ្នឹងកងពល២២១ ខ្ញុំបាទហើយ, កងពល៤៦០ ប្រធានឈ្មោះលោក ផន ស្លាប់ហើយ, កងពល៧០៣ ឈ្មោះលោក ឌី ស្លាប់ដែរ, កងពល៨៨៥ ឈ្មោះលោក ផន ក៏ស្លាប់ដែរ។

**ស៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**អ្នកបកប្រែ៖**

បាទ សហព្រះរាជអាជ្ញាអត់បានបើកក្បាលមីក្រូទេ ស្តាប់អត់ឮទេ។

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** ខ្ញុំសូមអានសម្រង់មួយពីកំណត់ហេតុស្តាប់ចម្លើយ E3/4593។ នេះជាកំណត់ហេតុស្តាប់ចម្លើយរបស់ ជួន ធី នៅត្រង់ចម្លើយលេខ១៥ គាត់និយាយអំពីអង្គភាពមួយ ដែលលោកបានលើកយកមកនិយាយ ហើយសូមដកស្រង់៖ “ក្រៅពីក្រុមកាំភ្លើងធំនិងក្រុមរថក្រោះ<ដែលជារបស់គណៈមជ្ឈិម>ក៏<>ចូលជាមួយនឹង<កងពលធំ>របស់ រ៉ែន នេះដែរ”។ តើវាជួយរំឭកដល់ការចងចាំទេថាមានកងរថក្រោះ និងកងកាំភ្លើងធំដែលជាកងពលរបស់មជ្ឈិមនេះ ក៏បានបញ្ជូនទៅ ឲ្យអមជាមួយនឹងកងពលធំ

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដែល រ៉ែន ក្ដោបក្ដាប់ដែរ។ លោកដឹងរឿងនេះទេ?

[១១:៤៤:២៦]

**លោក អៀង ផាន៖**

**ផ៖** បាទ ខ្ញុំដឹងតើ ប៉ុនខ្ញុំនិយាយមិនទាន់ចប់អំមិញបាទ។ ដឹងថានៅស្វាយរៀងហ្នឹង កងពលធំហ្នឹងមានកងរថក្រោះមួយកង ហើយមានកងកាំភ្លើងធំមួយកង អមនឹងកងពលធំហ្នឹង។

**ស៖** តើលោកដឹងទេហេតុអ្វីបានជាកងទាំងពីរហ្នឹង កងកាំភ្លើងធំនិងកងរថក្រោះហ្នឹងជាចំណុះឲ្យមជ្ឈិម?

**ផ៖** ខ្ញុំមិនយល់ថាជំនាន់ហ្នឹងចំណុះឲ្យមជ្ឈិមយ៉ាងណានោះទេ ប៉ុនគ្រាន់ថា ពេលដែលខ្ញុំទៅដល់ហ្នឹងគឺថាកងកាំភ្លើងធំ កងរថក្រោះហ្នឹង គឺចំណុះឲ្យ រ៉ែន ហ្នឹងហ្នង។ បាទចំណុះឲ្យ រ៉ែន អ្នកបញ្ជា អ្នកគ្រប់គ្រង អ្នកដឹកនាំ អ្នកដោះស្រាយភ័ស្តុភារអី លើ រ៉ែន ហ្នឹងទាំងអស់។ ខ្ញុំមិនដឹងថាមជ្ឈិមដាក់មកយ៉ាងណា ប៉ុនខ្ញុំដឹងកម្រិតប៉ុណ្ណឹងបាទ។

[១១:១៥:៤៩]

**ស៖** នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោក ចម្លើយលេខ៥ លោកបានលើកឈ្មោះអ្នកដែលទទួលខុសត្រូវកងពល<តូច>ដទៃៗទៀត<នៅក្នុងកងពលធំនេះ>យកមកនិយាយ សូមដកស្រង់៖ "ទាំងប្រាំកង<ពល>តូចហ្នឹងកើតបានជាកងពលមជ្ឈិមមួយដែលដឹកនាំ<ដោយ> រ៉ែន។" បញ្ចប់ការដកស្រង់។ ចុះហេតុអីបានជាលោកនិយាយថា <>ជាកងពលធំ<>មជ្ឈិម?

**ផ៖** ខ្ញុំមិនយល់ថាវ៉ៃខុស ឬក៏វ៉ៃត្រូវយ៉ាងម៉េចទេ ប៉ុន្តែជាក់ស្ដែងគឺថា នៅស្វាយរៀងហ្នឹងគេរៀបចំមួយកងពលធំ អត់មានវរសេនាតូចទៀតទេ។ មួយកងពលធំហ្នឹងមានប្រាំកងពលតូច។ ឯកសារខ្ញុំសម្ភាសអីហ្នឹងកាលគេយកទៅវ៉ៃអីខុសម៉េច ខ្ញុំមិនដឹងទេ ប៉ុន្តែខ្ញុំឆ្លើយ ខ្ញុំៗសម្ភាសនេះ ខ្ញុំនិយាយច្បាស់របស់ខ្ញុំណាស់ ហើយខ្ញុំរាប់ឈ្មោះឲ្យស្ដាប់ទៀត។ ឈ្មោះអីប្រធានកងពលតូចណាឈ្មោះអី ប្រធានកងពលតូចណាឈ្មោះអី សូមពិនិត្យឡើងវិញមើល បាទ។

**ស៖** តើលោកនៅឈរជើងឯស្វាយរៀងរហូតដល់ពេលវៀតណាមវាយលុកចូលមកនៅដំណាច់ឆ្នាំ៧៨នោះឬ? គឺខែធ្នូ ឆ្នាំ១៩៧៨។

**ផ៖** ខ្ញុំសូមជម្រាបថា ខ្ញុំទៅបាន ខ្ញុំទៅពាក់កណ្ដាល៧៨ ទៅបាន២ខែខ្ញុំត្រូវរបួស ហើយរបួសហ្នឹងធ្ងន់ដែរ របួសធ្ងន់ខ្ញុំមកសម្រាកពេទ្យនៅភ្នំពេញ។ អ៊ីចឹងពេលដែលវៀតណាមវ៉ៃចូលមកទ្រង់ទ្រាយ

ធំគឺខ្ញុំនៅពេទ្យនៅឡើយ។ ក្រោយពីរបួសមកអត់ក្តាប់បានសមរភូមិយ៉ាងណានោះទេបាទ វាមកនៅភ្នំពេញហើយ។ ដល់វៀតណាមវ៉ៃដល់ចូលដល់ស្វាយរៀង ខ្ញុំចេញពីពេទ្យទៅកម្លាំងវារប៉ាត់រប៉ាយអស់ហើយ ទៅជួបកម្លាំងនៅឯព្រៃវែងនោះ។ ព្រៃវែងដកថយមកព្រំដែនបណ្តោយ។ បាទ សូមជម្រាបប៉ុណ្ណឹងទេ។ ឯការប្រយុទ្ធអីតឹងតែងយ៉ាងនោះ គឺខ្ញុំរបួសហើយ របួសនៅប្រសូត្រនោះលោកប្រធានស្រុកប្រសូត្រនោះបាទ របួសធ្ងន់ទៀត។

[១១:១៨:២៥]

**ស៖** នៅពេលលោកទៅដល់ស្វាយរៀងដំបូង នៅពាក់កណ្តាលឆ្នាំ៧៨ តើលោកដឹងថាកងទ័ពវៀតណាមឈរជើងនៅឯណាដែរ តាមបណ្តោយព្រំដែន<កម្ពុជា>?

**ឆ៖** ខ្ញុំសូមជម្រាបថាពេលដែលខ្ញុំទៅដល់ស្វាយរៀង ខ្ញុំបាននិយាយពីមុនអម្បាញ់មិញថា គ្រាន់តែដល់ជិតទីរួមស្រុកប្រសូត្រហ្នឹង ភូមិចក វៀតណាមនៅនឹងស្រេចហើយ ហើយបាញ់ខាងខ្ញុំហ្នឹងឆេះបីឡានហើយស្រេចហើយ។ បានន័យថា អត់មានវៀតណាមអត់មាននៅព្រំដែនទៀតទេ មកដល់ស្រុកប្រសូត្រ មកដល់ភូមិចកអស់ហើយ បាទមកដល់ភូមិចកអស់ហើយ មកៗផុតព្រំដែនកម្ពុជាចូលជ្រៅដល់ៗទីរួមស្រុកប្រសូត្រហើយនៅឆ្ងាយ។

**ស៖** សូមអរគុណចំពោះការបញ្ជាក់បំភ្លឺនេះ។ តើកងពលតូចអន្តរាគមន៍ហ្នឹងមានមុខងារធ្វើអ្វី? តើកងពលតូច<អន្តរាគមន៍>មួយនេះ មានមុខងារខុសពីកងពលតូច<ធម្មតា>យ៉ាងដូចម្តេចដែរ?

**ឆ៖** ខ្ញុំសូមជម្រាបថាមុខងាររបស់កងពលតូចអន្តរាគមន៍នេះ ហៅថាមុខងារពិសេស គឺមិនប្រចាំនៅមុខសញ្ញាណាងាប់ក្រឡាទេ គឺមានភារកិច្ចចល័តបានគ្រប់កន្លែងទាំងអស់តាមតម្រូវរបស់ថ្នាក់លើ អត់ទៅឈរជើងនៅរុំរ៉ៃដូចទាហានថ្មើរជើងទេ ឧបមាថាកន្លែងណាមានអាសន្នអី ថ្នាក់លើថា អ្នក! ឥឡូវកងអន្តរាគមន៍ទៅ! គឺចល័តទៅហើយ។ អាហ្នឹងភារកិច្ចរបស់កងអន្តរាគមន៍គឺអ៊ីចឹងកងពលហ្នឹង។

**ស៖** អ៊ីចឹងគឺថា អ៊ីចឹងលោកមិនមែនតែនៅឈរជើងប្រយុទ្ធតែនៅឯប្រសូត្រទេ គឺថានៅតំបន់ដទៃទៀត ក៏ៗលោកទៅប្រយុទ្ធដែរ ឲ្យតែទទួលបានបញ្ជា អ៊ីចឹងមែនទេ?

**ឆ៖** ពិតអ៊ីចឹង។

[១១:២០:៤៦]

**ស៖** តើលោកអាចនៅនឹកឃើញ និងចងចាំជម្រាបផងថាទីតាំងដែលលោកទៅវ៉ៃក្រៅពីប្រសូត្រ នោះនៅកន្លែងណាខ្លះដែរនៅស្វាយរៀងហ្នឹង?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ធ៖** ខ្ញុំសូមជម្រាបថា បើឲ្យខ្ញុំរៀបរាប់ពីសមរភូមិប្រយុទ្ធវាច្រើនណាស់ ខ្ញុំមិនអាចចាំបានទេ ប៉ុន្តែខ្ញុំនិយាយថាច្រើនហ្នឹង។ លោះថ្ងៃតិចណាស់បាទ។ បើយើងនិយាយភាសាខ្មែរថា ជីវិតហ្នឹងវាគំរាមកំហែងរាល់ថ្ងៃហ្នឹង វាអត់មានថ្ងៃណាដែលមិនមានការគំរាមកំហែងទេ បាទ។ ហើយភារកិច្ចរបស់អន្តរាគមន៍ហ្នឹងកន្លែងណាលំបាក គឺគេរុញឲ្យទៅហ្នឹងហើយ កន្លែងណាលំបាក កន្លែងណាតឹងតែងឲ្យទៅនោះហើយ។ ឧទាហរណ៍ដូចខ្ញុំបានជម្រាបថា វៀតណាមមកដល់ស្រុកប្រសូត្រហើយ អ៊ីចឹងថ្នាក់លើជំរុញឲ្យទៅហ្នឹង ប៉ុនការពិតវៀតណាមមាននៅត្រឹមស្រុកប្រសូត្រងណា មកហួសទៀត បើយើងបើកឡានទៅដល់គេវ៉ៃមុនបាត់ហើយ។ អាហ្នឹងសូមជម្រាបអ៊ីចឹង ភារកិច្ចពិសេសអ៊ីចឹង បាទ។

**ស៖** នៅពេលដែលលោកនិយាយថាថ្នាក់លើជាអ្នកបញ្ជាទៅហ្នឹង តើថ្នាក់លើហ្នឹងជាអ្នកណា?

**ធ៖** ខ្ញុំសូមជម្រាបថា ថ្នាក់លើហ្នឹងមិនខុសពីកងពលធំ រ៉ែន ហ្នឹងទេ បាទ ព្រោះរ៉ែន ហ្នឹងក្ដាប់កងពលតូចទាំងបួន ទាំងប្រាំហ្នឹង។ អ៊ីចឹងបញ្ជាអីទាំងអស់គឺលើ រ៉ែន ហ្នឹងទាំងអស់ បាទ សូមជម្រាបឲ្យច្បាស់អ៊ីចឹងបាទ។

[១១:២២:៣២]

**ស៖** តើមន្ទីររបស់ រ៉ែន ហ្នឹងនៅកន្លែងណាដែរនៅស្វាយរៀងហ្នឹង?

**ធ៖** ខ្ញុំសូមជម្រាបថា ទៅសមរភូមិស្វាយរៀង ទាំងខ្ញុំ ទាំង រ៉ែន ហ្នឹងមិនមានទីស្នាក់ការជាអចិន្ត្រៃយ៍បានទេ ព្រោះប្រយុទ្ធវាមានលក្ខណៈទ្រង់ទ្រាយធំហើយ ហើយវៀតណាមក៏ប្រើយន្តហោះប្រើកាំភ្លើងធំ។ ដូច្នេះអត់មានទីស្នាក់ការណាដែលចាត់ទុកថា ទៅចាត់ចែងការងារងាប់ក្រឡាបានទេ អ៊ីចឹងចល័តរហូត បាទ ខ្ញុំសូមជម្រាបថាចល័តរហូត មិនអាចយកគោលដៅណាច្បាស់លាស់ទេ ឧបមាថាយកស្វាយរៀង នៅស្វាយរៀងអត់បានទេកាំភ្លើងធំ យកកន្លែងណាមួយ ក៏អត់បានដែរ។ អ៊ីចឹងមានលក្ខណៈចល័តហ្នឹង ទីបញ្ជាការចល័តហ្នឹងបាទ។

**ស៖** តើលោកធ្លាប់ដែលឮឈ្មោះកន្លែងមួយឈ្មោះ "ក្រោលគោ" ដែរឬទេ?

**ធ៖** ខ្ញុំឮ ហើយមិនត្រឹមឮទេ ខ្ញុំធ្លាប់បានទៀត ក្រោលគោនោះហួសអ្នកលឿងទៅបន្តិចនេះ។ កន្លែងហ្នឹងទីចាត់ការភស្តុភារហិរញ្ញវត្ថុសម្រាប់ផ្គត់ផ្គង់ទ័ព ឯមេបញ្ជាការអត់នៅកន្លែងទីចាត់ការភស្តុភារទេ គឺចល័ត ខ្ញុំសូមជម្រាបថាចល័ត សង្គ្រាមពេលនោះគឺថាទី -- មេបញ្ជាការមិនអាចនៅកន្លែងណាមួយនឹងថ្កល់បានទេ បាទ មានតែកន្លែងភស្តុភារទេ កន្លែងហ្នឹងបាទ។

**ស៖** ចុះតើអ្នកណាជាអ្នកឈរជើងទទួលខុសត្រូវនៅទី<មន្ទីរ>ភស្តុភារនោះ?

**ឆ៖** ខ្ញុំសូមជម្រាបថាមេបញ្ជាការកងពលធំ ធម្មតាមានរងៗទទួលបន្ទុកខាងយោធា ទទួលបន្ទុកខាងភស្តុភារហិរញ្ញវត្ថុ។ អ៊ីចឹងរងហ្នឹងអ្នកទទួលបន្ទុកការងារភស្តុភារហិរញ្ញវត្ថុ។

[១១:២៥:០០]

**ស៖** នៅឯមន្ទីរភស្តុភារ <តើមានម៉ាស៊ីន>សារទូរលេខ <>អីដែរទេ?

**ឆ៖** មានមួយចប់សម្រាប់ទំនាក់ទំនងទៅតាមកងពលធំ កងតូច -- តាមកងពលតូច តាមភស្តុភារកងពលតូចអីសម្រាប់អញ្ជើញមកយកថវិកា យកអី សម្ភារៈសម្រាប់ផ្គត់ផ្គង់សមរភូមិ គឺថាមានទំនាក់ទំនងគ្នារហូត។ និយាយតាមពាក្យទាហានគឺថា ខ្សែបញ្ជាគឺមានរហូតពីលើដល់ក្រោម។

**ស៖** នៅពេលដែលលោកឈរជើងនៅឯភូមិភាគបូព៌ាហ្នឹង លោកមានដែលបានជួបប្រជុំជាមួយ រ៉ែន ដែរទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា រវាងមេបញ្ជាការកងពលធំនិងមេបញ្ជាការកងពលតូច គឺថា៣ថ្ងៃជួបគ្នាម្តង។ មិនៗឲ្យយូរទេ ពីព្រោះទាក់ទងនឹងអី ទាក់ទងនឹងបញ្ហា ទាក់ទងនឹងប្រយុទ្ធ ទាក់ទងនឹងការរៀបចំកម្លាំង ទាក់ទងនឹងភស្តុភារហិរញ្ញវត្ថុ គ្រាប់រំសេវ អ៊ីចឹងត្រូវការជួបគ្នា បាទ ជួបគ្នា។

**ស៖** នៅក្នុងអង្គប្រជុំហ្នឹងក្រៅពីផែនការវាយប្រយុទ្ធ ក្រៅពីផែនការភស្តុភារ តើមាននិយាយអីក្រៅពីហ្នឹងទៀតដែរទេ?

[១១:២៦:៤៥]

**ឆ៖** ឆ្លងតាមការដែលខ្ញុំទៅរួមប្រយុទ្ធនៅស្វាយរៀងហ្នឹងគឺថា បើនិយាយថាសភាពការណ៍វាចំណុចខ្ពស់ទៅហើយ។ អ៊ីចឹងការដឹកនាំ ការណែនាំ ការអប់រំ ជុំវិញតែយុទ្ធវិធីប្រយុទ្ធ។ មិនៗមានពេលអីទៅនិយាយរឿងនយោបាយអីទៀតទេ ពីព្រោះបើវៀតណាមចង់ដល់ស្វាយរៀងអស់ហើយមាននៅនិយាយរឿងនយោបាយណាទៀត និយាយតែពីរឿងទប់ទល់ រកវិធីទប់ទល់ រកវិធីដកថយ យ៉ាងណាទេឯនយោបាយឯទៀត វាចប់រឿងនិយាយនយោបាយហើយ។ ខ្ញុំសូមជម្រាបអ៊ីចឹង។

**ស៖** តើ រ៉ែន ដែលនិយាយអីអំពីពួកក្បត់ ភូមិភាគបូព៌ា ឬក៏ថាអំពើក្បត់ដែលកម្មាភិបាលបូព៌ាហ្នឹងបានប្រព្រឹត្តអីដែរទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា បាននិយាយជាទ្រឹស្តី គ្រាន់ថានៅបូព៌ាអ្នកនេះក្បត់អ៊ីចេះៗ ហើយបីបួនម៉ាត់អ៊ីចឹងទៅៗរឿងយុទ្ធវិធីសង្គ្រាមណោះវិញ មិនចូលជ្រៅអាបញ្ហាហ្នឹងទេ។ បាទ សូមជម្រាបអ៊ីចឹង។

**ស៖** តើការជួបប្រជុំហ្នឹង គឺជួបប្រជុំនៅឯណា ជួបប្រជុំនៅ<មន្ទីរ>ភស្តុភារ<> ឬក៏ជួបប្រជុំ

នៅកន្លែងផ្សេង?

[១១:២៨:២៦]

**ឆ៖** ខ្ញុំសូមជម្រាបថា ខ្ញុំបានជម្រាបខាងដើមហើយថា ការប្រជុំនេះក៏ចល័តដែរ បន្តិចទៅកន្លែងនេះ បន្តិចទៅកន្លែងនោះ អត់មានប្រជុំនៅនឹងថ្កល់បានទេ ពីព្រោះកាំភ្លើងធំវៀតណាម យន្តហោះវៀតណាមតាមរហូតហ្នឹង។ អ៊ីចឹងអត់មាននឹងថ្កល់បានទេ ហើយមិនអាចរាប់ទីកន្លែងប្រជុំទេ គឺច្រើនកន្លែងណាស់ ខ្ញុំមិនអាចរាប់បានទេ ច្រើនកន្លែងណាស់ រាប់ឈ្មោះចេះតែបានហើយ ប៉ុន្តែគ្រាន់ថា--។

**ស៖** តើ រ៉េន មានដែលផ្តល់ព័ត៌មានអ្វីដែលគាត់បានទទួលតាមរយៈសារទូរលេខ ដើម្បីប្រាប់ទៅលោកទេនៅក្នុងអង្គប្រជុំទាំងនេះ?

**ឆ៖** ខ្ញុំសូមជម្រាបថា រវាងមេបញ្ជាការកងធំ និងកងពលតូចដូចខ្ញុំបានជម្រាបខាងដើមអ៊ីចឹងគឺថា ការដឹកនាំប្រជុំម្តងៗគឺថា និយាយចិញ្ច្រាំៗពីយុទ្ធវិធី ពីការគ្រប់គ្រងកម្លាំងទប់បានមិនបាន ដកយ៉ាងម៉េចអី ដកថយយ៉ាងម៉េច ហើយរៀបចំកម្លាំងយ៉ាងម៉េច គឺមានតែប៉ុណ្ណឹងទេ។ គឺណែនាំតែជុំវិញបញ្ហាយោធាតែម្តង ហើយសំខាន់គឺស្បៀង ធំជាងគេគឺស្បៀង។ ពេលដែលវៀតណាមវ៉ៃចូលមក គឺឲ្យប្រយ័ត្នបំផុតគឺស្បៀងនេះឯង។

[១១:៣០:០៤]

**ស៖** ខ្ញុំសូមអានសម្រង់មួយចេញពីកំណត់ហេតុស្តាប់ចម្លើយរបស់ សុខ ឈឿន គឺ E3/428 អង់គ្លេស 00374950, បារាំង 00485476 ដល់ 77, ខ្មែរ 00373485។ នេះគឺអ្វីដែលគាត់បានឆ្លើយ សុំដកស្រង់៖ "ខ្ញុំមិនដែលបានឃើញ ឬទទួលសារទូរលេខដោយផ្ទាល់ដៃទេ ប៉ុន្តែខ្ញុំបានស្តាប់ឮខ្លឹមសារនៅក្នុងសារទូរលេខទាំងនេះ ដែលគាត់អាននៅក្នុងអង្គប្រជុំ។ នៅពេលខ្ញុំនៅឯស្វាយរៀងនោះ គឺ រ៉េន បាននិយាយអំពី<ខ្លឹមសារសំខាន់នៃ>សារទូរលេខ<មួយចំនួន> គឺគេនិយាយអំពីការពង្រឹងទ័ពដើម្បីវាយបកទៅវៀតណាមវិញ ហើយត្រូវតែសហការជាមួយប្រជាជន ហើយត្រូវតែមានជំហរដាច់ខាតជាមួយវៀតណាម មិនត្រូវមានការចរចាអ្វីជាមួយវៀតណាមឲ្យសោះ។ វៀតណាមនេះគឺថាត្រូវចាត់ទុកជាខ្មាំងជាដាច់ខាត។" បញ្ចប់ការដកស្រង់។ អ៊ីចឹង<>តើ<លោកនឹកឃើញទេថា> រ៉េន <អាចពិភាក្សាអំពី>សារទូរលេខ<ប្រហាក់ប្រហែលគ្នា>នេះ<នៅក្នុងកិច្ចប្រជុំជាមួយលោក>ដែរឬទេ?

**ឆ៖** ខ្ញុំបានបញ្ជាក់ហើយថា ការណែនាំវាច្រើនបញ្ហាណាស់ បញ្ហាខ្លះខ្ញុំមិនចាំអស់ទេ ព្រោះបើគិតពេលវេលាមកដល់ឥឡូវ វាវែងណាស់ ម្ភៃសាមសិបឆ្នាំទៅហើយ។ អ៊ីចឹងចាំខ្លះ អត់ខ្លះ។ ហើយការ

ណែនាំនេះ វាច្រើនណាស់។ ហើយទាក់ទងនឹងកម្ពុជាវៀតណាមគឺខ្ញុំឯកភាពហើយ ពីព្រោះខាងលើណែនាំថាដាច់ខាតហើយ ពីព្រោះអត់មានសម្រុះសម្រួលទេ។ អាហ្នឹងន័យហ្នឹងគឺមាន មានជាប់ក្នុងកងទ័ពជាទូទៅអ៊ីចឹងតែម្តង បាទ អត់សម្រុះសម្រួលបានទេ។

**ស៖** ហើយថ្នាក់លើដែលលោកឡើងហ្នឹង <តើមានការបញ្ជាក់ពី> រ៉ែន <ទេថា នេះគឺមក>ពីភ្នំពេញ <>ឬ<ពីមជ្ឈិម ឬមួយក៏លោកមិនដឹងទេថា តើ រ៉ែន បានទទួលព័ត៌មាននោះមកពីណា ឬក៏នោះជាការណែនាំរបស់គាត់>?

**ឆ៖** ខ្ញុំថ្នាក់ក្រោម ខ្ញុំមិនយល់ថាមកពីណាទេ។ និយាយត្រង់អ៊ីចឹងតែម្តង គឺថាមិនដឹងថាសារទូរលេខហ្នឹងមកពីមជ្ឈិម មកពីអីយ៉ាងណាទេ ប៉ុន្តែដឹងថាត្រឹម រ៉ែន ហ្នឹងបាទ។

[១១:៣២:៤២]

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

លោកប្រធាន តើអនុញ្ញាតឱ្យខ្ញុំបន្តទៅទៀត ឬក៏ឈប់សម្រាកត្រឹមនេះសិន?

**ប្រធានអង្គជំនុំ៖**

លោកទាមទារពេលវេលា ជួសជុលពេលវេលាបន្ថែម។ ពេលវេលាសម្របសម្រួលដឹកនាំសវនាការលើប្រធានជាអ្នកចាត់ចែង។ ប្រធានមិនទាន់ឱ្យឈប់ផង មានន័យថាតទៅទៀត។ យើងដូចជារំពឹងច្រើនដងហើយ។

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** ត្រឹមត្រូវ។ លោកសាក្សី តើលោកដឹងទេថា រ៉ែន មានបានឡើងមកភ្នំពេញដើម្បីជួបប្រជុំណាមួយ ហើយយកព័ត៌មាននេះ ដែលទទួលបានពីការជួបប្រជុំនៅភ្នំពេញហ្នឹងដើម្បីយកទៅផ្សព្វផ្សាយជូនលោក និងអ្នកដទៃទៀតទេ នៅឯស្វាយរៀងនោះ?

**លោក អៀង ផាន៖**

**ឆ៖** ខ្ញុំសុំជម្រាបថា ជាធម្មតាទេរវាងថ្នាក់លើនិងថ្នាក់ក្រោម ជានិច្ចកាលគឺថា រ៉ែន ក៏មិនធំទាល់តែមកលើ។ ឯមកលើប្រជុំនិយាយយ៉ាងណានោះ គឺខ្ញុំមិនបានដឹងទេ។ ដែលខ្ញុំបានទទួលនោះ ខ្ញុំបានជម្រាបថា ខ្ញុំទទួលបានតែឃោធាទេ បាទ ករណីឃោធាទេ ឯក្រៅពីនេះខ្ញុំក្តាប់មិនបានទេ។ ហើយ រ៉ែន ហ្នឹងគឺឡើងមកញាប់ហើយ ពីព្រោះរវាងកងពលធំ ហើយមជ្ឈិម គឺត្រូវតែជួបគ្នាញាប់ហើយ ប៉ុន្តែ

ជួបនិយាយរឿងអី ខ្ញុំម៉េចដឹងរឿង ព្រោះខ្ញុំបានជម្រាបខាងដើមថា សម័យខ្មែរក្រហមមានពាក្យមួយមាត់គឺថា "ការងារអ្នកណា អ្នកហ្នឹងដឹង មិនត្រូវជ្រៀតជ្រែកការងារអ្នកដទៃទេ"។ កងពលតូចដឹងការងារត្រឹមកងពលតូច កងពលធំដឹងត្រឹមកងពលធំ ឯខាងលើទៀត គឺខាងលើអ្នកដឹង។ ហើយខ្ញុំអត់ក្ដាប់បានទេបញ្ហានេះ មកប្រជុំយ៉ាងម៉េច។ គ្រាន់តែដឹងថាមកហើយ មកញឹកញាប់ទៀត ពេលវៀតណាមវ៉ៃហ្នឹងគឺកាត់តែញាប់ហើយ។ ហ្នឹងសុំជម្រាបប៉ុណ្ណឹង បាទ។

[១១:៣៤:៤២]

**ស៖** លោកបានឆ្លើយថា នៅពេលដែលលោកទៅដល់ទីនោះលើកដំបូងនោះ គឺនៅម៉ោង ១០:២៣:០០វិនាទី៖ "រ៉ែន គឺជាមេបញ្ជាការកងពលធំ ហើយពិតហើយគាត់មានសិទ្ធិចូលរួមប្រជាជុំជាមួយថ្នាក់លើ។ ហើយខ្ញុំគេមិនត្រូវបានអនុញ្ញាតឲ្យប្រជុំជាមួយថ្នាក់លើទេ ក៏ប៉ុន្តែក្រោយពេលប្រជុំ គឺគាត់ត្រូវផ្សព្វផ្សាយព័ត៌មាននៅក្នុងអង្គជំនុំជាមួយមេបញ្ជាការ អនុមេបញ្ជាការកងពលតូចទាំង<ប្រាំ> ដែលចូលរួមប្រជុំជាមួយនឹងគាត់។" តើត្រឹមត្រូវដែរឬទេថាក្រោយពេល រ៉ែន <ត្រឡប់មកពី>ប្រជុំ<ស្ដីអំពីការប្រយុទ្ធគ្នាជាមួយវៀតណាម រួច>ហើយ គឺថារ៉ែន នេះបានយកព័ត៌មាននេះទៅផ្សព្វផ្សាយ<បន្តទៀត> អ៊ីចឹងមែនទេ?

**ឆ៖** ពិតជាអ៊ីចឹងបាទ។

**ស៖** ចុះលោកធ្លាប់បានជួបប្រជុំជាមួយនឹង សុន សេន នៅពេលណាមួយដែរឬទេ នៅឯស្វាយរៀងនោះ?

**ឆ៖** ខ្ញុំសូមជម្រាបថា ខ្ញុំធ្លាប់ចូលរួមប្រជុំជាមួយ សុន សេន នៅក្រោលគោ។ លោក សុន សេន ចល័តពីភ្នំពេញទៅ ទៅក្រោលគោហ្នឹង ធ្លាប់បានចូលរួមប្រជុំម្ដងជាមួយគាត់ ទាក់ទងដែលវៀតណាមវ៉ៃចូលដល់ទីរួមស្រុកចក ហើយប្រសូត្រអីហ្នឹង។ ហ្នឹងលោក សុន សេន អញ្ជើញទៅដល់ហ្នឹង។

[១១:៣៦:២១]

**ស៖** លោកបានលើកឡើងពីខាងដើមថា រ៉ែន នេះបាននិយាយអំពីកម្មាភិបាលបូព៌ាហ្នឹងបានប្រព្រឹត្តអំពើក្បត់ បើទោះណាជាកម្មវត្ថុបេសសកម្មចម្បងរបស់លោក គឺទៅប្រយុទ្ធជាមួយវៀតណាម <ចុះចំណែក សុន សេន វិញ តើគាត់ធ្លាប់>និយាយ<នៅក្នុងអង្គប្រជុំ>អំពីសកម្មភាពក្បត់ដែលប្រព្រឹត្តឡើងដោយកម្មាភិបាលបូព៌ា<ដែរ>ទេ?

**ឆ៖** ខ្ញុំបានជម្រាបខាងដើមហើយថា មុនបើកអង្គប្រជុំហ្នឹង គាត់បាននិយាយពីរបីម៉ាត់ ដល់មេ

ទ័ពទាំងអស់ថា នៅបូព៌ាមានកម្មាភិបាលក្បត់អ៉ីចេះៗ ហើយក៏ចប់ទៅ អត់មាននិយាយអីវែងទេ។ អត់រកមូលហេតុអី ហេតុផលអីឲ្យថ្នាក់ក្រោមដឹងទេ គ្រាន់តែប្រកាសតែប៉ុណ្ណឹង ហើយបានចូលរបៀបវារៈធ្វើការងារ។

**ស៖** តើលោកអាចបញ្ជាក់បានទេនៅឯស្វាយរៀងហ្នឹង លោកបានចូលប្រជុំដោយផ្ទាល់ជាមួយនឹង សុន សេន ហ្នឹងបានប៉ុន្មានដងដែរ?

**ឆ៖** ខ្ញុំសូមជម្រាបថា ពេលវេលាដែលខ្ញុំទៅហ្នឹង គឺខ្លីណាស់ ពាក់កណ្ដាល៧៨។ ពេលដែលខ្ញុំទៅដល់បាន១ខែហ្នឹង គឺខ្ញុំបានជួបប្រជុំម្ដងហើយ ប៉ុន្តែក្រៅពីហ្នឹងមក ខ្ញុំរបួសហើយ របួសរហូតដល់វៀតណាមវ៉ៃចូលហើយ អត់ៗបានចូលរួមប្រជុំអីទៀតទេ។ នេះសូមជម្រាបអ៉ីចឹង ចូលរួមបានប្រជុំម្ដងគាត់ចល័តពីភ្នំពេញទៅកន្លែងក្រោលគោហ្នឹង។

**ស៖** នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោក ត្រង់ចម្លើយលេខ៨ សូមដកស្រង់៖ “ខ្ញុំបានចូលរួមប្រជុំជាមួយ សុន សេន នៅខេត្តស្វាយរៀងជាច្រើនដង ជាពិសេសនៅក្រោលគោ នៅពេលដែលគេបញ្ជូនខ្ញុំទៅស្វាយរៀង។ <នោះជា>លើកទី១<ដែលខ្ញុំស្គាល់ សុន សេន>។ <ក្នុងអំឡុងពេលប្រជុំនោះ សុន សេន>ហ្នឹងគាត់និយាយអំពីភារកិច្ចយោធា គាក់ទិកវាយបកទៅកងទ័ពវៀតណាមវិញនៅតាមព្រំដែន។” បញ្ចប់ការដកស្រង់។ អ៉ីចឹងនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោកនេះ លោកបាននិយាយថាលោកបានចូលរួមប្រជុំជាមួយ សុន សេន ហ្នឹង<នៅស្វាយរៀង គឺ>ច្រើនដងដែរ មិនមែនតែម្ដងទេ។ អ៉ីចឹងលោកនឹកឃើញទេ?

**ឆ៖** ខ្ញុំខ្លាចតែវ៉ៃ ខ្ញុំនិយាយទៅដែលអ្នកកំណត់ហេតុខុស សរសេរទៅដាក់ ប៉ុន្តែជាក់ស្ដែង ខ្ញុំបានប្រជុំម្ដង ហើយខ្ញុំរបួសទៅ ហើយមានបានប្រជុំអីទៀត។ ចេញពីរបួសមក វៀតណាមចូលមកបាត់ហើយ។

[១១:៣៩:៤៨]

**ស៖** តើខ្លួនលោកផ្ទាល់ធ្លាប់បានទទួលសារទូរលេខពី រ៉ែន ដែរឬទេ? គឺសារទូរលេខហ្នឹងគឺថាដោយមានទាំងការបង្គាប់បញ្ជានៅក្នុងនោះផង លោកធ្លាប់ទទួលពី រ៉ែន ដោយផ្ទាល់ទេ?

**ឆ៖** ខ្ញុំបានជម្រាបខាងដើមហើយថា រវាងមេបញ្ជាការថ្នាក់លើនិងថ្នាក់ក្រោម គឺថាទទួលទាំងសារទូរលេខ ទទួលទាំងការមកប្រជុំផ្ទាល់ គឺថាជាញឹកញាប់ជាមួយ រ៉ែន ហ្នឹងបាទ។ ជួនកាលតែពីរនាក់ក៏មាន ជួនកាលច្រើននាក់ក៏មាន តាមករណីចាំបាច់ដែលសភាពការណ៍សមរភូមិតម្រូវ ហើយសារ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទូរលេខហ្នឹងជាប្រចាំហើយ បាទសារទូរលេខជាប្រចាំ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាក ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រងចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលសម្រាក និងឲ្យអញ្ជើញគាត់មកកាន់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងមួយកន្លះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួន លោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៤១ នាទី ដល់ម៉ោង ១៣:៣០នាទី)*

[១៣:៣០:៣២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិសវនាការ។ ហើយតទៅនេះ ផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី ហើយបញ្ជាក់ថាសហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលមួយវគ្គនៃថ្ងៃសវនា-ការថែមទៀតទេ ក្នុងការសួរដេញដោលសាក្សីរូបនេះ។

**សួរដោយលោក ចូសេហ្វ អេនគ្រូ ប៊ីយលី៖**

**ស៖** បាទ សូមអរគុណលោកប្រធាន។ លោកសាក្សី ខ្ញុំចង់ត្រឡប់សួរលោកអំពីពេលវេលាដែលលោកបាននៅស្វាយរៀង។ នៅពេលដែលលោកបានទៅដល់ស្វាយរៀងនៅពាក់កណ្តាលឆ្នាំ១៩៧៨ តើលោកបានឃើញជនស៊ីវិលដែលរស់នៅក្នុងតំបន់ដែលលោកត្រូវទៅឈរជើង ឬក៏ត្រូវទៅការពារនោះដែរឬទេ កន្លែងដែលកងលោកទៅនោះ?

**លោក អៀង ផាន៖**

**ផ៖** ខ្ញុំសូមជម្រាបថា ពេលដែលខ្ញុំទៅហ្នឹង នៅខាងសមរភូមិមុខហ្នឹង គឺអត់មានប្រជាជនទេ។ ប្រជាជនមានត្រឹមៗភូមិក្រោលគោ មកអ្នកលឿងមាន ប៉ុន្តែខាងមុខស្វាយរៀងអត់មានទេ មុខទីរួមខេត្តទៅអត់មានប្រជាជនទេ។

**ស៖** តើលោកដឹងដែរឬទេ <មានអ្វីកើតឡើងចំពោះ>ប្រជាជនដែលបានរស់នៅក្នុងតំបន់នោះពីមុន<មក>?

**ផ៖** ខ្ញុំសូមជម្រាបថា ពេលដែលខ្ញុំដល់ហ្នឹង ប្រជាជនជម្លៀសចេញអស់ហើយ។ មូលហេតុដែលជម្លៀសចេញនោះគឺថា ការប្រយុទ្ធគ្នារវាងកងទ័ពកម្ពុជានិងវៀតណាមមានសភាពខ្លាំងក្លា អ៊ីចឹងមិនអាចនៅបានទេ គាត់ជម្លៀសមកខាងក្រោយហើយ។

[១៣:៣២:៥៥]

**ស៖** ចំពោះបញ្ហានេះ ខ្ញុំចង់អានឯកសារជូនលោកស្តាប់ គឺថាE3/862 គឺអង់គ្លេស ERN 00185207 ដល់ 08, ខ្មែរ 00021019, បារាំង 00814597 គឺជារបាយការណ៍នៅសប្តាហ៍ទី១ នៃខែឧសភា <១៩៧៨ ពី>តំបន់២៣ និងតំបន់២៤។ អ្វីដែលនិយាយនោះគឺសូមដកស្រង់ដូចទៅនេះ៖ “នៅក្នុងតំបន់២៣ ខ្មាំងយួនបានចូល<ឈ្លានពាន>ទឹកដីរបស់យើងនៅថ្ងៃទី២៦ មេសា ឆ្នាំ១៩៧៨ ហើយបានចូលអន្ទាក់របស់យើង ឥឡូវនេះយើងហ៊ុមព័ទ្ធវាហើយ។ នៅក្នុងសមរភូមិតំបន់២៣ យើងបានកម្ទេចខ្មាំង ហើយបានកម្ទេចទាំងស្រុង ហើយនិងរថក្រោះផងដែរ។ យើងបានដកប្រជាជនពីស្រុក<ចំនួនបួន> មករស់នៅ<ខាងក្នុងទឹកដី>របស់យើង។ <ស្រុកទាំងនោះរួមមាន ស្រុក>ប្រស្សូត្រ ស្រុកចន្ទ្រា ហើយនិងស្រុកកំពង់រោទិ៍ ហើយនិងស្រុកសំរោងផងដែរ។” ហើយនៅខាងក្រោមបន្ទាប់ នៅជីវភាពប្រជាជននៅផ្នែកដែលនិយាយពីបញ្ហានេះ ឯកសារហ្នឹងនិយាយដូចតទៅនេះ៖ “ដោយសារថាប្រជាជននៅប្រស្សូត្រ កំពង់រោទិ៍ ចន្ទ្រា និងស្រុកសំរោង ត្រូវតែត្រឡប់ទៅសមរភូមិក្រោយ ដោយសារថាពួកគេខ្វះស្បៀងអាហារ...។ល។” សូមចប់សេចក្តីដកស្រង់។ សំណួរថាតើនេះជាការជម្លៀសដែលលោកបាននិយាយដែលថាប្តូរទីតាំងប្រជាជនពីស្រុកចំនួនបួន ទៅសមរភូមិក្រោយនោះ ដូចដែលខ្ញុំបានអានជូនលោកស្តាប់អំមិញ?

**ផ៖** ខ្ញុំបានជម្រាបហើយថា ទោះបីយើងមិនជម្លៀសក៏ប្រជាជនគាត់មកដែរ ពីព្រោះសុទ្ធតែគ្រាប់កាំភ្លើងធំ។ គាត់មកទាំងហ្វូងៗតែម្តង អត់បាច់ជម្លៀសក៏មកដែរ ពីព្រោះប្រយុទ្ធគ្នាហើយ។ ខ្ញុំ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សូមជម្រាបអ៊ីចឹងបាទ។

[១៣:៣៥:២២]

**សៈ** ខ្ញុំនឹងសួរលោកអំពីការផ្តោងកាំភ្លើងធំចំនួនច្រើនៗ <និងការប្រយុទ្ធគ្នានៅតំបន់នោះ។> <>លោកបានធ្វើសក្ខីកម្មផងដែរថា កងរបស់លោកក៏បានចូលរួមប្រយុទ្ធភ្លាមៗពេលដែលលោកទៅដល់ស្វាយរៀង។ ហើយមុននោះលោកបានធ្វើសក្ខីកម្មជូនតុលាការនេះ។ លោកនិយាយ<> នៅម៉ោង ១០:២៤:៤៤វិនាទី<>ថា <មានការ>វាយប្រហារទៅ<>វិញ<ទៅមកជាមួយកងកម្លាំងវៀតណាម> ហើយនៅម៉ោង១៥:២២:២៧វិនាទី <លោកថា មានការ>វាយប្រហារ<គ្នាទ្រង់ទ្រាយធំ>។ <តើមានអ្វីទៀតដែលលោកអាចបន្ថែមបានទេ ដូចជា>រៀបរាប់<អំពីថាតើការប្រយុទ្ធគ្នាជាមួយកងកម្លាំងវៀតណាមមានសភាពបែបណា> នៅពេលដែលលោក<នៅ>ស្វាយរៀង<>នោះ?

**ឆៈ** ខ្ញុំសូមជម្រាបថា ការប្រយុទ្ធគ្នានេះ គឺពេលដែលខ្ញុំទៅដល់នេះគឺមានសភាព យើងប្រើពាក្យថា"រុញទៅ រុញមក"។ អត់មានរុញកងទ័ពវៀតណាមទៅដល់ព្រំដែនវិញទេ អត់ទេ គឺបានតែត្រឹមទីរួមស្រុកប្រសូត្រតែប៉ុណ្ណឹង។ យើងដណ្តើមបានទីរួមស្រុកអ៊ីចឹងទៅ បាន២ថ្ងៃហ្នឹងវៀតណាមយកវិញ រុញទៅ រុញមក ឲ្យរុញវៀតណាមទៅដល់ទឹកដីវៀតណាមវិញអត់ទេ។ តាំងពីខ្ញុំទៅហ្នឹងឃើញតែវៀតណាមមកដល់ស្រុកប្រសូត្រហ្នឹង គ្រាន់រុញទៅរុញមករហូតមក រហូតដល់ខ្ញុំរបួស។

[១៣:៣៧:០២]

**សៈ** នៅពេលដែលលោកនៅស្វាយរៀង តើកាលនោះមានការវាយប្រហារគ្នា ប្រយុទ្ធគ្នាជារៀងរាល់ថ្ងៃដែរឬទេ?

**ឆៈ** ការប្រយុទ្ធជារៀងរាល់ថ្ងៃ មិនៗមានថ្ងៃសម្រាកទេបាទ សូមជម្រាប ព្រោះព្រំដែន គម្លាតពីព្រំដែនមកស្រុកប្រសូត្រឆ្ងាយណាស់ ហើយទទឹងមុខហ្នឹងគឺធំណាស់ វៀតណាមចូលមកធំ។ អ៊ីចឹងគឺថា បើមិនប៉ះអង្គភាពកងពលមួយ ប៉ះអង្គភាពកងពលមួយទៀត ព្រោះវាប្រឈមដាក់គ្នាកងពល។ អ៊ីចឹងវា ជួនកាលចំមុខ អត់ប្រយុទ្ធ ប៉ុនពីឆ្វេងពីស្តាំប្រយុទ្ធ ជារៀងរាល់ថ្ងៃអ៊ីចឹងតែម្តង រហូតវៀតណាមលើកទ័ពដោយទ្រង់ទ្រាយធំមកតែម្តង។ អានេះសូមជម្រាបអ៊ីចឹង។

**សៈ** លោកបានបញ្ជាក់ខាងដើមនេះថា លោកបានរងរបួសនៅពេលដែលលោកនៅស្វាយរៀង។ <ខ្ញុំឮថាលោកនិយាយថា> របួសនោះដោយសារគ្រាប់កាំភ្លើងធំ តើលោកវាយប្រយុទ្ធនៅកន្លែងណាដែលលោកបានទទួលរងរបួសនោះ?

**ឆ៖** ខ្ញុំប្រយុទ្ធនៅ ភូមិចក១។ ត្រូវ១គ្រាប់កាំភ្លើងលើរថក្រោះ កាំភ្លើងធំលើរថក្រោះ។ ខ្ញុំសូមជម្រាបថា១ថ្ងៃហ្នឹងខ្ញុំត្រូវពីរដង ត្រូវកាំភ្លើងធំលើរថក្រោះហើយ ពេលសែងរបួសខ្ញុំមក ទាក់មីនត្រូវមួយអំបែងក្បាលទៀត អត់ងាប់។

**ស៖** ថាតើមានសមាជិកចំនួនច្រើនដែរឬទេនៅក្នុងកង<ពលតូច>អន្តរាគមន៍របស់លោក <ត្រូវបានសម្លាប់> ឬក៏ត្រូវរងរបួស <ឬក៏ត្រូវ>បានចាប់<ដោយកងទ័ពវៀតណាម>ដែរឬទេ?

[១៣:៣៩:១៧]

**ឆ៖** ខ្ញុំសូមជម្រាបថាពេលប្រយុទ្ធគ្នានេះគឺថា អង្គភាពយើងខ្ញុំពលី ស្លាប់ច្រើន ហើយរបួសក៏ច្រើនដែរ ហើយបាត់ខ្លួនក៏ច្រើន បាត់ខ្លួននេះមិន១ដឹងថាវៀតណាមចាប់ ឬក៏បាត់ខ្លួនដោយសារអី ប៉ុន្តែបាត់រហូតទាល់សព្វថ្ងៃនេះ អត់មានឮដំណឹងអីទេ។

**ស៖** លោកបានបញ្ជាក់នៅក្នុងការឆ្លើយសំណួររបស់ខ្ញុំដែលថាមានទីតាំងច្រើន ដែល<ត្រូវប្រាប់ឈ្មោះ ដែលលោកបានចូលពាក់ព័ន្ធនឹងការប្រយុទ្ធនៅស្វាយរៀង> ដោយសារលោកប្តូរទីតាំងពីកន្លែងមួយទៅកន្លែងមួយ <ថាតើកន្លែងទាំងនោះ មានកន្លែងមួយហៅថាបាវិត ដែរឬទេ?> តើលោកធ្លាប់វាយប្រយុទ្ធជាមួយវៀតណាមនៅបាវិតដែរឬទេ បាទ?

**ឆ៖** ខ្ញុំបានជម្រាបខាងដើមហើយថា ខ្ញុំទៅនេះវៀតណាមមកដល់ប្រសូត្រ មកដល់ចកទៅហើយ មានរឿងអីឲ្យខ្ញុំទៅដល់បាវិតទៀត បើវៀតណាមមកហួសបាវិតមកដល់សាលាស្រុកប្រសូត្រហើយនិងស្រុកចកនេះហើយហ្នឹង បាទ មានអីខ្ញុំទៅបាវិត? អត់បានទៅបាវិតទេ បាទ។

**ស៖** តើលោកបានវាយប្រយុទ្ធនៅក្នុងតំបន់ នៅតំបន់មួយដែលគេហៅថា ចំពុះទា តើលោកធ្លាប់ច្បាំងគ្នានៅកន្លែងហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំសុំជម្រាបថា នៅតំបន់ចំពុះទានេះមានតែអ្នកទៅមុនខ្ញុំ បាន១ប្រយុទ្ធ ហើយខ្ញុំទៅនេះដូចខ្ញុំជម្រាប ខ្ញុំទៅវៀតណាមមកហើយ ហួសចំពុះទាមកហើយ បាទ។

**ស៖** តើលោកនៅចាំដែរឬទេថា <ពួកគេបានចូលមកជ្រៅក្នុងតំបន់នោះ>នៅក្នុងខែមិថុនា ឆ្នាំ១៩៧៨<>?

**ឆ៖** ខ្ញុំយល់ឃើញថា ក្នុងការប្រយុទ្ធគ្នានៅស្វាយរៀង មានលក្ខណៈទ្រង់ទ្រាយធំនេះ សម្រាប់កងទ័ពកម្ពុជាមិនបានរុញកងទ័ពវៀតណាមឲ្យឃ្លាតឆ្ងាយទេ អត់ទេ។ ពីមុនមកយ៉ាងម៉េច ខ្ញុំមិនទាន់ទៅដល់ ប៉ុន្តែត្រឹមម៉ាខ្ញុំទៅដល់ហ្នឹង អត់ទេ។ បានត្រឹមតែចាក់ឆ្វេង ចាក់ស្តាំ វៀតណាមមកហួស ថយ –

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ចាក់ឆ្វេង ចាក់ស្តាំ វៀតណាមមកហួស ថយ។ ឯរុញវៀតណាមឲ្យដល់ព្រំដែនវិញអត់ទេ អត់មានទេ បាទ។

[១៣:៤២:២៥]

**ស៖** ខ្ញុំនឹងអានសេចក្តីដកស្រង់ពី<អត្ថបទ>សារព័ត៌មាន<មួយ ដែលវាមាននៅក្នុងសំណុំរឿង> គឺថា ដែលគេសរសេរពីតំបន់ចំពុះទា គឺឯកសារ E3/8234 មានតែ<មួយ>ទំព័រទេ គឺនៅថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ១៩៧៨ <កាសែតវ៉ាស៊ីនតោនប៉ុស្តិ៍>សារព័ត៌មាននោះសរសេរថា សុំដកស្រង់៖ "វិទ្យុផ្សាយសំឡេងអាមេរិកាំងប្រកាសថ្ងៃនេះថា ប្រហែលជាទ័ពវៀតណាម <៨០.០០០ នាក់> បានធ្វើការវាយប្រហារ<ចូលកម្ពុជានៅ>តំបន់ចំពុះទា។ វិទ្យុវី.អូ.អេ<ដកស្រង់សម្តីរបស់មន្ត្រីសហរដ្ឋអាមេរិក> នៅទីក្រុងវ៉ាស៊ីនតោន។ <ទីភ្នាក់ងារសារព័ត៌មាន បាននិយាយ>ថា <កងកម្លាំងវៀតណាម>បានវាយប្រហារលុបបំបាត់ចោលកងវរសេនា<តូច>មួយ<>របស់<កម្ពុជា>នៅ<ក្នុងខេត្ត>តៃនិញ <និងមួយទៀតនៅស្រុក>ប៊ិនខារ។ <កាសែតនោះរាយការណ៍ថាកង>ទ័ព<កម្ពុជា១៦០នាក់ត្រូវបានសម្លាប់នៅលើសមរភូមិ នៅថ្ងៃទី២០ ដល់ថ្ងៃទី២៣ មិថុនា នៅក្នុងស្រុកចូវថាញ់>។" អ៊ីចឹងតើលោកនឹកឃើញដែរឬទេ នៅក្នុងខែមិថុនា ឆ្នាំ១៩៧៨ គឺការវាយប្រហារចូលមកដោយកងទ័ពវៀតណាមហ្នឹង ទ្រង់ទ្រាយធំគ្រាន់បើ បាទ?

**ឆ៖** ក្នុងខែមិថុនានេះ ខ្ញុំអត់ទាន់ទៅដល់ទេបាទ។ អ៊ីចឹងការប្រយុទ្ធគ្នារវាងកងទ័ពវៀតណាម និងកងទ័ពកម្ពុជា គឺតាមខ្ញុំដឹង គឺក្នុងក្របខ័ណ្ឌកងពល៧០៣ ដែលបោះចំនៅតាញនិញហ្នឹង បាទ ៧០៣ ព្រោះខ្ញុំមិនទាន់ទៅដល់។ ដែលមានលក្ខណៈទ្រង់ទ្រាយ វៀតណាមប្រយុទ្ធមានលក្ខណៈទ្រង់ទ្រាយធំហ្នឹងហើយ បានគេបញ្ជូនខ្ញុំពីតាកែវទៅស្វាយរៀងហ្នឹង បាទ មុនខ្ញុំទៅដល់។

[១៣:៤៤:២៣]

**ស៖** តើលោកនៅឮដែរទេ គឺថាកងពល៧០៣ បានវាយប្រហារ<នៅក្នុងខេត្ត>តៃនិញ ហើយនៅ<ស្រុក>ប៊ិនខារផងដែរ? តើលោកបានឮពីព័ត៌មាននេះទេ?

**ឆ៖** ខ្ញុំបានឮព័ត៌មានថា កងពល៧០៣ ចូលទៅវៃមិនដល់តៃនិញទេ បាទ តាមខ្ញុំដឹងមិនដល់តៃនិញទេ ដល់តែត្រឹមផ្លូវកៅស៊ូទេ ហើយត្រូវកងទ័ពវៀតណាមឡោមព័ទ្ធកម្ទេច ស្ទើរទាំងស្រុងៗ សល់តិចណាស់ដែលមកៗដល់ដីកម្ពុជាវិញ។ ហ្នឹងសូមជម្រាបអ៊ីចឹង។

**ស៖** តើការដែល -- <តើលោកគិតថា ដោយសារតែ>ការចាញ់<របស់>កងពល៧០៣ហ្នឹង

<ឬ ទើបជាមូលេហាតុដែលគេបញ្ជូនលោកពីនិរតីទៅបូព៌ាជាមួយទាហានជាច្រើនផ្សេងទៀត>?

**ធ៖** ចំណុចនេះហើយដែលខ្ញុំបានបញ្ជាក់ថា មូលហេតុដែលគេជ្រើសរើសគ្រប់បណ្ដាកងពលប្រចាំនៅតាកែវនេះ ហើយបន្ថែមរៀបចំជាកងអន្តរាគមន៍២២១នេះ ដើម្បីទៅជួយ ប៉ុន្តែទៅជួយនេះ មិនមែនទៅសំដៅទៅតែនិញទេ គឺទៅចំមុខប្រស្វូត្រនិងចកនេះ ដើម្បីទប់ខាងហ្នឹង ទាញកម្លាំងវៀតណាមពីខាងនោះ ឲ្យមកទប់ខាងនេះវិញ។

**ស៖** តើលោកបានដឹងថា មានការទម្លាក់គ្រាប់បែកពីយន្តហោះ ឬក៏វាយប្រហារពីលើអាកាសមកដែរឬទេ<ពេលលោក>នៅស្វាយរៀង? <លោកបានរៀបរាប់>ថា<មាន>យន្តហោះប្រយុទ្ធរបស់វៀតណាមគេបាញ់គ្រាប់រ៉ុក្កែត ឬក៏ទម្លាក់គ្រាប់បែកអីពីលើអាកាស<>នៅឯខេត្តតាកែវ <តើមានយន្ត-ហោះវៀតណាមទម្លាក់គ្រាប់បែកនៅស្វាយរៀងទេ ពេលលោកនៅទីនោះ>?

[១៣:៤៦:៤៧]

**ធ៖** ខ្ញុំសូមជម្រាបថា នៅស្វាយរៀង វៀតណាមប្រើយន្តហោះច្រើនជាងតាកែវ។ តាកែវ ប្រើត្រឹមយន្តហោះបាញ់រ៉ុក្កែតមួយគ្រឿងអីទេ ប៉ុន្តែបើនៅស្វាយរៀង ប្រើម៉ិចតែម្ដង ប្រើយន្តហោះប្រយុទ្ធតែម្ដង ហើយនិងកាំភ្លើងធំ។ កាំភ្លើងធំហ្នឹងច្រើន យន្តហោះហ្នឹងក៏ច្រើនគ្រឿងដែរ បាទ។ មុននឹងបើកយុទ្ធនាការធំហ្នឹង គឺវើៗខ្លាំងណាស់ វើបានៗតែកងទ័ពថ្មើរជើងចូល។

**ស៖** តើកងអន្តរាគមន៍របស់លោក បានចូលរួមក្នុងការដាក់មីន ហើយនិងដាក់ចម្រូងនៅតាមព្រំដែន ឬក៏ខ្សែត្រៀមណាមួយ ដើម្បីការពារប្រឆាំងនឹងកងទ័ពវៀតណាមដែរឬទេ?

**ធ៖** ខ្ញុំសូមជម្រាបថា ពេលដែលទៅដល់ស្វាយរៀងហើយអត់បានគិតពីរឿងចម្រូងទេ បាទ ពីព្រោះវាធ្លាយៗពីព្រំដែនមក អត់មានដាក់ចម្រូងកើតទៀតទេ ខ្ញុំសូមជម្រាបអ៊ីចឹង។ ឯមីន ក៏យើងអត់ដាក់កើតទៀតដែរ វាទាក់ទងនឹងប្រជាជនខ្លះរត់ចេញ អត់បានដាក់ៗមីន ដាក់ចម្រូងអីកើតទៀតទេ។

[១៣:៤៨:២៥]

**ស៖** ខ្ញុំចង់អានសេចក្ដីដកស្រង់ជូនលោកស្ដាប់ គឺថាដកស្រង់សក្ខីកម្មរបស់បុគ្គលម្នាក់ដែលមកធ្វើសក្ខីកម្មពីអាទិត្យមុន គឺៗអនុកង<ពលតូច>៣៤០ <ឈ្មោះ ជួន ធី។ នេះគឺជាសេចក្ដីព្រាងប្រតិ-ចារឹក>នៅថ្ងៃទី<២៦> តុលា ឆ្នាំ២០១៦ នៅម៉ោង<១០:៥៥:៥៥ វិ>នាទី គឺថា៖ “គេដាក់<>ចម្រូង<នៅតាមព្រំដែន> ហើយ<>ចម្រូងទាំងអស់ហ្នឹង<ធ្វើពីឈើឫស្សី។ យើងគិតថា យើងក៏អាចជាប់ចម្រូងនោះផងដែរ។ ចម្រូងទាំងអស់នោះគឺ>គេដាក់<តែ>នៅព្រំដែន<តែប៉ុណ្ណោះ។ បញ្ចប់ការដក

ស្រង់>។ អ៊ីចឹងថាតើលោកនៅចាំទេ<ពាក់ព័ន្ធនឹង>សមាជិកចេញពីកងពល<របស់លោកបាន>ដាក់ចម្រូង<នៅតាមព្រំដែន>?

**ឆ៖** ខ្ញុំសូមជម្រាបថា ពេលដែលខ្ញុំទៅដល់ហ្នឹង ដូចមិនមានគំនិតអីនៅដាក់ចម្រូងអីទៀតទេ។ បើដាក់ពីមុននៅព្រំដែន ហ្នឹងខ្ញុំជឿថាមានដាក់ចម្រូង មានដាក់មីនខ្លះ។ ប៉ុន្តែដល់ពេលប្រយុទ្ធគ្នា ផ្លាយពីព្រំដែនមកហើយ ដូចជាមិនមានដាក់ចម្រូងទៀតទេ។ អត់មានចម្រូងណាបិតយកទៅទៀតទេ បាទ។ សមរភូមិ វាលាតសន្ធឹងធំហើយ អត់មានដាក់ចម្រូងកើតទេ បាទ។

**ស៖** ខ្ញុំនឹងអានជូនស្តាប់ពីឯកសារមួយទៀត គឺរបាយការណ៍អំពីសប្តាហ៍ទី១ នៃខែឧសភា ឆ្នាំ១៩៧៨ នៅ<តំបន់ភ្លោះ> តំបន់២៣ និង តំបន់២៤ គឺ E3/862 គឺ ERN ជាអង់គ្លេស 00185208, ភាសាខ្មែរ 00021020, បារាំង <00814598>។ <របាយការណ៍នេះនិយាយថា> “យើងបានចលនាប្រជាជនដើម្បីឲ្យផលិតចម្រូងឲ្យបានចំនួន<១.៦៣៥.៣៨០ដើម>ដើម្បី<ផ្តល់ទៅ>សមរភូមិ។” <បញ្ចប់ការដកស្រង់>។ តើលោក<កំពុងតែនិយាយថា លោកមិនបានដឹងអំពី>ចម្រូង<ដែលមានចំនួនលើស ១លាន -- >ស្ទើរតែ<>២លាន ត្រូវបានគេដាក់នៅតំបន់នៅស្វាយរៀងនោះ<ទេឬ>?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! អញ្ជើញលោកស្រី អង់តា ហ្គិសសេ!

[១៣:៥១:២៦]

**កញ្ញា អង់តា ហ្គិសសេ៖**

ខ្ញុំសូមជំទាស់ទៅនឹងរបៀបនៃការសួរសំណួររបស់សហព្រះរាជអាជ្ញារង។ បើខ្ញុំយល់មិនច្រឡំទេ ខ្ញុំគិតថាមានចម្រូងហ្នឹង<ជាង>១លាន<ត្រូវបានគេប្រើនៅពេលនោះ>។ ខ្ញុំមិនដឹងថា តើខ្ញុំយល់ខុស ឬក៏យ៉ាងម៉េចទេ នៅពេលដែលសហព្រះរាជអាជ្ញាគាត់ដកស្រង់ចម្លើយរបស់សាក្សីរូបនោះមកនិយាយនេះ ហើយគាត់គួរតែបញ្ជាក់ផងថា តើគេដាក់ចម្រូងហ្នឹង គេដាក់នៅកន្លែងណា ដែលនិយាយថាមានចម្រូង<ជាង>១លានអីហ្នឹង ហើយសួរសាក្សីឲ្យច្បាស់ផង ថាគាត់ធ្លាប់ទៅកន្លែងហ្នឹងឬក៏អត់? ដើម្បីឲ្យគាត់ដឹងថា តើមានអន្ទាក់ ឬក៏មានចម្រូងហ្នឹង ដាក់នៅកន្លែងណាឲ្យបានច្បាស់លាស់។

**សួរដោយលោក ចូសេហ្វ អេនទ្រូ ប៊ិយលី៖**

**ស៖** ខ្ញុំនឹងកែសម្រួលប្រយោគរបស់ខ្ញុំ ដើម្បីកំណត់ត្រាតុលាការត្រឹមត្រូវ។ របាយការណ៍ដែលខ្ញុំអាននេះ គឺថាពាក់ព័ន្ធទៅនឹងការផលិតចម្រូង។ <សម្រង់ដែលខ្ញុំអាននេះ>មិន<>បាន<និយាយថា

គេ>យកទៅដាក់<នៅ>កន្លែង<ណា>នោះទេ។ គឺនិយាយអំពីការផលិតចម្រូងសម្រាប់យកទៅប្រើក្នុងតំបន់២៣។ នេះហើយជាមូលហេតុដែលខ្ញុំសួរសាក្សី ថាតើគាត់ដឹងឬអត់។ ឥឡូវនេះខ្ញុំសួរសម្រួលសំណួរឡើងវិញ ដើម្បីឱ្យស្របទៅតាមគោលដៅហ្នឹង។ ក្នុងរបាយការណ៍នេះ លោកសាក្សី ទាក់ទងទៅនឹងតំបន់២៣ ដូចខាងក្រោមនេះ៖ “យើងបានបណ្តុះលើកកម្ពស់ឱ្យមនុស្ស ឱ្យប្រជាជនផលិតចម្រូង <១.៦៣៥.៣៨០ ដើម> ដើម្បី<ប្រគល់ឱ្យសមរភូមិមុខ។” បញ្ចប់ការដកស្រង់។ ដូច្នេះរបាយការណ៍នេះហាក់ដូចជាបញ្ជាក់ថា ពួកគេបានផលិតចម្រូងទាំងនោះដើម្បីប្រគល់ជូន>សមរភូមិនៅតំបន់២៣។ ខ្ញុំចង់សួរលោកថា តើលោក<នឹកឃើញ>អំពី<ការទទួល>ចម្រូង <ឬក៏បានឮគេនិយាយអំពីចម្រូងដែលបានប្រើនៅតំបន់២៣>ដែរឬទេ?

[១៣:៥៣:៤៤]

**លោក អៀង ផាន៖**

**ឆ៖** ខ្ញុំអត់បានដឹងទេ ពីព្រោះបានជម្រាបហើយថា ខ្ញុំទៅនេះ វាមានតែការប្រយុទ្ធអាវុធនឹងអាវុធទេ ឯចម្រូងអត់មានទេ។

**ស៖** តើលោកដឹងដែរឬទេ ថាកងទ័ពខ្មែរក្រហមប្រើគ្រាប់មីន ឬក៏គ្រប់បំផ្ទុះ<ប្រឆាំងនឹងកម្លាំងវៀតណាមនៅតំបន់២៣>?

**ឆ៖** ខ្ញុំសូមជម្រាបថា គូភាគីដែលប្រយុទ្ធគ្នាមិនសំដៅតែកងទ័ពខ្មែរកម្ពុជាទេ សូម្បីតែកងទ័ពវៀតណាមក៏ប្រើមីនដូចគ្នា។ កងទ័ពកម្ពុជាក៏ប្រើមីនដូចគ្នា ព្រោះភាគីមួយៗ ដើម្បីឈ្នះ គឺប្រើគ្រប់កលល្បិច។ សូមអរគុណ។

**ស៖** លោកបានរៀបរាប់ពីខាងដើមអំពីតាក់ទិក ដែលចូលទៅពីខាងក្រោយទ័ពខ្មែរក្រហម -- វៀតណាមពីខាងក្រោយនៅតាកែវ តើលោកបានប្រើយុទ្ធសាស្ត្រ ឬក៏តាក់ទិកដូចគ្នាហ្នឹងទេ នៅពេលដែលលោកនៅតំបន់ស្វាយរៀង?

**ឆ៖** ខ្ញុំបានជម្រាបហើយថា ខ្ញុំទៅស្វាយរៀងហ្នឹងរយៈពេលខ្លីណាស់ ពាក់កណ្តាល៧៨ ទៅហើយបានតែ២ខែ ខ្ញុំត្រូវរបួស មានបានប្រើតាក់ទិកអីច្រើនប៉ុន្មានទេបាទ រយៈពេលខ្លីពេក។ ត្រូវរបួសមក ចេញពីរបួសមក វៀតណាមមកបាត់ហើយហ្នឹង មកហួសស្វាយរៀងមកដល់អ្នកលឿងបាត់ហើយ។

**ប្រធានអង្គជំនុំ៖**

ពាក់កណ្ដាល ៨៨ ឬក៏ពាក់កណ្ដាលឆ្នាំ៧៨ សាក្សី?

**លោក អៀង ផាន៖**

**ផ៖** បាទ ៧៨។

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** សូមអរគុណចំពោះការបំភ្លឺនេះ។ តើលោកបានដឹង ឬក៏លោកបានឮថា មានកងកម្លាំងផ្សេងៗទៀត<ក្រៅពីកងកម្លាំងរបស់លោក> ដែលទៅទីនោះមុនលោក <ដូចជា>កងពល៧០៣ ដែលថាតើកងទ័ពដែលមុនៗនោះបានចូលទៅដល់ទឹកដីវៀតណាម<ហើយបានធ្វើការវាយប្រហារ>?

[១៣:៥៦:៣១]

**ផ៖** ខ្ញុំបានជម្រាបហើយថា ចូលទៅទឹកដីវៀតណាមនេះ មានតែកងពល៧០៣ ដែលចូលតាមច្រកតៃនិញ ហើយមិនដល់តៃនិញទេ នៅក្នុងព្រៃនៅឡើយទេ ពីព្រោះពីព្រំដែនទៅដល់តៃនិញ ភាគច្រើនគឺព្រៃ តាមបងប្អូននិយាយនោះ។ អ៊ីចឹង៧០៣ ហ្នឹង អត់ដល់តៃនិញទេ ត្រូវវៀតណាមវ៉ៃឱ្យខ្ចាតមកវិញទៅហើយ មិនគ្រាន់ថាខ្ចាតធម្មតាទេ អស់ សឹងអស់រលីងតែម្ដងកងពលខ្លះ ពីព្រោះវៀត-ណាមមិនវ៉ៃចំមុខណ៎ា ដល់មក វាយរថក្រោះ កាំភ្លើងនៅតាមព្រំដែនហើយស្រេច ដល់ពេលដកទៅ ជាន់នឹងអ្នក ទល់មុខវ៉ៃទៅ ដល់ទៅៗជាន់ខ្សែត្រៀមវៀតណាមទាំងអស់។ ចាប់យកទាំងអស់ ស្លាប់។ សូមជម្រាបអ៊ីចឹងបាទ។

**ស៖** ខ្ញុំនឹងអានចម្លើយមួយនៅក្នុងសំណុំរឿង។ នេះគឺឯកសារ E3/376 <របស់ឈ្មោះ ឡាយអ៊ាន>គឺអង់គ្លេស 00278690 ដល់ 91, ខ្មែរ 00270173 ដល់ 74, បារាំង 00486094។ សាក្សីនោះនិយាយថា "ប្រហែលជា៧ខែ <មុន>ថ្ងៃ០៧ មករា <១៩៧៩> គឺថាគេបាន<បញ្ជាឱ្យខ្ញុំ>ប្រមូលទ័ពដើម្បីវាយវៀតណាម។ គឺថា<រាល់ប្រធានក្រុម ប្រធាន>កងវរសេនាធំ <និងប្រធានកងពលទាំងអស់គឺជាកម្មាភិបាល>មកពីភូមិភាគនិរតី។ <យើងទៅវាយប្រយុទ្ធនៅតាមផ្លូវទៅក្រែកនៅក្នុងខេត្ត>កំពង់-ចាម ហើយៗបានចូល<វៀតណាម>តាមច្រក២៧ ចូលទៅដល់តៃនិញ គឺថាក្រុមរបស់ខ្ញុំមានគ្នា២០០នាក់ <>ហើយមានឈ្មោះ ស៊ន <ជាប្រធានវរសេនាធំ> និងឈ្មោះ ញ៉ <ជាប្រធានកងពលតូច២០៧ហើយនិងតាពិន ជាប្រធានកងពលធំ។ ក្រុមរបស់ខ្ញុំ>បានចូលទៅប្រហែលជា<១៥>ទៅ២០គីឡូ ទៅក្នុងប្រទេសវៀតណាម។ <ការវាយ>ប្រយុទ្ធ<បន្តមិនតិចជាង>រយៈពេល៣ខែ<នោះទេ ហើយយើងបានទទួលបញ្ជាពី តាស៊ន ឱ្យកម្ទេច និងដុតបំផ្លាញអ្វីៗទាំងអស់ ហើយគាត់មិនបាននិយាយអំពីច្បាប់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សង្គ្រាមនោះទេ។ ក្នុងពេលពួកយើងប្រយុទ្ធនៅក្នុងប្រទេសវៀតណាម ក្រុមរបស់ខ្ញុំ និងខ្ញុំបានគប់គ្រាប់បែក> បានដុតផ្ទះ ហើយនិង<>មន្ទីរពេទ្យ<កងទ័ព>។” តើលោកនៅចាំដែរឬទេ គឺថាគេអាចនឹងចូលពី ១៥ ទៅ២០គីឡូម៉ែត្រហួសពីព្រំដែនទៅ កាលនោះ?

[១៣:៥៩:១៧]

**ឆ៖** ចំណុចនេះខ្ញុំមិនបានដឹងទេបាទ ពីព្រោះខ្ញុំទៅ ដឹងថាវៀតណាមមកផុតអស់ទៅហើយ ហើយពីមុនមក ខ្ញុំក្ដាប់អត់បានទេ។

**ស៖** ខ្ញុំចង់សួរលោកអំពីរបាយការណ៍ជាក់លាក់របស់ទីភ្នាក់ងារវៀតណាម ខែតុលា ឆ្នាំ១៩៧៨ ដែលនិយាយពីកងពលអន្តរាគមន៍របស់លោក<និងកងពលតូចលេខ៣៤០> គឺនៅរបាយការណ៍ថ្ងៃទី ១២ ខែ១០ ១៩៧៨ គឺ ឯកសារ E3/1608 គឺERN 00013179 ដល់ 80, ខ្មែរ 00810114 ដល់ 15, ហើយបារាំង 00793493 ដល់ 94។ ចំណុចនេះគាត់បាននិយាយថា សូមដកស្រង់៖ “នៅថ្ងៃទី០១ ខែតុលា កងទ័ពប៉ុល ពត, អៀង សារី <គឺកងពល២២១>បាន<បើកការវាយប្រហារទ្រង់ទ្រាយធំ ដើម្បីប៉ុនប៉ងកាន់កាប់នៅតាមបរិវេណការពារព្រំដែននៅខាង>លិច<>ស្រុកប៊ិនខារ ខេត្តតៃនិញ។ <កងវរសេនាធំមួយរបស់កម្ពុជាបានរងនូវការបាត់បង់យ៉ាងខ្លាំង។> ហើយកងទ័ពប្រហែលជា១០០នាក់ត្រូវបានសម្លាប់ ហើយអ្នកដទៃទៀតត្រូវបានចាប់ខ្លួន ហើយនិងបានអាវុធមួយចំនួន។ នៅថ្ងៃដដែលនោះកងទ័ពវៀតណាមបានវាយកម្ទេចកងទ័ពខ្មែរ<មួយវរសេនាតូច របស់កងពលធំ៣៤០> គឺថា ៣គីឡូនៅខាងលិចប៊ិនខារ <ទៅកាន់ទិសអាគ្នេយ៍> ហើយបានសម្លាប់ ហើយនិងធ្វើឲ្យរបួសកងទ័ពទាំង ស្ទើរតែ <២៥០>នាក់ជាង <ហើយនិងរឹបអូសអាវុធ៧៨ដើម>។” សូមចប់សេចក្ដីដកស្រង់។ ខ្ញុំចង់សួរលោកពីដំបូងនោះគឺថា <តើលោកនៅក្នុង>កងពលតូច២២១ <ទេ នៅខែតុលានោះ ឬក៏>លោកបាននៅមន្ទីរពេទ្យ<នៅភ្នំពេញហើយ នៅពេលនោះ>?

**ឆ៖** ខ្ញុំមកៗពេទ្យហើយ ខ្ញុំមកពេទ្យបាត់ហើយ។

[១៤:០២:០៥]

**ស៖** ទោះបីលោកនៅពេទ្យក៏ដោយ តើលោកមានស្ដាប់ឮពីកងពលតូច<អន្តរាគមន៍>របស់លោកពាក់ព័ន្ធទៅនឹងការវាយប្រយុទ្ធនៅឯតៃនិញ នៅក្នុង<ខែតុលា>ឆ្នាំ៧៨នោះដែរឬទេ?

**ឆ៖** ខ្ញុំបានដឹង មិនមែនមិនដឹងទេ គឺដឹងៗថាមានដកកម្លាំងមួយវរសេនាតូចទៅជួយកង៧០៣ ទៅជួយ មិនដឹងថាវ៉ៃចូលតៃនិញ ឬយ៉ាងណា ប៉ុន្តែដឹងតែដកកម្លាំងខ្ញុំមួយវរសេនាតូចទៅជួយកងពល

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

៧០៣ នៅទិសតៃនិញហ្នឹង។ ឯវើចូលយ៉ាងម៉េចនោះ ខ្ញុំភ្លាប់មិនច្បាស់ទេអាហ្នឹង ពីព្រោះដឹងតែៗទ័ពបាក់មកវិញអស់។

**ស៖** នៅពេលដែលលោកជាប់កំពុងតែវាយប្រយុទ្ធនោះ លោកដែលមានបានចាប់កងទ័ពវៀត-ណាមបានទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា អង្គភាពយើងខ្ញុំអត់ដែលបានចាប់ទេ បាទ អត់ដែលបានចាប់បានទេ។

**ស៖** តើលោកមានដឹងថាកងពលតូចដទៃទៀត <ចំណុះឲ្យកងពលធំរបស់លោក> ឬកងទ័ពខ្មែរក្រហម<ផ្សេងទៀត>ធ្លាប់បានចាប់វៀតណាមទេ នៅពេលប្រយុទ្ធគ្នានោះ?

**ឆ៖** តាមដែលខ្ញុំដឹងគឺថា ដូចជាមិនធ្លាប់ចាប់ទេទៅស្វាយរៀងនេះ គឺថាមានអីចាប់វៀតណាមបើកុនខ្លួនឯងរហូតហ្នឹងបាទ អត់មានចាប់គេបានទេ។ អាហ្នឹងសូមជម្រាបអ៊ីចឹង។

**ស៖** នេះគឺជាការ ឯកសារបោះពុម្ពផ្សាយដោយកម្ពុជាប្រជាធិបតេយ្យនិយាយអំពីរឿងរ៉ាវឈ្លានពានរបស់វៀតណាមមកទឹកដីកម្ពុជាគឺ E3/8403, ERN អង់គ្លេស <00749682>, ខ្មែរ <00744492>, បារាំង 00419636។ បាទឯកសារនេះគឺសរសេរដូចតទៅ សូមដកស្រង់៖ "ថ្មីៗនេះនៅថ្ងៃទី២៤ កក្កដា ឆ្នាំ១៩៧៨ វៀតណាមបានទទួលបរាជ័យយ៉ាងខ្លាំង នៅពេលដែលខ្លួនព្យាយាមបញ្ជូនកងទ័ពដើម្បីមកវាយប្រយុទ្ធកម្ពុជានៅបារិតខេត្តស្វាយរៀង។ កងទ័ពបដិវត្តន៍កម្ពុជាយើងបានវាយកម្ទេចកងវរសេនាតូចលេខ៥ <នៃ>កងពលតូចលេខ៧ របស់វៀតណាមខ្ទេចទាំងស្រុង។ <កងទ័ព និងមន្ត្រីនៅក្នុងកងអនុសេនាធំលេខ៧ នៃកងពលតូចនេះត្រូវបានសម្លាប់ទាំងអស់> មានអ្នកនៅរស់តែម្នាក់ទេគឺ <ពលបាលឯក> ង្វៀន វ៉ាន់ ឃឺ ដែលរស់រានមានជីវិត ហើយត្រូវបានកងទ័ពរបស់យើងចាប់បាននៅថ្ងៃនោះ។" លោកសាក្សីនៅថ្ងៃទី៣១ កក្កដា ៧៨ ឯកសារ E3/75, អង់គ្លេស 00168931 វិទ្យុកម្ពុជាប្រជាធិបតេយ្យបានផ្សព្វផ្សាយអំពីចម្លើយសារភាពរបស់កងទ័ពវៀតណាមរូបនេះ។ តើវាជួយរំឭកដល់ការចងចាំរបស់លោកទេដែលថា មានពេលមួយកងទ័ពវៀតណាមត្រូវបានចាប់ខ្លួនទាំងរស់ ហើយបញ្ជូនមកភ្នំពេញ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។ អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[១៤:០៦:០៦]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ខ្ញុំមានការជំទាស់មួយពាក់ព័ន្ធទៅនឹងឯកសារទី១ ដែលសហព្រះរាជអាជ្ញារងបានអានឲ្យសាក្សីស្ដាប់។ ខ្ញុំខ្លាចតែខ្ញុំយល់ច្រឡំ តែខ្ញុំជឿថា សហព្រះរាជអាជ្ញា<បង្ហាញថា>ជាឯកសារសម័យកាលកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំមិនដឹងថាត្រឹមត្រូវឬក៏អត់ទេ ការថាបែបនេះ។ គឺឯកសារខែកញ្ញា ៧៨ ពីអង្គការរបស់បារាំងមួយ <នៅ ហ្សង់ទីយី> ហៅថា គណៈកម្មាធិការអ្នកស្នេហាជាតិ<នៃកម្ពុជាប្រជាធិបតេយ្យ>នៅប្រទេសបារាំងទៅវិញនោះទេ។ <ដូច្នេះ ខ្ញុំមិនច្បាស់ទេថាតើនេះជាឯកសារផ្លូវការរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ>នោះទេ។

**សួរដោយលោក ចូសេហ្វ អេនគ្រូ ប៊ិយលីះ**

ខ្ញុំសូមដកស្រង់ឯកសារនេះចេញវិញ។

**ស៖** លោកសាក្សី តើវាជួយរំឭកដល់ការចងចាំរបស់លោកទេ ដែលថានៅពេលមួយនោះកងទ័ពវៀតណាមត្រូវបាន<ចាប់ខ្លួននៅក្នុងទឹកដី>កម្ពុជាប្រជាធិបតេយ្យ<> ហើយបញ្ជូនខ្លួនមកភ្នំពេញ?

**ឆ៖** ខ្ញុំបានជម្រាបហើយកាលនោះខ្ញុំត្រូវរបួស ខ្ញុំអត់បានគិតរឿងសមរភូមិទៀតទេ អត់បានតាមដានសមរភូមិអីទេតែធ្វើម៉េចឲ្យជាសះស្បើយតែប៉ុណ្ណឹងទេ ហើយសមរភូមិលែងដៃហើយ។

**ស៖** នៅពេលលោកចូលរួមប្រយុទ្ធនៅស្វាយរៀង តើលោកមានធ្វើរបាយការណ៍ ឬក៏ផ្ញើសារទូរលេខអំពីការវាយប្រយុទ្ធគ្នានេះដែរឬទេ? ហើយថាតើលោកមានបានផ្ញើមកឲ្យមេៗរបស់លោកទេ?

[១៤:០៧:០១]

**ឆ៖** ខ្ញុំសូមជម្រាបថាជាធម្មតារវាងមេបញ្ជាការ មេបញ្ជាការរង រឿងថ្នាក់លើនិងថ្នាក់ក្រោមជានិច្ចកាលត្រូវមានរបបរាយការណ៍ជាប្រចាំថ្ងៃអ៊ីចឹងតែម្ដង។ មួយថ្ងៃត្រូវតែរាយការណ៍ម្ដងអ៊ីចឹងតែម្ដង។ ពីសកម្មភាព ពីកម្លាំងទ័ព ពីស្បៀង ពីគ្រាប់អីគឺត្រូវតែរាយរាល់ថ្ងៃអ៊ីចឹង។

**ស៖** តើលោកមានរាយការណ៍ថាការប្រយុទ្ធនេះ វាប្រយុទ្ធដោយរបៀបណាៗដែរឬទេ? <តើលោកមានរាយ>ការណ៍<លោកវាយប្រយុទ្ធនៅកន្លែងណាដែរទេ>?

**ឆ៖** ខ្ញុំបានជម្រាបហើយថា ផែនការប្រយុទ្ធ បើយើងនិយាយថាប្រយុទ្ធគឺជាការស្លាប់រស់ អ៊ីចឹងការធ្វើផែនការ របៀបវាយ របៀបធ្វើផែនការ គឺលម្អិតណាស់ មិនអាចលីកាំភ្លើងទៅដល់បាញ់ផ្ទួសផាំងមកវិញបានទេ គឺត្រូវមានការឆ្លងហើយឯកភាពគ្នា ថាតើផែនការហ្នឹងវើបានទេ? ប្រយុទ្ធបានទេ? ទុកបានទេ? ហើយទុកបានដោយសារមូលហេតុអី? ទុកមិនបានមូលហេតុអី? បើអធិប្បាយពីរឿងផែនការវាវែងណាស់ៗបាទ ខ្ញុំគ្រាន់ថា រវាងថ្នាក់លើ ថ្នាក់ក្រោមមានរបាយការណ៍។

[១៤:០៩:៣៦]

**សៈ** ខ្ញុំសូម<អានឲ្យលោកស្តាប់នូវ>ការផ្សាយសំឡេងនៅខែតុលា ៧៨។ គឺឯកសារ E3/294 តាមរយៈវិទ្យុកម្ពុជាប្រជាធិបតេយ្យ អង់គ្លេស 00170239។ មិនមាន ERN ជាភាសាខ្មែរ ឬភាសាភាសាបារាំងទេ។ នេះអ្វីដែលវិទ្យុបានផ្សាយ សូមដកស្រង់៖ “ថ្មីៗនេះវៀតណាមបញ្ជូនទ័ពមកឈ្លានពានចូលមកក្នុងទឹកដីកម្ពុជា យើងនៅតាមព្រំដែនខេត្តស្វាយរៀង ក៏ប៉ុន្តែពួកវាត្រូវទទួលបរាជ័យយ៉ាងអាម៉ាស់មុខ។ តាមទូរលេខដែលបានរាយការណ៍ជូនពីថ្ងៃទី១៦ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ៧៨ កងទ័ពបដិវត្តន៍កម្ពុជាយើង បានសម្លាប់កងទ័ពវៀតណាម៤២២នាក់ <និងបានចាប់ខ្លួន>ជាច្រើន រឹបអូសអាវុធ <បេ៤០ ចំនួន១១ដើម, បេ៤១ ប្រាំមួយដើម, អឹម៧៩ បីដើម> អឹម៧២ <ចំនួន១២៨ដើម, កាំភ្លើងត្បាល់៦០មិល្លីម៉ែត្រ បីដើម, ដេកា៨២ មួយដើម, ដេកា៧៥>បីដើម, អាវុធ១២.៨មិល្លីម៉ែត្រ <ប្រាំដើម, អឹម៦០ ប្រាំពីរដើម និងអឹម៣០ ប្រាំបីដើម>។ល។ តើ<ព័ត៌មាន>លម្អិត<បែបនេះ> លោក<មាន>រាយការណ៍នៅក្នុងរបាយការណ៍<ទេ នៅពេលដែលលោកបានចូល>ប្រយុទ្ធ<នោះ? តើលោកមានពន្យល់លម្អិតអំពីប្រភេទអាវុធ>ដែល<លោក>រឹបអូសបាន<ទេ>?

**ឆៈ** ខ្ញុំសូមជម្រាបថា ខ្ញុំបានជម្រាបខាងដើមថា មិនមែនមានតែកងពលខ្ញុំមួយទេ គឺមានដលតែប្រាំកងពល។ អ៊ីចឹងមុខសញ្ញារបស់ខ្ញុំ ជាកងអន្តរាគមន៍។ ពេលកន្លែងណាមានអាសន្នបានខ្ញុំទៅ។ ឯការរាយការណ៍របស់កងពលផ្សេងៗទៀត ខ្ញុំក្តាប់អត់បានទេហ្នឹងបាទ រាយៗទៅថ្នាក់លើតែម្តង ត្រង់តែម្តង មិនមែនរាយមកខ្ញុំឯណា ព្រោះខ្ញុំជាប្រធានកងពលមួយ ហើយកងពលដែលមិនទៅប្រយុទ្ធផ្ទាល់ផង ដល់មានអាសន្នអី បានគេអញ្ជើញទៅ បានអន្តរាគមន៍ទៅ។ អ៊ីចឹងឯការរាយការណ៍អី ស្តាប់ របួសអី ទៅថ្នាក់លើ ខ្ញុំម៉េចបានដឹង។ ខ្ញុំសូមជម្រាប បាទ។ ខ្ញុំអត់បានដឹងទេ។

[១៤:១២:១៤]

**សៈ** តើលោកមានបានត្រឡប់ទៅស្វាយរៀងវិញដែរឬទេ នៅក្រោយពេលលោកសម្រាកនៅមន្ទីរពេទ្យនៅភ្នំពេញ មុនខែធ្នូ ៧៨? ឬក៏ថា នៅពេលណាក៏ដោយ មុនពេលវៀតណាមចូលមកឈ្លានពានជាលើកចុងក្រោយនេះ<នៅចុងខែធ្នូ ១៩៧៨> តើលោកមានបានត្រឡប់ទៅស្វាយរៀងវិញទេ?

**ឆៈ** ខ្ញុំអត់បានទៅដល់ស្វាយរៀងទេ បាទ។ ខ្ញុំទៅជួបទ័ពនៅព្រៃវែងតែម្តង បាទ កាត់ពីណាទៅ ទៅជួបទ័ព ដកចេញពីស្វាយរៀងទាំងអស់នៅព្រៃវែង។ ហើយបានធ្វើដំណើរពីព្រៃវែងមក មកវាលតាំងគោកបណ្តោយ បាទ ឆ្លងទន្លេសាប មកខាងនេះមក អត់បានទៅស្វាយរៀងវិញទេ បាទ។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សៈ** តើលោកនៅចាំកាលបរិច្ឆេទទេ នៅពេលដែលលោកទៅជួបទ័ពរបស់លោកនៅព្រៃវែងហ្នឹង?

[១៤:១៣:១២]

**ឆៈ** ខ្ញុំទៅជួបហ្នឹងគឺថា៧៩ហើយ ថ្ងៃ០១អីហ្នឹង ថ្ងៃ០១ ខែ០១ ៧៩ហើយ ឬក៏ថ្ងៃ០៥ផង តាមខ្ញុំមើល ពីព្រោះខ្ញុំមកដល់ផ្លូវលេខ៥យើង សាលាលេខ៥នេះ នៅថ្ងៃ១២ ថ្ងៃ១២ ៧៩។ ខ្ញុំធ្វើដំណើរពីរដណ្ដប់ថ្ងៃពីព្រៃវែងមកជាមួយទ័ព ដើរកាត់មកតែម្ដង។ ហ្នឹងអត់មានកម្លាំងនៅប្រយុទ្ធស្វាយរៀងទៀតទេ ដកមកហើយ។ វៀតណាមមកដល់ភ្នំពេញបាត់ហើយ ហើយខ្ញុំធ្វើដំណើរកាត់ទន្លេមេគង្គមក កាត់ទន្លេសាបមក មកសាលាលេខ៥ ផ្លូវលេខ៥នេះតែម្ដង។

**សៈ** សូមអរគុណ។ នៅពេលដែលលោកផ្ដល់សក្ខីកម្មពីលើកមុន លោកបានឆ្លើយជាច្រើន អំពីដំណើរការនៃការសរសេរប្រវត្តិរូប នៅពេលដែលលោកស្ថិតនៅក្នុងជួរកងទ័ពខ្មែរក្រហម។ លោកបានរៀបរាប់អំពីដំណើរការនៃការសរសេរប្រវត្តិរូប <ហើយមានគេទៅតាមដានព័ត៌មានលម្អិតរបស់លោកនៅតាម>ភូមិ។ <ហើយបន្ទាប់មកគេឃ្លាំមើល>ហើយក្នុងនោះ លោកក៏និយាយ<អំពីបុគ្គលមួយចំនួននៅក្នុងអង្គភាពរបស់លោក> ត្រូវបានគេនាំខ្លួនយកចេញទៅបាត់ទៅ នៅពេលដែលពួកគេរកឃើញថាមានជាប់ទាក់ទងជាមួយនឹងមន្ត្រីរដ្ឋការ លន់ នល់។ ខ្ញុំសូមយោងជារួមតែម្ដង គឺនៅម៉ោង ១១:១៣:៥៤ និងម៉ោង ១១:១៧។ ខ្ញុំសូមសួរបញ្ជាក់ចំណុចពីរ។ ទី១ សូមយកសម្រង់ដែលលោកឆ្លើយផ្ទាល់តែម្ដង គឺ E1/193.1 នៅម៉ោង ១០:០០:៥៦វិនាទី នេះអ្វីដែលលោកបានឆ្លើយ៖ “នៅក្នុងការអនុវត្តជាធម្មតា ក្នុងជួរកងទ័ពខ្មែរក្រហម ជាពិសេសក្នុងឆ្នាំ១៩៧៦ និង ៧៧ វាមានដំណើរការចម្រាញ់ប្រវត្តិរូបអ្នកដែលមានសាច់ញាតិ មានបុណ្យស័ក្តិខ្ពង់ខ្ពស់ក្នុងរបបលន់ នល់ នឹងត្រូវគេដកចេញ ហើយគេត្រូវបញ្ជូនមកខាងក្រោយឲ្យមកចិញ្ចឹមមាន់ទាជ្រូក<ឲ្យបំបែកថ្ម ឬក៏ដាំកប្បាសជាដើម>។ នេះគឺជាអ្វីដែលគេធ្វើយ៉ាងដូច្នេះឯង។ ក្នុងចំណោមជួរកងទ័ពហ្នឹង មានករណីតែពីរបីតែប៉ុណ្ណោះឧទាហរណ៍នៅក្នុងអង្គភាពរបស់ខ្ញុំ មានតែពីរបីករណីតែប៉ុណ្ណោះ បើខ្ញុំនឹកមិនច្រឡំទេ មិនមានអ្វីកើតឡើងដល់អ្នកទាំងអស់នោះទេ។” បញ្ចប់ការដកស្រង់។

តើធ្វើម៉េចបានជាលោកដឹងថាបុគ្គលមួយចំនួននោះ នៅក្នុងកងរបស់លោកត្រូវបានគេហៅចេញទៅបាត់ដោយសារតែអ្នកទាំងអស់នោះ ជាប់ពាក់ព័ន្ធទៅនឹងមន្ទីររដ្ឋការដែលមានបុណ្យស័ក្តិខ្ពង់ខ្ពស់ក្នុងរបបលន់ នល់?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៤:១៧:១០]

**ធ៖** ចំណុចនេះ ខ្ញុំមិនបដិសេធទេ គឺគាំទ្រចំណុចនេះទាំងស្រុង។ ដោយសារថានៅក្នុងអង្គភាពយើងខ្ញុំ ឲ្យតែមានបងប្អូនទាក់ទងនឹងទាហានលន់ នល់ ដែលមានបណ្ដាស័ក្តិធំៗ គឺថាគេដកទៅចិញ្ចឹមសត្វៗ ដាំដំណាំ បាទ។ មិនៗយកទៅសម្លាប់ទេ គ្រាន់តែដកចេញពីកងយោធា ឲ្យទៅដាំដំណាំ ឬចិញ្ចឹមសត្វតែប៉ុណ្ណោះបាទ។ ចំណុចនេះមាន ក្នុងកងពលខ្ញុំបាទ គឺមានអ៊ីចឹងមែន។

**ស៖** សំណួររបស់ខ្ញុំសួរថា ហេតុអ្វីបានជាដឹងថាគេដកអ្នកទាំងអស់ហ្នឹងទៅឲ្យចិញ្ចឹមសត្វ ដាំដំណាំ <ឬក៏វាយបំបែកថ្ម ដូចដែលលោកបាននិយាយ>ហ្នឹង? តើលោកបានទទួលព័ត៌មាននេះពីណាមកដែរ? លោកបានឃើញអ្នកទាំងនោះ គេដកចេញពីកងទ័ពទៅៗឲ្យធ្វើកិច្ចទាំងអស់នេះ ឬក៏លោកទទួលព័ត៌មានពីខាងណា?

**ធ៖** ចំណុចនេះ គឺថានៅក្នុងកងទ័ព គឺថាមានអ្នកស៊ើបអង្កេត អ៊ីចឹងតែម្ដងបាទ។ ស៊ើបអង្កេតចេញពីប្រភពណា ខ្ញុំមិនដឹងទេ ប៉ុន្តែការស៊ើបរបស់គេហ្នឹង គឺច្បាស់ៗអ៊ីចឹងតែម្ដង។ បើមិនច្បាស់គេអត់ដកទេបាទ មិនមែនចេះតែដកប្រថុយប្រថានទេ។ តាមខ្ញុំដឹង គឺថាគេពិនិត្យច្បាស់លាស់ណាស់ បានគេដកបាទ។ មុននឹងដក គេជូនដំណឹងមកមេទ័ព ថាអ្នកនេះត្រូវឲ្យទៅនេះ ថ្ងៃប៉ុណ្ណោះបញ្ចេញ ហើយក្នុងអង្គភាពខ្ញុំក៏មិនច្រើនដែរ មិនៗមានចំនួនច្រើនប៉ុន្មានទេ ប៉ុន្តែមានការដកហូតអ៊ីចឹង។

[១៤:១៩:០៤]

**ស៖** បើខ្ញុំយល់មិនច្រឡំទេ គឺថាគេមានអ្នកស៊ើបអង្កេត ហើយអ្នកស៊ើបអង្កេតហ្នឹងបានប្រាប់មកលោកថា អ្នកហ្នឹងគេចាត់តាំងទៅឲ្យធ្វើការដូចដែលលោករៀបរាប់អំមិញអ៊ីចឹង។ អ៊ីចឹងឬ?

**ធ៖** ពិតជាអ៊ីចឹង។

**ស៖** ចុះលោកដែលឃើញអ្នកទាំងអស់នុ៎ង ត្រឡប់ចូលមកក្នុងអង្គភាពរបស់លោក ឬក៏ថាត្រឡប់ចូលធ្វើជាទ័ពនៅក្នុងអង្គភាពផ្សេងទៀតទេ ក្រោយពីដកចេញពីទ័ពទៅឲ្យធ្វើ ទៅឲ្យចិញ្ចឹមមាន់ទា ស្រែចម្ការនេះ?

**ធ៖** ខ្ញុំសូមជម្រាបថា ការពិនិត្យនិងដកហូតនេះតាំងពីឆ្នាំ៧៦ ដើម ឆ្នាំ៧៧។ ប៉ុន្តែដល់វៀតណាមវ៉ៃចូលមក គឺថាអ្នកទាំងអស់គ្នាហ្នឹងគឺមកយោធាវិញទាំងអស់ ចូលមកយោធាវិញទាំងអស់ អត់មានគិតរឿងមុនទៀតទេ។ ហ្នឹងអង្គភាពខ្ញុំឃើញមកវិញទាំងអស់ ថ្នាក់លើឲ្យមកវិញទាំងអស់។ អ្នកណាតំណែងអី មកកាន់តំណែងហ្នឹងវិញមក ដើម្បីយកកម្លាំងនេះទប់ទល់ជាមួយវៀតណាម។

[១៤:២០:២៧]

**ស៖** សំណួរមួយចុងក្រោយពាក់ព័ន្ធនឹងអ្វីដែលលោកបានផ្ដល់សក្ខីកម្មកាលពីលើកមុននោះ គឺនៅម៉ោង១០:០៧:១០វិនាទី។ នេះគឺអ្វីដែលលោកបានឆ្លើយ លោកសាក្សី៖ "ជាទូទៅ នៅក្នុងកម្លាំងកងទ័ពនេះ ប្រជាជនគេអាចនិយាយ -- គេនិយាយគ្នាពីមាត់មួយអំពីការចម្រាញ់ អំពីការដកហូតអ្នកណាម្នាក់ ប៉ុន្តែមិនមានការណែនាំ<ជាផ្លូវការ>ដល់មេបញ្ជាការឱ្យដំណើរការបែបនេះទេ ដូចជាខ្លួនខ្ញុំក្ដី គេមិនដែលប្រាប់ខ្ញុំឱ្យធ្វើបែបដូច្នេះទេ។ ហើយនៅក្នុងកងខ្ញុំ បើគេ<ដក>មនុស្សចេញក៏គេមិនប្រាប់ខ្ញុំដែរ។ គឺថា<អាច>មានការណែនាំពីថ្នាក់លើមក គឺថ្នាក់លើជាអ្នកបញ្ជាមកឱ្យដកយ៉ាងដូច្នេះឯង។ សួរ៖ តើអ្នកដឹងថាអ្នកណាជាអ្នកមកដកកម្លាំងចេញពី<កងវរសេនាតូច>របស់លោកហ្នឹង <ហើយពួកគេមកពីណាដែរ>? ឆ្លើយ៖ គេអាចមកពីថ្នាក់<កងពល ឬ>ថ្នាក់ភូមិ<>ហើយពេលគេមកដល់ គេថាចង់អញ្ជើញបុគ្គលរូបនេះ <ឬបុគ្គលនោះ> គឺថាដោយសារថ្នាក់លើនេះ គឺថាអញ្ជើញបុគ្គលរូបនេះឱ្យទៅ។ ខ្ញុំគ្មានអ្វីនិយាយរឿងនេះទៀតទេ ម្នាក់ៗខ្លាចណាស់ ខ្ញុំផ្ទាល់ក៏ភ័យខ្លាចដែរ ជាពិសេសចន្លោះពីឆ្នាំ១៩៧៦ ដល់៧៨។ ទោះបីជាអ្នកនោះជាយុទ្ធជនធម្មតា ជាមេបញ្ជាការក៏ដោយ ម្នាក់ៗគឺថាខ្លាច ភ័យខ្លាចណាស់ ស្ថានភាពគឺវាយ៉ាងដូច្នេះឯង។" បញ្ចប់ការដកស្រង់។ តើត្រឹមត្រូវដែរឬទេ ថាក្នុងអំឡុងពេលនោះ លោកមានការភ័យខ្លាចនោះ?

**ឆ៖** ត្រឹមត្រូវ។

**ស៖** <តើលោកខ្លាចអ្វីនៅ>ចន្លោះពីឆ្នាំ<៧៦> ដល់ទៅដល់ ៧៨ <ដែលលោកនិយាយ>ថាម្នាក់ៗខ្លាច<ខ្លាចនោះ>? តើលោកខ្លាចពីរឿងអ្វី?

[១៤:២២:៣២]

**ឆ៖** ខ្លាចសំខាន់គឺគឺការចោទប្រកាន់ជាប់និន្នាការនយោបាយជាមួយទាហាន លន់ នល់។ ខ្លាចណាស់អាហ្នឹង ព្រោះខ្ញុំៗសម្ដែងការស្មោះត្រង់ ខ្ញុំក៏មានមាក្ដីខ្ញុំធ្វើទាហាន នៅខាងលន់ នល់ ធ្វើទាហានក៏មាន ធ្វើប៉ូលិសក៏មាន ធ្វើពេទ្យក៏មាន ហ្នឹងហើយ។ អ៊ីចឹងចេះតែមានការព្រួយបារម្ភដែរ ធ្វើមេមែនប៉ុន្តែមានការព្រួយបារម្ភដែរ។ ប៉ុន្តែការព្រួយបារម្ភ មិនមែនៗបង្ហាញឥរិយាបថឱ្យអ្នកផ្សេងដឹងទេ គឺថាគ្រាន់តែទុកក្នុងចិត្តរបស់ខ្លួន – ទុកក្នុងចិត្តរបស់ខ្លួនទេ។

**ស៖** ចុះបើគេរកឃើញថាសាច់ញាតិរបស់លោក ដែលរៀបរាប់ហ្នឹងអាចថាជាទាហានលន់ នល់ ជាអ្នករដ្ឋការលន់ នល់ ហ្នឹង តើលោកភ័យខ្លាចយ៉ាងម៉េចដែរ ភ័យខ្លាចថាមានអ្វីកើតឡើងចំពោះ

លោក?

**ឆ៖** ខ្ញុំយល់ឃើញថាមានការព្រួយបារម្ភ មានការភ័យខ្លាច ប៉ុន្តែខ្ញុំអាចយល់បានថា ពេលនោះគេយកតែទាហាន លន់ នល់ ដែលមានបណ្ដាស័ក្តិធំៗ ឯមាក្តើខ្ញុំសុទ្ធតែពលទាហាន នាយទាហាន កូនទាហាន មិនៗនេះទេ គ្រាន់តែមានការព្រួយបារម្ភអីចឹង។ គេយកនេះ គេយកតែអ្នកដែលមានបណ្ដាស័ក្តិធំៗ ដូចជាថ្នាក់ឧត្តមសេនីយ៍ ឬវរសេនីយ៍ឯង ឬមេទ័ពធំៗទេ បើថាអ្នកល្មមៗ អត់ទេបាទ។

[១៤:២៤:១៨]

**ស៖** ចុះអ្នកដែលមានការជាប់ពាក់ព័ន្ធ ជាប់សាច់ឈាមជាមួយនឹងអ្នកដែលមានបណ្ដាស័ក្តិនៅក្នុងរបប លន់ នល់ ហ្នឹង តើពួកគាត់ហ្នឹងព្រួយបារម្ភយ៉ាងដូចម្ដេចដែរ?

**ឆ៖** គាត់ព្រួយបារម្ភ ប៉ុន្តែគេដកទៅ គេអត់សម្លាប់អី គេគ្រាន់តែយកទៅដាក់ឱ្យចិញ្ចឹមសត្វ អីចឹងទៅ គាត់មានជីវភាពអីធូរធារ ក៏គាត់បំភ្លេចរឿងហ្នឹងជាបណ្ដើរៗទៅ។ គ្រាន់តែគេមិនឱ្យកាន់អាវុធតែប៉ុណ្ណឹងទេ។

**ស៖** តើលោកនិយាយថា ពួកគេទាំងអស់ហ្នឹងមានការភ័យខ្លាច លោកភ័យខ្លាច ម្នាក់<ៗ>ភ័យខ្លាច ពីព្រោះដោយសារតែខ្លាចគេយកទៅឱ្យចិញ្ចឹមសត្វ។ អីចឹងមែនទេ?

**ឆ៖** ខ្ញុំចង់និយាយថា ការព្រួយបារម្ភនេះ ឱ្យតែមានបងប្អូនធ្វើទាហានលន់ នល់ ហើយទាហានលន់ នល់ នេះខ្ញុំចង់បញ្ជាក់និងសង្កត់ថា អ្នកដែលមានបណ្ដាស័ក្តិធំៗ អីចឹងគេដកហើយ បើបណ្ដាស័ក្តិទាបហ្នឹង គេអត់ដកទេ គេទុកនៅក្នុងទាហានដដែល។ សូមជម្រាបអីចឹងបាទ។

**លោក ចូសេហ្វ អេនត្រូ ប៊ិយលើ៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអរគុណលោកសាក្សី ហើយខាងសហមេធាវីនាំមុខក៏បានប្រាប់មកខ្ញុំវិញដែរ ថាពួកគាត់ៗមិនមានសំណួរអ្វីដែរ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយតទៅនេះ ផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តី។ ដំបូងនេះ ផ្តល់វេទិកាជូនទៅមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក វិចទ័រ កូប៉េ៖**

**ស៖** សូមអរគុណលោកប្រធាន។

[១៤:២៦:៣៥]

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** សូមជម្រាបសួរលោកសាក្សី ខ្ញុំនឹងសួរសំណួរលោកមួយចំនួនក្នុងនាមកូនក្ដីរបស់ខ្ញុំឈ្មោះ នួន ជា។ ឥឡូវនេះ យើងចាប់ផ្ដើមដោយសំណួរមួយចំនួនជាសំណួរទូទៅដែលថារូបលោក និងជាបឋម ចង់សួរថា តើលោកស្គាល់មនុស្សម្នាក់ឈ្មោះ ឈូក រីន ដែរឬទេ?

**លោក អៀង ផាន៖**

**ឆ៖** ឈូក រីនៗ នៅកំពត។

**ស៖** បាទ អ៊ីចឹងមែន។ តើគាត់សមាជិកម្នាក់នៅកងពល៧០៣ តើមែនទេ?

**ឆ៖** បាទ មិនមែនទេ ឈូក រីន មិនមែន៧០៣ ទេ គឺ ឈូក រីន នៅខាងកំពត នៅខាង៤០៥ ឯណោះវិញ ៧០៣ អត់មាន។

**ស៖** ប្រហែលជាលោកត្រូវហើយ គាត់ខ្លួនឯង គាត់និយាយថាគេបញ្ចូលគាត់ទៅកងពល៧០៣ ប៉ុន្តែមិនសំខាន់ទេ លោកដឹងច្បាស់ជាង។ ឥឡូវនេះ ខ្ញុំសូមប្រាប់លោកថា ហេតុអីបានខ្ញុំសួរពីបញ្ហានេះ ថាលោកស្គាល់គាត់នោះ។ គាត់និយាយរឿងខ្លះអំពីលោកដែលខ្ញុំចង់សួរលោកឲ្យលោកបញ្ជាក់។

លោកប្រធានឯកសារ E3/361 ជាកំណត់ហេតុលោក ឈូក រីន គឺឯកសារ 00766452, បារាំង 00268884, ខ្មែរ 00194466។ នេះជាអ្វីដែលគាត់និយាយអំពីលោក៖ "អៀង ផាន ដែលគាត់នៅរស់ទេបច្ចុប្បន្ននេះ គាត់មានឋានន្តរសក្តិជាឧត្តមសេនីយ៍ផ្កាយ១ នៅយោធភូមិភាគ៥ បាត់ដំបង"។ គាត់និយាយរឿងនេះក្នុងឆ្នាំ២០០៨ គឺក្នុងរយៈ៨ឆ្នាំកន្លងមកហើយ។ តើលោកជាឧត្តមសេនីយ៍ដែលថាមានផ្កាយ១ តើលោកនៅមានឋានន្តរសក្តិនេះដដែលទេ?

**ឆ៖** ខ្ញុំអត់នៅដដែលទេ ឥឡូវនេះខ្ញុំឧត្តមសេនីយ៍ទោ ផ្កាយ២ មេបញ្ជាការរងភូមិភាគ៥។

[១៤:២៩:៥៥]

**ស៖** សូមលោកប្រាប់ខ្ញុំ នៅពេល<ណា>ដែលលោកបានធ្វើជាឧត្តមសេនីយ៍នៅក្នុងកងយោធពលខេមរភូមិន្ទនោះ បាទ ដែលថាឋានន្តរសក្តិជាផ្កាយ២នោះ?

**ឆ៖** ចង់ៗបញ្ជាក់សំណួរឡើងវិញ។

**ស៖** បាទ សំណួរ ខ្ញុំសួរខុសពីហ្នឹងបន្តិច។ តើត្រឹមត្រូវដែរឬទេនៅពេល ប្រហែលជានៅក្នុងឆ្នាំ ១៩៩៧ ដែលលោកហើយនិងលោក មាស មុត ត្រូវបានគេធ្វើសមាហរណកម្មចូលមកក្នុងកងទ័ពនៃរាជ

រដ្ឋាភិបាលកម្ពុជា?

**ឆ៖** ពិត។

**ស៖** ហើយនៅពេលដែលលោកហើយនិងកងទ័ពរបស់លោកត្រូវបានធ្វើសមាហរណកម្មនោះ មកក្នុងៗកងយោធពលខេមរភូមិន្ទនោះ តើលោកនៅមានឋានន្តរសក្តិជា<ឧត្តមសេនីយ៍ត្រី ឬក៏>ឧត្តមសេនីយ៍ទោ <ដែរ>?

**ឆ៖** ខ្ញុំសូមជម្រាបថា ខ្ញុំចូលរួមជាមួយរដ្ឋាភិបាលជាដំបូងត្រូវបានតែងតាំងដោយព្រះមហាក្សត្រ គឺថ្នាក់ឧត្តមសេនីយ៍ត្រីផ្កាយ១ ហើយបំពេញភារកិច្ចជាបន្តបន្ទាប់រហូតមកដល់សព្វថ្ងៃនេះបានឡើងមួយផ្កាយទៀត គឺផ្កាយ២ ឧត្តមសេនីយ៍ទោបាទ។

[១៤:៣១:០១]

**ស៖** តើលោកដឹងដែរឬទេថា តើ មាស មុត គាត់បានទទួលងារអ្វីស្រដៀងរូបលោកដែរទេនៅពេលដែល មាស មុត ក៏គាត់បានធ្វើសមាហរណកម្មទៅក្នុងកងយោធពលខេមរភូមិន្ទដែរនោះ?

**ឆ៖** បង មាស មុត គាត់ទទួលឋានន្តរសិក្តគឺថា ឧត្តមសេនីយ៍ទោ ហើយជាទីប្រឹក្សារបស់ក្រសួងការពារជាតិ។

**ស៖** សំណួរចុងក្រោយនៅក្នុងបរិបទនេះលោកសាក្សី។ នៅពេលដែលលោកត្រូវបានធ្វើសមាហរណកម្មចូលទៅកងយោធពលខេមរភូមិន្ទនោះ។ តើលោកបានទទួលដំណឹងដែរឬទេថា ខ្លួនលោកនឹងមិនត្រូវទទួលរងការចោទប្រកាន់អំពីអ្វីៗដែលលោកបានធ្វើនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ?

**ឆ៖** ខ្ញុំបានទទួលថាមិនមានការចោទប្រកាន់មកលើរូបខ្ញុំបាទ។

**ស៖** សូមអរគុណដែលលោកបានបំភ្លឺ លោកសាក្សី។ សំណួរបន្ទាប់មករបស់ខ្ញុំនោះ គឺនិយាយអំពីអនុមេបញ្ជាការរបស់លោកឈ្មោះ សុខ ឈៀន ហើយគាត់ក៏បានផ្តល់សម្ភាស សក្ខីកម្មទៅដល់អ្នកស៊ើបអង្កេតរបស់តុលាការនេះដែរ។ តើលោកដឹងឬទេថា គាត់នៅរស់ដែរឬទេរាល់ថ្ងៃនេះ?

**ឆ៖** សព្វថ្ងៃគាត់នៅរស់។

**ស៖** តើគាត់ក៏ជាសមាជិករបស់កងយោធពលខេមរភូមិន្ទដែរឬទេ?

**ឆ៖** សព្វថ្ងៃគាត់ជានាយសេនាធិការរងកងទ័ពជើងគោក ថ្នាក់ឧត្តមសេនីយ៍ទោ។

**ស៖** ដូចដែលខ្ញុំបញ្ជាក់ គឺគាត់បានឆ្លើយទៅអ្នកស៊ើបអង្កេតគឺ ឯកសារ E3/428, អង់គ្លេស ERN 007-- សូមកែតម្រូវ <00374949>, <ជាភាសាខ្មែរ 00373484> និង<ភាសាបារាំង>

01377053



00485476។ <ខ្ញុំសូម>អានសំណួរនិងចម្លើយរបស់គាត់<ជូន>លោកស្តាប់។ "តើស្ថានភាពអ្វីដែលលោកបានឃើញថា កើតឡើងពាក់ព័ន្ធទៅនឹងកម្មាភិបាលភូមិភាគបូព៌ាទាំងយោធា និងប្រជាជននៅពេលដែលលោកទៅដល់។ គឺទៅដល់ក្នុងពាក់កណ្តាលឆ្នាំ១៩៧៨? គាត់បានឆ្លើយថា៖ នៅពេលដែលខ្ញុំទៅដល់ខេត្តស្វាយរៀង ខ្ញុំមិនបានឃើញមានប្រជាជននៅទីនោះសូម្បីតែមួយនាក់ឡើយ គឺឃើញតែកងទ័ពដែលមកពីនិរតី ហើយកងទ័ពដែលមាននៅបូព៌ាស្រាប់នោះ គឺដូចជាកងពលលេខ៨៨៥ ជាដើម។ ចំណែកនៅតំបន់ប្រសូត្រកងទ័ពវៀតណាម បានចូលមកកាន់កាប់ហើយ ហើយជាតំបន់សមរភូមិប្រយុទ្ធគ្នាយ៉ាងខ្លាំង។ នៅពេលដែលខ្ញុំទៅដល់ទីនោះ ខ្ញុំបានឮដំណឹងពីក្នុងចំណោមទ័ព<ថា> កងទ័ព<>ភូមិភាគបូព៌ារបស់ សោ ភឹម បានក្បត់ ហើយនាំកម្លាំងចូលរួមជាមួយកងវៀតណាម<>។ ឈ្មោះ រ៉ែន បានប្រកាសប្រាប់នៅពេលប្រជុំថា សោ ភឹម <និង>កម្លាំងនៅភូមិភាគ<បូព៌ា>មួយចំនួនបានចូលរួមជាមួយវៀតណាម ដើម្បីវាយរំលំខ្មែរក្រហម។" បញ្ចប់សេចក្តីដកស្រង់។ តើលោកសាក្សីសក្ខីកម្មរបស់ សុខ <ឈៀន> ជាអនុបញ្ញាការរបស់លោកនេះ តើខ្លឹមសារដែលគាត់បញ្ជាក់នេះ ត្រឹមត្រូវដែរឬទេ? បាទ របស់ សុខ ឈៀន។

[១៤:៣៦:៤៣]

**ឆ៖** ចំណុចមួយចំនួន គឺត្រឹមត្រូវបាទ។

**ស៖** តើលោកអាចជម្រាបអង្គជំនុំជម្រះ ថាតើចំណុចណាខ្លះត្រឹមត្រូវ? អ្វីដែលខ្ញុំអានជូនលោកស្តាប់ខាងដើមនោះ?

**ឆ៖** ខ្ញុំបានជម្រាបខាងដើមមុនហើយថា ពេលដែល រ៉ែន ប្រជុំ គឺគាត់បាននិយាយ។ គាត់បាននិយាយពីរឿងភូមិភាគបូព៌ា អ្នកនេះក្បត់ៗអីហ្នឹង គ្រាន់តែខ្ញុំមិនបានលម្អិតទេ ប៉ុន្តែគាត់បាននិយាយ តាមដែលខ្លឹមសារដូចលោក ឈៀន បានរាយការណ៍បាទ។

**ស៖** សូមអរគុណដែលលោកបានបំភ្លឺ។ ប៉ុន្តែអ្វីដែលខ្ញុំចាប់អារម្មណ៍ខ្លាំងនោះ គឺ<នៅពេល>ដែលគាត់និយាយថា <អ្វីដែល>គាត់បានឮ<អំពី> សោ ភឹម <គឺថា>គាត់ដឹងដំណឹងនេះពីចំណោមពួកកងទ័ព។ តើនេះជាអ្វីដែលៗ កងទ័ពរបស់លោកបានដឹង តើព័ត៌មានទាំងនោះបានដឹងទៅដល់កងទ័ពយ៉ាងដូចម្តេច ព័ត៌មានអំពី សោ ភឹមនោះបាទ?

**ឆ៖** ខ្ញុំសូមជម្រាបថា នៅក្នុងខេត្តស្វាយរៀង ហើយអតីតកងពលរបស់លោក សោ ភឹម ដែលគាត់ភូមិបូព៌ាមុននោះ ដូចជាកងពល៨០៥ ដែលលោកអានអម្បាញ់មិញ គឺជាអតីតរបស់កងពលនៅបូព៌ា

ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ស្រាប់ហើយ។ អ៊ីចឹង ដំណឹងទាំងអស់នេះ គឺថាយុទ្ធជនតែងតែនិយាយ ប៉ុន្តែសម្រាប់ខ្ញុំ ខ្ញុំមិនដែលចាត់ទុកជាផ្លូវការទេ ព្រោះចេះតែឮតែនិយាយតៗគ្នាអ៊ីចឹង បានខ្ញុំមិនសូវចាប់អារម្មណ៍ប៉ុន្មានបាទ។ នេះសូមជម្រាបអ៊ីចឹង គឺដឹងតាមរយៈកងពលអតីតដែលនៅនឹងស្រាប់។

**ស៖** ហើយគាត់ក៏បាននិយាយផងដែរថា សោ ភឹម បានចូលរួមកម្លាំងជាមួយវៀតណាម។ តើលោកអាចបញ្ជាក់បានដែរឬទេ ថាតើគាត់និយាយបែបនេះមានន័យដូចម្ដេច ដែលគាត់និយាយថា សោ ភឹម បានចូលដៃរួមកម្លាំងជាមួយវៀតណាម? ថាតើ<គាត់ធ្វើរឿងនេះនៅពេលណាដែរ? តើគាត់>ធ្វើការងារហ្នឹងដោយរបៀបណា? <តើលោកដឹងរឿងនេះដែរឬទេ>?

[១៤:៣៩:៤២]

**ឆ៖** ខ្ញុំសូមជម្រាបថា ចំណុចនេះខ្ញុំមិនច្បាស់ដែរ គាត់ក្លាប់បានពីប្រភពណា ខ្ញុំ -- គ្រាន់តែខ្ញុំជាមេ ខ្ញុំៗមិនច្បាស់លាស់ដែរចំណុចហ្នឹងបាទ។ អត់ច្បាស់ទេ អត់ច្បាស់ ខ្ញុំមិនហ៊ាននិយាយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណលោកសាក្សី ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីសូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់មកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងបី។

បាទ សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤០ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:១៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្ដល់វេទិកាជូនទៅសហមេធាវីការពារក្ដី នួន ជា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរសាជាថ្មីលោកសាក្សី។ មុនពេលយើងឈប់សម្រាកនេះ យើងនិយាយគ្នាអំពី សោ ភឹម ហើយយោងទៅតាមអនុ<មេ>បញ្ជាការរបស់លោក គឺថា សោ ភឹម នេះគឺគាត់ធ្វើការជាមួយនឹងកងកម្លាំងវៀតណាម។ ខ្ញុំដឹងថាវាយូរយារមកហើយ ក៏ប៉ុន្តែសូមលោកគិតត្រឡប់ទៅពេលនោះតាមការចងចាំរបស់លោក ថាអំពើក្បត់របស់ សោ ភឹម ហ្នឹងមានអំពើអ្វីខ្លះដែរ លោកដឹងទេ បើសិនលោកដឹង សូមជួយរៀបរាប់ផង?

[១៥:០២:៣៦]

**លោក អៀង ផាន៖**

**ផ៖** ខ្ញុំសូមជម្រាបថា ខ្ញុំអត់បានដឹងទេបាទ។

**ស៖** ខ្ញុំសូមអាននូវអ្វីដែល ឈូក រីន បានឆ្លើយប្រាប់មន្ត្រីស៊ើបអង្កេត គឺ E3/362, ERN អង់គ្លេស 00268898, ខ្មែរ 00210213, បារាំង 00268906។ នេះគឺជាអ្វីដែល ឈូក រីន បានឆ្លើយ សូមដកស្រង់៖ "តាម យោងតាមបទពិសោធន៍របស់ខ្ញុំ ឧទាហរណ៍ អ្នកភូមិភាគបូព៌ាដូចជា សោ ភឹម គឺជាខ្មាំងបង្កប់។ ទោះគាត់ជា<មនុស្សរបស់>បក្សកុម្មុយកម្ពុជាក៏ដោយ គាត់មានទំនាក់ទំនងជាមួយវៀតណាម ហើយកម្មាភិបាលដទៃទៀតនៅបូព៌ា មាន ហេង សំរិន, ជា ស៊ីម, ហ៊ុន សែន ជាដើម។ បើពួកគាត់មិនរត់គេចខ្លួនទេ ថាពួកគាត់ក៏ត្រូវបានចាប់ខ្លួនដែរ។" បញ្ចប់ការដកស្រង់។ តើចំណុចនេះវាជួយរំឭកដល់ការចងចាំរបស់លោកបានខ្លះទេ?

**ផ៖** ចំណុចនេះ ខ្ញុំយល់ឃើញថា ខ្ញុំមិនយល់ កន្លងមកខ្ញុំមិនយល់ដល់បញ្ហានេះទេបាទ។ អត់យល់ដល់ថាអ្នកនេះក្បត់ អ្នកនោះក្បត់អី អត់ៗដឹងតែម្តងនិយាយរួម។ ឯលោក ឈូក រីន ហើយណា គេដឹងពីណា ខ្ញុំមិនបានដឹងទេបាទ។

[១៥:០៤:៣៧]

**ស៖** អាចប្រហែលជាដោយសារការចងចាំក៏ថាបាន ប៉ុន្តែខ្ញុំមានការភ្ញាក់ផ្អើលដែរ នៅពេលដែលស្តាប់ឮសួរចម្លើយរបស់លោក ពីព្រោះនៅក្នុងខែសីហា ឆ្នាំ៧៨ គឺប្រមាណជា<១ខែ ឬក៏>២ខែក្រោយពេលលោកទៅដល់ស្វាយរៀង សារព័ត៌មានបស្ចិមប្រទេសបានរាយការណ៍<រួចហើយ>ថា សោ ភឹម ជាមេដឹកនាំចលនាតស៊ូប្រឆាំងនឹង ប៉ុល ពត នៅក្នុងប្រទេសកម្ពុជា។ អ៊ីចឹងបើសិនណាជាសារព័ត៌មានបស្ចិមប្រទេស<បាន>ដឹង<រួចហើយ> ហើយចុះផ្សាយនៅខែសីហា ៧៨នោះ ហេតុអីក៏

លោកមិនដឹង?

**ឆ៖** ខ្ញុំសូមជម្រាបថា ចំណុចនេះខ្ញុំមិនបានតាមដានសារព័ត៌មាននេះទេ ព្រោះវីវក់រឿងកម្លាំង ទ័ព រឿងប្រយុទ្ធអីហ្នឹងទៅ អត់សូវបានយល់ពីសភាពការណ៍ខាងក្រៅយ៉ាងណានោះទេបាទ។

**ស៖** បាទ ដើម្បីប្រតិចារឹក លោកប្រធានខ្ញុំយោងទៅឯកសារសៀវភៅរបស់ ណាយាន់ ចាន់ដា <E3/2376>, ERN អង់គ្លេស 00192626, ខ្មែរ 00191793 មិនមានការបកប្រែជាភាសាបារាំងនៅឡើយទេចំពោះឯកសារនេះ។ បាទ ខ្ញុំសូមអាន សូមដកស្រង់៖ “យោងទៅតាមព័ត៌មានដែលផ្តល់ដោយទីក្រុងហាណូយទៅឲ្យអ្នកការទូតមកពីប្រទេសទី៣ ខ្ញុំបាន<រាយការណ៍នៅថ្ងៃទី១១> ខែសីហា ៧៨ នៅក្នុងកាសែត *“ហ្វារ <អ៊ីសស្ទើន> អេកូណូមិច រីវ្យូ”* ដែលថា សោ ភឹម ដឹកនាំកម្លាំងចលនាតស៊ូប្រឆាំងនឹង ប៉ុល ពត នៅក្នុង<ប្រទេសកម្ពុជា>។ សំណួរចុងក្រោយពាក់ព័ន្ធទៅនឹងប្រធានបទដដែលនេះ ក៏ប៉ុន្តែសួរពាក់ព័ន្ធទៅនឹងមនុស្សផ្សេងទៀតទេ។ តើលោកធ្លាប់ឮអំពីមេបញ្ជាការម្នាក់ទៀតមកពីភូមិភាគបូព៌ាឈ្មោះ ចាន់ ចក្រី ដែរឬទេ?

[១៥:០៦:៥៩]

**ឆ៖** ខ្ញុំធ្លាប់ឮឈ្មោះ ប៉ុនអត់ៗបានស្គាល់មុខអីទេឮតែឈ្មោះ។ សោ ភឹម ក៏ឮតែឈ្មោះ, ចាន់ ចក្រី ក៏ឮតែឈ្មោះអត់ដែលៗជួបមុខ ជួបឃើញអីទេ។

**ស៖** ចុះ<តើលោកបានឮអ្វីខ្លះ?> តើលោកដឹងអ្វីខ្លះអំពី ចាន់ ចក្រី នេះ?

**ឆ៖** ចំពោះ ចាន់ ចក្រី នេះ ឈ្មោះគ្រាន់តែឮឈ្មោះ មុខអត់ដែលស្គាល់អត់បានដឹងរឿងប្រវត្តិរបស់ ចាន់ ចក្រី នោះទេខ្ញុំ។

**ស៖** តើលោកដឹងថាគាត់ចូលរួមពាក់ព័ន្ធនៅក្នុងការ<ផ្តួលរលំរបប>កម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ឆ៖** ខ្ញុំមិនបានដឹង ដូចខ្ញុំជម្រាបអ៊ីចឹងថា ឮតែឈ្មោះ ហើយក៏មិនដឹងថាគេរៀបផែនការយ៉ាងណានោះអត់បានដឹងទេខ្ញុំបាទ។

**ស៖** បាទ ដើម្បីយល់ឲ្យបានពេញលេញខ្ញុំសូមអាននូវចម្លើយរបស់ ឈូក រីន ដែលគាត់បានឆ្លើយប្រាប់មន្ត្រីស៊ើបអង្កេតគឺ ឯកសារ E3/361, ERN អង់គ្លេស 00766455, ខ្មែរ 00194470, បារាំង 00268887៖“នៅក្នុងឆ្នាំ១៩៧៦ <>កងពល២៨០, ២៩០ ដែលដឹកនាំដោយ ចាន់ ចក្រី គឺថាប៉ុនប៉ងធ្វើរដ្ឋប្រហារទម្លាក់ ប៉ុល ពត ប៉ុន្តែមិនបានជោគជ័យ ហើយ<ចាន់ ចក្រី> ត្រូវបានចាប់ខ្លួន<ដោយ

កម្លាំងរបស់ប៉ុល ពត កងពល៧០៣>។" តើសម្ដី របស់ ឈូក រីន ដែលនិយាយពាក់ព័ន្ធទៅនឹង ចាន់ចក្រី នេះតើវាជួយឲ្យលោកនឹកឃើញទេ?

[១៥:០៩:០៩]

**ឆ៖** ខ្ញុំនៅតែមិនយល់ ពីព្រោះខ្ញុំអត់បានយល់ស្ថានការណ៍ហ្នឹងផង។ បាទ មិនដឹងគាត់ថាបានដំណឹងហ្នឹងពីណា អ្នកណាអ្នកណែនាំអប់រំអី ខ្ញុំអត់បានដឹងទេបាទ។

**ស៖** មិនថ្វីទេលោកសាក្សី។ បាទ មួយសំណួរទៀតពាក់ព័ន្ធទៅនឹងប្រធានបទដដែលនេះ តើហេតុអ្វីបានជា ឈូក រីន ដឹងបញ្ហានេះ ឯលោកអត់បានដឹង ដោយសារថានៅក្នុងជួរកងទ័ពហ្នឹងលោកក៏មានឋានៈខ្ពស់ជាងគាត់ផង?

**ឆ៖** ខ្ញុំសូមជម្រាបថា ពិតមែនតែខ្ញុំឋានៈខ្ពស់ជាង ប៉ុន្តែការដើរហើរ ខ្ញុំដូចជាជើងខ្លីជាងគាត់ ដល់គាត់ដើរច្រើនជាងខ្ញុំ គាត់ដឹងរឿងច្រើន។ ឯការណែនាំពីខាងលើអី ខ្ញុំអត់ដែលបានទទួលការណែនាំសោះបាទ ខ្ញុំបានតែៗទទួលការណែនាំមក ខ្ញុំបានជ្រួតជ្រាប។ តែឯលោក ឈូក រីន គាត់បានដឹងដំណឹងនេះពីណាខ្ញុំមិនយល់ដែរ ប៉ុន្តែសម្រាប់ខ្ញុំៗមិនៗដឹងតែម្ដង មិនយល់តែម្ដង។

**ស៖** សំណួរខាងដើមដែលខ្ញុំសួរថា តើលោកស្គាល់ ឈូក រីន ទេ? លោកថា ស្គាល់។ នៅពេលលោកឈរជើងនៅស្វាយរៀងនៅពាក់កណ្ដាលឆ្នាំ៧៨ តើ ឈូក រីន មានឋានន្តរសក្តិប៉ុនណាដែរនៅពេលនុ៎ង?

**ឆ៖** ខ្ញុំសូមជម្រាបថា លោក ឈូក រីន នេះអត់មានមកស្វាយរៀងទេ គាត់នៅភ្នំវល្លិ៍ កំពត។ គាត់ឋានៈជាប្រធានវរសេនាធំរបស់កងពល៤០៥ សំ ប៊ិត ក្រោយនេះ។ ៤០៥ សំ ប៊ិត រៀបដែលវៀតណាមចូលហើយនេះ។ ឯមកស្វាយរៀងនេះក៏គាត់មានមកទេ ហើយគាត់ទទួលការណែនាំពីណានោះ ខ្ញុំមិនៗបានជ្រាបទេបាទ។

[១៥:១១:៥០]

**ស៖** តើ ឈូក រីន មានវត្តមាននៅក្នុងអង្គប្រជុំមួយដែលលោកបានចូលរួម គឺអង្គប្រជុំនៅផ្ទះតាម៉ុក នៅឯតាកែវ <នៅ>ពាក់កណ្ដាលឆ្នាំ១៩៧៧ ឈូក រីន មានវត្តមាននៅទីនោះដែរឬទេ?

**ឆ៖** ចំណុចនេះខ្ញុំក្ដាប់អត់ជុំដែរ ពីព្រោះ ឈូក រីន ឋានៈជាវរសេនាធំ ឯការអញ្ជើញមកប្រជុំគឺអញ្ជើញតែកងពល ពេលនោះគាត់មកឬមិនមក ខ្ញុំក្ដាប់អត់ជុំដែរចំណុចនេះ។

**ស៖** ខ្ញុំសូមសួរ<បញ្ជាក់>ពាក់ព័ន្ធទៅនឹងអ្វីដែល<លោកបាននិយាយអំពី ឈូក រីន ថា>តើ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ឈ្មោក រីន មានទៅស្វាយរៀង <ឬក៏អត់ទេ, ទៅ ឬ មិនទៅ>។ គឺឯកសារ E3/361, ERN ជាភាសាអង់គ្លេស 00766451, ខ្មែរ 00194466, បារាំង 00268883។ សូមដកស្រង់៖ “នៅឆ្នាំ៧៧ គេបញ្ជូនខ្ញុំទៅស្វាយរៀង ហើយគេដាក់បញ្ចូលខ្ញុំទៅកងពល៧០៣ ចំណុះឲ្យអគ្គសេនាធិការ<របស់មជ្ឈិម> ហើយ<បានក្លាយទៅជាមេ>បញ្ជា<កងវរសេនាធំ>៤០២។ <កងពល៧០៣ បានឈរជើងនៅខេត្តស្វាយរៀង ហើយ>វរសេនាធំ៤០១ ឈរជើងនៅភ្នំពេញនៅសាលាបឹងត្របែក”។ តើវាអាចដែរទេថា ឈ្មោក រីន នេះ<នៅ>ស្វាយរៀងនៅឆ្នាំ១៩៧៧ មិនមែន ១៩៧៨ ទេ?

**ឆ៖** ខ្ញុំនៅមិនច្បាស់ថា ឈ្មោក រីន ហ្នឹងគាត់ចេញពីប្រភពណានេះ ខ្ញុំអត់ទាន់ច្បាស់ បើពួដល់ទៅស្វាយរៀងនេះ ខ្ញុំគើតជាឆ្លល់ថា គាត់ទៅកងពល៧០៣ នៅបូព៌ានេះគឺថា ខ្ញុំមិនច្បាស់ត្រង់ហ្នឹងដែរ ព្រោះវាមិនដឹងថា ឈ្មោក រីន ណាមួយទេ។ ព្រោះ ឈ្មោក រីន កំពត នៅឯកំពតនេះទេ ឯ ឈ្មោក រីន មកនេះខ្ញុំមិនច្បាស់។ ឬគាត់ឡើងឋានៈអីអ្នក ឈ្មោក១ រីន ផ្សេងហើយគាត់ឡើងឋានៈផ្សេង ខ្ញុំក្តាប់មិនបានអាហ្នឹង។ បើ ឈ្មោក រីន ដែលខ្ញុំស្គាល់គឺស្គាល់ ឈ្មោក រីន នៅកំពត ភ្នំវល្លិ៍។ ឈ្មោក រីន ភ្នំវល្លិ៍ អាហ្នឹងបានខ្ញុំស្គាល់ ឯ ឈ្មោក រីន ដែលលោកមានយោបល់អម្បាញ់មិញនេះគឺថា ខ្ញុំមិនទាន់ច្បាស់ចំណុចនេះទេបាទ មិនថា ឈ្មោក រីន នៅភ្នំវល្លិ៍ ឬ ឈ្មោក រីន ណាផ្សេង ខ្ញុំមិនច្បាស់ត្រង់ហ្នឹង។

[១៥:១៤:៥៦]

**ស៖** ថាតើ ឈ្មោក រីន នេះលោកឆ្លើយនឹងសំណួរខ្ញុំថាស្គាល់ហ្នឹង តើ ឈ្មោក រីន ដែលកំពុងទទួលរងទោសគុក សព្វថ្ងៃនេះអត់ទេ?

**ឆ៖** បាទ ឈ្មោក រីន ដែលខ្ញុំស្គាល់នេះ ឈ្មោក រីន ដែលសាលាក្តីអញ្ជើញមកដែរ។ លោក ឈ្មោក រីន ភ្នំវល្លិ៍ហ្នឹង ហើយតាមមើលដូចជាប់គុករហូតដល់សព្វថ្ងៃនេះ។ ខ្ញុំស្គាល់តែ ឈ្មោក រីន ហ្នឹងទេ។ ឯឈ្មោក រីន លោកមានយោបល់អំមិញ ដូចខ្ញុំមិនស្គាល់បាទ។

**ស៖** គ្មានអ្វីដែលសង្ស័យទេ យើងកំពុងនិយាយ ឈ្មោក រីន តែមួយហើយ។ ខ្ញុំសូមចូលទៅប្រធានបទមួយទៀត។ សក្ខីកម្មរបស់លោកនៅខែឧសភា ឆ្នាំ២០១៣ ថ្ងៃទី<២០> គេបានសួរលោកអំពីការប្រយុទ្ធគ្នាជាមួយនឹងកងទ័ព លន់ នល់ មុនខែមេសា ឆ្នាំ៧៥ ហើយនៅម៉ោង ១១:០៩ <នៅព្រឹក> ថ្ងៃទី<២០> ឧសភា ២០១៣ លោកនិយាយអំពី<វិធានអន្តរជាតិស្តីអំពីឈ្លើយសឹក ដែលបានប្រើប្រាស់ម្តង>ពាក់ព័ន្ធទៅនឹងកងទ័ពលន់ នល់ <នៅពេល>ដែលកម្លាំងរបស់លោកបានចាប់ខ្លួន។ ច្បាប់ស្តីអំពីឈ្លើយសឹកជាសកលនេះ គឺថាក្រោយឆ្នាំ១៩៧៥មក ពាក់ព័ន្ធទៅនឹងកងទ័ពវៀតណាម វិញម្តង គឺកង

01377059



ទ័ពវៀតណាមដែលចាប់ខ្លួនបាន គេធ្វើយ៉ាងដូចម្ដេចដែរ គេអនុវត្តនូវវិធានឈ្លើយសឹកក្នុងសង្គ្រាមលក្ខណៈអន្តរជាតិអីចេះទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា ចំពោះច្បាប់សង្គ្រាម ហើយនៅក្នុងសង្គ្រាម ក៏អនុវត្តនយោបាយឈ្លើយសឹកដែរ ពិតមែនតែនៅក្នុងព្រៃ ប៉ុន្តែមានការអប់រំដែរ បាទ។ អីចឹងការប្រយុទ្ធជាមួយទាហាន លន់ នល់ ជំនាន់នោះ ក៏មានចាប់បានដែរ ប៉ុន្តែអត់សម្លាប់ទេ គេមានកន្លែងបញ្ជូនទៅអប់រំបាទ ហើយកន្លែងណានោះ ខ្ញុំមិនច្បាស់ទេអាហ្នឹង ព្រោះធម្មតាអ្នកមុខ តែបញ្ជូនទៅក្រោយហើយ រឿងអ្នកក្រោយ។ ឯជាមួយវៀតណាមក៏ធ្លាប់ចាប់វៀតណាមបានដែរ ប៉ុន្តែមិនមែនកងពលរបស់ខ្ញុំទេ កងពលផ្សេងមក ចាប់មកបញ្ជូន។ បញ្ជូនទៅក៏មានកន្លែងអប់រំដែរ រហូតដល់មានភាពនយោបាយឈ្នះៗហ្នឹង ក៏លែងតាមរយៈទៅថៃ នៅសំឡូតហ្នឹង គឺបញ្ជូនទៅថៃច្រើនដែរ បាទ តាមបងម៉េត។ គាត់អ្នកមើលរឿងហ្នឹងបាទ។ បញ្ជូនទៅតាមរយៈថៃហ្នឹងច្រើនដែរ អត់សម្លាប់ទេ។ អាហ្នឹងចុងក្រោយនេះ គឺមិនមានឃើញសម្លាប់ទេបាទ។

[១៥:១៨:៣២]

**ស៖** ក៏ប៉ុន្តែវិធានអន្តរជាតិស្ដីអំពីឈ្លើយសឹក<ដែលលោកនិយាយ>នេះ ពាក់ព័ន្ធទៅនឹងការចាប់ខ្លួនទាហាន លន់ នល់ តើវិធាននេះ ជាវិធានដដែលតែមួយ ឬដែលកងទ័ពរបស់លោកត្រូវអនុវត្តទៅលើកងទ័ពវៀតណាម <ម្ដងនៅពេល>ដែលបានចាប់ខ្លួននោះណា គឺវិធានច្បាប់អន្តរជាតិស្ដីអំពីឈ្លើយសឹកហ្នឹង អនុវត្តដូចគ្នាទាំងទាហាន លន់ នល់ ទាំងវៀតណាម <>ដែលចាប់ខ្លួនទុំងដែរឬទេ?

**ឆ៖** ដូចគ្នា មិនមានការប៉ះទង្គិចរាងកាយអីទេ បាទ។

**ស៖** សូមអរគុណលោកសាក្សី។ នៅថ្ងៃនេះ ក៏ដូចជានៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោក លោកថាអង្គភាពរបស់លោកមិនដែលចាប់បានកងទ័ពវៀតណាមណាម្នាក់ទេ ប៉ុន្តែអង្គភាពផ្សេងអាចធ្លាប់ចាប់កងទ័ពវៀតណាមបាន។ នៅក្នុងឯកសារ E3/419 សំណួរ-ចម្លើយលេខ៧ លោកបានឆ្លើយថាកងទ័ពរបស់លោក<ជាច្រើន>ត្រូវបានសម្លាប់និងចាប់ខ្លួនដោយកងទ័ពវៀតណាម<>។ តើលោកដឹងទេ មានអ្វីកើតឡើង នៅពេលដែលកងទ័ពវៀតណាមចាប់បានកងទ័ពកម្ពុជាប្រជាធិបតេយ្យ តើខាងវៀតណាមនោះ គេធ្វើយ៉ាងដូចម្ដេចដែរមកលើកងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលគេចាប់ខ្លួនបាននោះ?

**ឆ៖** ចំណុចនេះ ខ្ញុំមិនបានយល់ថានយោបាយរបស់វៀតណាមយ៉ាងណានោះទេបាទ ព្រោះពេលដែលវៀតណាមចាប់ទៅ អត់ដែលឃើញមកវិញផង ពិសេសអង្គភាពកងពលខ្ញុំ បាត់ខ្លួនអីហ្នឹង គឺ

ថាបាត់រហូត។ អ្នកស្លាប់ឃើញស្លាប់ ប៉ុនអ្នកដែលបាត់ខ្លួន គឺបាត់រហូត មិនដឹងថាវៀតណាមចាប់ ឬក៏ស្លាប់នៅកន្លែងណាផ្សេងទៀត ប៉ុន្តែអត់ៗដឹងថានយោបាយខាងវៀតណាមយ៉ាងណានោះទេ ខ្ញុំក្លាប់មិនបានទេ។

[១៥:២១:០០]

**ស៖** តើធ្វើម៉េចបានលោកដឹងថា វៀតណាមបានចាប់កងទ័ពកម្ពុជាប្រជាធិបតេយ្យបានមួយចំនួនដែរ? តើលោកដឹងៗ លោកបានព័ត៌មាននេះមកពីណា?

**ឆ៖** ដឹងតាមរយៈប្រជាជនវៀតណាម ដែលកងទ័ពកម្ពុជាយើងស្តាប់តាមវិទ្យុតេអូហ្នឹង ហ្នឹងហើយ គេនិយាយឆ្លើយឆ្លងទៅ យើងស្តាប់បានថា កងទ័ពវៀតណាមហ្នឹងចាប់កងទ័ពកម្ពុជាបានប៉ុណ្ណេះៗ មិនមែនតាមរយៈព័ត៌មានទេ គឺតាមតេអូដែលសមរភូមិប្រយុទ្ធគ្នាបាទ។ ប្រយុទ្ធគ្នា គេនិយាយត្រង់ៗអ៊ីចឹងតែម្តង។

**ស៖** តើធ្វើដូចម្តេច ទើបលោកដឹងថាកងទ័ពនេះ ដែលត្រូវបានកងទ័ពវៀតណាមចាប់ខ្លួនហ្នឹងមិនដែលបានត្រឡប់មកវិញ?

**ឆ៖** ពីព្រោះជាក់ស្តែងមិនឃើញតែម្តង មិនឃើញរហូតដល់ថ្ងៃហ្នឹង អត់ដែលឃើញបានមកវិញផង។

**ស៖** តើលោកដឹងថា អ្នកដែលគេ អ្នកដែលត្រូវកងទ័ពវៀណាមចាប់ខ្លួនបានទាំងអស់ហ្នឹង ត្រូវបានគេសម្លាប់ចោទទាំងអស់តែម្តង ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំមិនយល់ថាសម្លាប់ ឬមិនសម្លាប់ទេ ប៉ុន្តែជាក់ស្តែងមិនឃើញវិលវិញ។ រឿងសម្លាប់ ឬមិនសម្លាប់ ខ្ញុំអត់ហ៊ានថា ប៉ុន្តែជាក់ស្តែង មិនឃើញវិលវិញ បាទ មិនឃើញវិលវិញ។

[១៥:២២:៥៥]

**ស៖** ខ្ញុំបានសួរលោកម្តងហើយ ឥឡូវខ្ញុំសូមសួរម្តងទៀត។ អ្វីដែលអ្នកជំនាញបានមកសរសេរនៅសៀវភៅរបស់គាត់ គឺឯកសារ E3/9, អង់គ្លេស 00396585។ ខ្ញុំមាន ERN ជាភាសាខ្មែរ បារាំងដែរ ប៉ុន្តែសុំការអនុញ្ញាតនឹងផ្តល់ជូនឆាប់ៗនេះលោកប្រធាន។

នេះគឺអ្វីដែលគាត់សរសេរនៅក្នុងសៀវភៅរបស់គាត់ ERN ជាភាសាអង់គ្លេស 00396585 គឺទំព័រ៣៧៧ នៅក្នុងសៀវភៅរបស់គាត់នេះ សូមដកស្រង់៖ “នៅពាក់កណ្តាលខែធ្នូ ឆ្នាំ១៩៧៧ កងទ័ពវៀតណាម ៥០.០០០នាក់ ដែលអមដោយរទេះតង់ ហើយនិងកាំភ្លើងធំបានឆ្លងកាត់ព្រំដែន នៅជួរ

សមរភូមិមុខ <លាតសន្ធឹង>ជាង១០០ម៉ាយល៍ <ចាប់ពី>ស្វាយរៀង នៅចំពុះទា<ទៅដល់ស្ទួលនៅខាងជើង>។ នៅសប្តាហ៍ទី១ គឺថាពួកគេថាមានការប្រយុទ្ធតិចតួចទេ ប៉ុន្តែបានចូលមកក្នុងបូរណភាពនៃកម្ពុជារហូតដល់១២ម៉ាយល៍។ ហើយកងទ័ពខ្មែរក្រហម<ដែលបានធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់ពួកគេ>នោះ ក៏ត្រូវបានសម្លាប់ជាប្រព័ន្ធតែម្តង។" តើលោកអាចបញ្ជាក់អះអាងបានទេត្រង់ចំណុចនេះដែលថា កងទ័ពកម្ពុជាប្រជាធិបតេយ្យដែលធ្លាក់ទៅក្នុងដៃរបស់កងទ័ពវៀតណាមហ្នឹង គឺត្រូវបានសម្លាប់ចោលជាប្រព័ន្ធតែម្តង សម្លាប់ខ្ទេចតែម្តង។ តើលោកមានដឹងរឿងនេះទេ?

**ឆ៖** បើនិយាយពីស្វាយរៀង ដូចខ្ញុំបានជម្រាបសំណួរខាងដើមមុនហ្នឹង គឺថាខ្ញុំទៅពាក់កណ្តាលឆ្នាំ១៩៧៨ហើយ។ អ៊ីចឹងហេតុការណ៍នេះកើតពីឆ្នាំ៧៧ ចុងឆ្នាំ៧៧ អ៊ីចឹងយើងខ្ញុំក្តាប់មិនបានទេ។ សូមជម្រាបអ៊ីចឹង ក្តាប់អត់បានទេ ពីព្រោះអង្គភាពកងពលក្នុងហ្នឹងវាច្រើនហើយ ឯការហ៊ុមព័ទ្ធវ៉ៃយ៉ាងណានោះ ខ្ញុំក្តាប់មិនជុំទេបាទ។

[១៥:២៥:៤៨]

**ស៖** មិនថ្វីទេលោកសាក្សី។ នៅពេលដែលលោកឈរជើងនៅស្វាយរៀងនៅពាក់កណ្តាលឆ្នាំ៧៨ និងនៅពេលដែលលោកវាយប្រយុទ្ធជាហូរហែជាមួយកងទ័ពវៀតណាម តើលោកមានបានចូលរួមប្រយុទ្ធ មិនមែនប្រយុទ្ធជាមួយកងទ័ពវៀតណាមទេ ក៏ប៉ុន្តែប្រយុទ្ធជាមួយគេហៅថាខ្មែរតស៊ូ ឬក៏កម្លាំងបះបោរដែលចេញមកពីខាងបូព៌ានេះតែម្តង គឺកងទ័ពខ្មែរចេញពីបូព៌ា <ដែលជួយ>កងទ័ពវៀតណាមហ្នឹង តើលោកផ្ទាល់មានបានប្រយុទ្ធជាមួយកងទ័ពខ្មែរបះបោរនេះទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា ពេលដែលខ្ញុំទៅនេះ ភាគច្រើនគឺឃើញតែវៀតណាម វ៉ៃទៅវ៉ៃមកឃើញតែវៀតណាម ពីព្រោះយ៉ាងម៉េចបើខ្មែរបះបោរដែលទៅរួមជាមួយវៀតណាមក៏ពាក់មួកកូប ឯវៀតណាមក៏ពាក់មួកកូប អ៊ីចឹងវៀតណាមតែទាំងអស់ហ្នឹង មានបានណាបែងចែកអ្នកខ្មែរ អ្នកវៀតណាមណាបាទអត់បានបែងចែកទេ។ បាទ អ៊ីចឹងប្រយុទ្ធជាមួយវៀតណាមទាំងអស់។ បាទ សូមជម្រាបអ៊ីចឹង។

**ស៖** សូមអរគុណ។ ឃើញថាចម្លើយនេះអាចទទួលយកបាន។ លោកសាក្សី តើលោកមានបានដឹងអំពីជំរំសម្ងាត់នៅក្នុងទឹកដីវៀតណាមខាងត្បូង ដែលគេ កន្លែងដែលគេចាប់ផ្តើមបណ្តុះបណ្តាលកម្លាំងខ្មែរហ្នឹងដើម្បីឲ្យចាប់ផ្តើមសង្គ្រាមទ័ពព្រៃនេះ លោកមានដឹងដែរ ដឹងថានៅទីនោះមានជំរំមួយមានកន្លែងហ្វឹកហាត់សម្ងាត់មួយនៅវៀតណាមខាងត្បូង?

**ឆ៖** ខ្ញុំសូមជម្រាបថា ខ្ញុំអត់បានៗបានដឹងទេលោកប្រធាន។ ព្រោះចំណុចនេះសុទ្ធតែចំណុច

លាក់ការណ៍។

[១៥:២៨:២៨]

**ស៖** តើលោកមានន័យថានៅពេលនោះ លោកមិនបានដឹងដោយសារតែថា កន្លែងហ្វឹកហ្វឺននេះ ឬក៏ជំរំហ្វឹកហ្វឺននេះ គឺថាជាកន្លែងសម្ងាត់?

**ឆ៖** ពិតមែនហើយបាទ។

**ស៖** តើលោកដឹងរឿងនេះក្រោយ<មកទេ គឺប្រហែលជាក្រោយ>ឆ្នាំ១៩៧៩ហើយទេ? <តើមានអ្វីដែល>លោកដឹង<អំពី>ទាហាន<កម្ពុជា> ដែលឈរជើង<នៅជំរំសម្ងាត់ នៅវៀតណាមខាងត្បូង ដែល>ជួយ<>ដល់កម្លាំងវៀតណាមដែលមកប្រយុទ្ធជាមួយកម្លាំងរបស់លោកនោះ<ដែរឬទេ?> អ៊ីចឹងលោកដឹងរឿងនេះក្រោយ៧៩ហើយទេ ឬក៏យ៉ាងណា?

**ឆ៖** សម្រាប់ខ្ញុំវិញ ដឹងក្រោយ៧៩ហើយបាទ។ ហើយពិសេសដឹងវៀតណាមចូលដល់ភ្នំពេញហើយ បានដឹងថាមានទ័ពខ្មែរបាទ។

**ស៖** តើលោកដឹងអំពីរឿងនេះក្រោយមកហ្នឹងដឹងពីអ្វីខ្លះដែរ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា ចំណុចដែលខ្ញុំដឹងនេះគ្រាន់ថា នៅក្នុងកងទ័ពវៀតណាមហ្នឹងមានកងទ័ពខ្មែរដែលបានហ្វឹកហ្វឺននៅវៀតណាម ហើយភាគច្រើនដែលរត់ចេញពីបូព៌ា ហើយដែលដឹងច្បាស់លាស់ហ្នឹងគឺពេលសមាហរណកម្មហើយទេបាទ។ សមាហរណកម្មហើយ មិត្តភក្តិដែលហ្វឹកហ្វឺននៅវៀត-ណាមហ្នឹងពាក់ផ្កាយ១ ផ្កាយ២ ត្រូវជាមិត្តភក្តិហ្នឹងបាននិយាយរឿងរ៉ាវដែលទៅហ្វឹកហ្វឺននៅវៀតណាមប្រាប់ បាទអាហ្នឹងបានដឹងការពិតកាន់តែច្បាស់ ឯពីមុនមកដឹងមិនច្បាស់លាស់ទេ បាទ សូមជម្រាប។

[១៥:៣០:៣៣]

**ស៖** តើពួកគាត់ប្រាប់លោកពីពេលវេលាដែលពួកគាត់ចេញទៅប្រទេសវៀតណាមដែរឬទេ ដើម្បីទទួលការបណ្តុះបណ្តាលនៅជំរំយោធានោះ? ឬក៏ថាមុនពេលដែលលោកគេ គេបញ្ជូនលោកទៅស្វាយរៀង <នៅពាក់កណ្តាលឆ្នាំ៧៨> ឬក៏ក្រោយពេលដែលគេបញ្ជូនលោកទៅស្វាយរៀង តើពួកគេបានបញ្ជាក់ពីពេលវេលាដែលថាពួកគាត់ទៅទីនោះដែរឬទេ?

**ឆ៖** បង១ខ្លះ គាត់បញ្ជាក់ប្រាប់ខ្ញុំថា គាត់ទៅតាំងពីដើមឆ្នាំ៧៨អីនោះ អ្នកខ្លះពាក់កណ្តាល៧៨ ប៉ុន្តែភាគច្រើនដើមឆ្នាំ៧៨តែម្តង ចុង៧៧ ដើម៧៨ ហើយសុទ្ធតែមេទ័ពរាល់ថ្ងៃហ្នឹង។

**សៈ** តាមពិតគឺអ៊ីចឹងមែនលោកសាក្សី សូមអរគុណ។ តើលោកនៅចាំដែរឬទេនៅពេលដែលលោកនៅខេត្តស្វាយរៀងនៅពាក់កណ្ដាលឆ្នាំ១៩៧៨ តើលោកបានឮការផ្សាយតាមវិទ្យុ តាមវិទ្យុជាភាសាខ្មែរ ដែលៗជាសំឡេងរបស់<អតីតខ្មែរក្រហម> ឬក៏<អតីតមេបញ្ជាការ>នៅភូមិភាគបូព៌ា ដើម្បីអំពាវនាវឲ្យមនុស្សងើបតស៊ូឡើង បះបោរ?

**ឆៈ** ខ្ញុំសូមជម្រាបថា សម្រាប់ខ្ញុំវិញអត់បានតាមដានរឿងវិទ្យុអីទេ ព្រោះយ៉ាងម៉េចបាននិយាយអ៊ីចឹង គឺថា១ថ្ងៃៗគឺថារវល់រក់តែពីរឿងរៀបចំកម្លាំងទប់ខាងឆ្វេង ទប់ខាងស្ដាំ។ រៀបចំកម្លាំងរឿងគ្រាប់រំសេវ ដល់អ៊ីចឹងទៅអត់បានតាមដានវិទ្យុអីទេ សូមជម្រាបដោយត្រង់អ៊ីចឹង។

[១៥:៣២:៤៦]

**សៈ** ខ្ញុំយល់ ប៉ុន្តែលោកបានឮពីរឿងហ្នឹងទេ? ជាពិសេសគឺថា តើសំឡេងមនុស្ស កម្មាភិបាល <ខ្មែរតាមវិទ្យុ ដែល>យើងជឿជាក់ថាបានស្ដាប់ហើយ ហើយគាត់បានគេចាក់ផ្សាយតាម វ៉ាដ្យូថា និយាយពីបញ្ហាបះបោរហ្នឹង<ដែរឬទេ? តើនេះគឺជាអ្វីដែលលោកអាច>បានឮ ឬក៏<លោកមិនបានស្ដាប់ឮផ្ទាល់ខ្លួនលោកទេ ក៏ប៉ុន្តែលោកត្រូវបានគេប្រាប់ព័ត៌មាននេះ ក្នុងនាមលោកជាមេបញ្ជាការមួយរូប>?

**ឆៈ** ខ្ញុំសូមជម្រាបថា ឮដែរ ប៉ុន្តែមិនបានចាប់អារម្មណ៍ទេបាទ អត់សូវចាប់អារម្មណ៍ប៉ុន្មានទេ ចាប់អារម្មណ៍តែវៀតណាមចូល ដល់រឿងខ្មែរបះបោរអីអត់សូវចាប់អារម្មណ៍ ខ្ញុំសូមជម្រាបត្រង់អ៊ីចឹងតែម្ដងបាទ។

**សៈ** *(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

កុំអាលៗទាន់ មានបញ្ហាបកប្រែភាសា។ មានបញ្ហាបកប្រែភាសាហ្នឹង ភាសាអត់មានទេ។

បាទ ចាប់ផ្ដើមសាជាថ្មីម្ដងទៀតលោកមេធាវី វ៉ិចទ័រ កូប៉េ។

[១៥:៣៤:២៥]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**សៈ** បាទ លោកប្រធាន។ ខ្ញុំអានជូនលោកស្ដាប់នូវសេចក្ដីដកស្រង់ចេញពីសៀវភៅមួយ ណាយ៉ាន់ ចាន់ដា គឺឯកសារ E3/2376, អង់គ្លេស 00192440, បារាំង 00237111, ខ្មែរ <00191 597>។ គាត់បានសរសេរអំពីហេតុការណ៍ដែលបានកើតឡើងដើមខែកញ្ញា ខ្ញុំមិនប្រាកដថា លោកនៅតំបន់នោះដែរឬទេ ប៉ុន្តែខ្ញុំនឹងអានជូនលោកស្ដាប់៖ “នៅដើមខែកញ្ញា វៀតណាមបានធ្វើការវាយប្រហារ

ដោយ ដឹកនាំដោយរថក្រោះចូលមកក្នុងប្រទេសកម្ពុជា គោលដៅរបស់គេនោះ គឺចង់ទាក់ទងលោក ហេង សំរិន ហើយនិងអ្នកគាំទ្ររបស់ពួកគាត់ដែលលាក់ខ្លួននៅក្នុងព្រៃ ដើម្បីយកពួកគេទៅប្រទេសវៀតណាម។ ដោយលោក ហេង សំរិន និង លោក ជា ស៊ីម ហើយនិង<អ្នករស់រានមានជីវិតពីរបប>ខ្មែរក្រហមផ្សេងទៀតក៏បានទៅដល់ប្រទេសវៀតណាមនោះ <អនាគតរដ្ឋាភិបាលកម្ពុជាលម្អៀងទៅវៀត-ណាមត្រូវបានបង្កើតឡើង>។" បញ្ចប់សេចក្ដីដកស្រង់។ តើខ្លឹមសារនេះធ្វើឲ្យលោកនឹកឃើញទេ ដែលថាកងកម្លាំងវៀតណាមព្យាយាមទាក់ទងកម្លាំងលោក ហេង សំរិន ដែលលាក់ខ្លួននៅក្នុងព្រៃ ហើយនាំពួកគេត្រឡប់ទៅវៀតណាម? ពួកគាត់ត្រឡប់ទៅវៀតណាមនោះ?

**ឆ៖** ខ្ញុំសូមជម្រាបថា ខ្ញុំភ្លេចអស់បាន ហើយក៏មិនយល់បញ្ហានេះដែរបាទ។

[១៥:៣៦:២៨]

**ស៖** មិនបញ្ហាទេ ខ្ញុំបន្តទៅប្រធានបទមួយផ្សេងទៀត លោកសាក្សី។ តើលោកបានដឹងឬទេក្នុងនៅឆ្នាំ១៩៧៨ ហើយក៏ខ្ញុំនឹងសួរថា តើលោកដឹង ឃើញថា មានការកសាងទីវាលយន្តហោះមួយនៅខេត្តកំពង់ឆ្នាំងដែរឬទេ?

**ឆ៖** ខ្ញុំដឹង គ្រាន់តែដឹង តែអត់ដែលបានទៅទេ គ្រាន់តែឮការណែនាំថា មានការកសាងទីលានយន្តហោះនៅកំពង់ឆ្នាំងនេះបាទ។

**ស៖** តើលោកដឹងឬទេ ថាតើអ្នកណាដែលធ្វើការងារជាពលកម្មនៅទីនោះ? តើកងកម្លាំងណាខ្លះចូលរួមក្នុងការកសាងទីលានយន្តហោះនៅកំពង់ឆ្នាំងហ្នឹង?

**ឆ៖** ចំណុចនេះខ្ញុំអត់បានដឹងទេបាទ។ អត់បានដឹង អត់បានយល់ ថាគេប្រមូលកម្លាំងមកធ្វើទីលានយន្តហោះនេះ យកកម្លាំងពីណានោះ គឺអត់បានដឹងបាទ។

**ស៖** ខ្ញុំយោងទៅអ្វីដែលលោក ឈួក រីន។ ឈួក រីន បានប្រាប់ទៅអ្នកអង្កេត គឺអង់គ្លេស <00766453> ខ្មែរ 00194468, បារាំង 00268885។ ក្នុងឯកសារ E3/361 គឺថា "<សំណួរ៖ តើលោកបានធ្វើ>អ្វីទៅ<លើ>កម្មាភិបាលបូព៌ា? <ចម្លើយ៖>ថ្នាក់មជ្ឈិមបានបញ្ជូនខ្ញុំ <និងអ្នកផ្សេងទៀត>ទៅភូមិភាគ<បូព៌ា ដើម្បីចាប់ខ្លួនកម្មាភិបាលទាំងអស់នៅក្នុងកងពលតូចទាំង៩> ហើយ<> បញ្ជូនពួកគេទៅកសាងព្រលានយន្តហោះ<> ហើយមេបញ្ជាការត្រូវបញ្ជូនមកភ្នំពេញ ហើយកងទ័ព <ថ្នាក់ក្រោម>ទាំងអស់ត្រូវបញ្ជូនទៅ<ធ្វើ>ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង។" តើ<នេះជាអ្វីដែល> លោក<បានឮ>ថា <កម្មាភិបាល ឬក៏យុទ្ធជនមកពីកងទ័ព>នៅភូមិភាគបូព៌ាត្រូវបានបញ្ជូនមកធ្វើ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ព្រលានយន្តហោះកំពង់ឆ្នាំង<ក្នុងទ្រង់ទ្រាយធំដែរទេ>?

[១៥:៣៩:១៨]

**ឆ៖** ខ្ញុំសូមជម្រាបថា ខ្ញុំអត់បានដឹងទេបាទ កិច្ចការងារផ្ទៃក្នុងហ្នឹង គឺថាមិនដឹង មិនស៊ីជម្រៅ។

**ស៖** មិនបញ្ហាទេ ហើយមានសំណួរមួយទៀត លោកសាក្សី បន្តពីសំណួរដែលសហព្រះរាជអាជ្ញាបានសួរថ្ងៃនេះ នៅពេលដែលគាត់យោងទៅរករបាយការណ៍វៀតណាមនិយាយអំពីការអះអាង ឬក៏ការចោទប្រកាន់ថា កងទ័ពកម្ពុជាប្រជាធិបតេយ្យវាយប្រហារទៅខាងវៀតណាមនៅថ្ងៃទី៣០ មេសា ឆ្នាំ១៩៧៧។ អ៊ីចឹងគឺថាថ្ងៃទី៣០ មេសា នេះគឺជាៗថ្ងៃជោគជ័យរបស់<កុម្មុយនីស្តវៀតណាម> គឺដូចគ្នានឹងថ្ងៃ១៧ មេសា <សម្រាប់បក្សកុម្មុយនីស្ត>កម្ពុជាអ៊ីចឹងដែរ។ គឺគេរំដោះប្រទេសវៀតណាមបាននៅថ្ងៃ៣០ មេសា រីឯកម្ពុជាប្រជាធិបតេយ្យ ១៧ មេសា។ ថាតើ<លោកបានដឹងអំពី>កង<ប្រដាប់អាវុធ>កម្ពុជាប្រជាធិបតេយ្យធ្វើការវាយប្រហារនៅចំថ្ងៃទី៣០ មេសា ១៩៧៧ គឺ២ឆ្នាំ បន្ទាប់ពីគេរំដោះបានទីក្រុងសៃហ្គនហ្នឹងដែរឬទេ?

**ឆ៖** ចំណុចនេះ ដូចខ្ញុំបានជម្រាបពីព្រឹកមិញហើយថា ការប្រយុទ្ធគ្នាឆ្នាំ៧៧ រវាងកម្ពុជានិងវៀតណាមនេះ គឺមានលក្ខណៈរប៉ះរបោះរហូត។ បន្តិចកន្លែងនេះ បន្តិចកន្លែងនោះ ហើយទាក់ទងនឹងបញ្ហាដីធ្លី ទាក់ទងបញ្ហានេសាទអីប៉ុណ្ណឹងទេ ឯលក្ខណៈវ៉ៃទ្រង់ទ្រាយធំថ្ងៃ៣០អីនេះ គឺថាវៀតណាមវ៉ៃចូលមកមែន ប៉ុន្តែខាងកម្ពុជាគ្រាន់តែកម្រិតទប់ទេ ទប់វៀតណាមបន្តិចៗទេ។ ហ្នឹងសូមជម្រាបជាក់ស្ដែងគឺអ៊ីចឹង។ មិនមានលក្ខណៈទ្រង់ទ្រាយធំដូចកាសែតនិយាយថា ចាប់វ៉ៃស្អី។ ៧៧នេះ គឺមានលក្ខណៈតូច តូចៗណាស់ ប្រយុទ្ធមិនមានលក្ខណៈធំទេ។

[១៥:៤១:៤៧]

**ស៖** ខ្ញុំយល់ ប៉ុន្តែសំណួរជាក់លាក់របស់ខ្ញុំហ្នឹង គឺសួរអំពីការវាយប្រហារទ្រង់ទ្រាយធំ ដែលថានាំឲ្យមានស្លាប់របួសច្រើន ជាពិសេសគឺក្នុងដែនដីវៀតណាមនៅថ្ងៃ៣០ មេសា <៧៧>។ តើព័ត៌មានហ្នឹង ធ្វើឲ្យលោកនឹកឃើញដែរឬទេ អំពីការវាយលុករបស់កម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី៣០ មេសា ដែលជាថ្ងៃបុណ្យជោគជ័យរបស់វៀតណាមនោះ?

**ឆ៖** ខ្ញុំសូមជម្រាបថា ព័ត៌មាននេះពិត ឬមិនពិត ខ្ញុំមិនយល់ទេ ប៉ុន្តែវៀតណាមបានសរសេរអ៊ីចឹងហើយ ប៉ុន្តែការប្រយុទ្ធជាក់ស្ដែង មិនមានលក្ខណៈធំអ៊ីចឹងទេ ហើយមិនមានអីចូលទៅដីវៀត-ណាមអីច្រើនជ្រៅអីទេ ពីព្រោះ ៧៧ នេះ គឺខ្ញុំនៅហ្នឹងទេ។ ខ្ញុំចាំៗខេត្តចូវដុកហ្នឹង ទល់មុខខេត្តចូវដុក

ហ្នឹង។ ដូច្នេះគ្មានថាវ៉ៃចូលជ្រៅប៉ុណ្ណេះៗ អីអត់មានទេបាទ គ្រាន់តែកម្រិតទៅមកៗនឹងព្រំដែនហ្នឹង។

**ស៖** តើលោកអាចនិយាយជាទូទៅបានដែរឬទេ អំពីគោលនយោបាយរបស់កងទ័ពបដិវត្តន៍កម្ពុជាចំពោះប្រទេសវៀតណាម? តើអ្វីដែលមេបញ្ជាការ ដូច សុន សេន ឬក៏ តាម៉ុក បានប្រាប់ទៅមេបញ្ជាការក្រោមឱវាទរបស់ពួកគាត់ ថាតើត្រូវធ្វើដូចម្ដេចចំពោះការឈ្លានពានរបស់ខ្មាំងវៀតណាមមកដល់ដែនដីកម្ពុជាប្រជាធិបតេយ្យ? តើលោកដឹងអំពីមាគ៌ានយោបាយត្រង់ចំណុចនេះដែរឬទេ?

[១៥:៤៤:០៣]

**ឆ៖** ចំណុចនេះ ខ្ញុំសូមបញ្ជាក់ផងដែរថា ការណែនាំរបស់ខាងលើពន្យល់ដល់កងទ័ពជាទូទៅបានន័យថាប្រទេសកម្ពុជាជាប្រទេសមួយតូច កងទ័ពតិច ប្រជាជនក៏តិច ឯវៀតណាមប្រទេសធំ កងទ័ពច្រើន អាវុធយុទ្ធភណ្ឌអីក៏ច្រើន ហើយកម្ពុជាយើងក៏ទើបតែរំដោះ អ៊ីចឹងយើងមានលទ្ធភាពអីទៅទប់ទល់ជាមួយវៀតណាមបាន អត់ទេ គឺថ្នាក់លើមានការណែនាំអ៊ីចឹង។ ណែនាំជាបន្តបន្ទាប់ ជាគោលនយោបាយហ្នឹង។ អាហ្នឹងសូមជម្រាបអ៊ីចឹង មិនមែនអត់មានការណែនាំទេ គឺណែនាំអ៊ីចឹង ថាយើងតូចយើងតិច យើងមិនអាចទៅទ្របានទេ ហើយទើបចេញពីសង្គ្រាម។ ចំណុចនេះ គឺមានការណែនាំ មានការអប់រំក្នុងកងទ័ព។

**ស៖** តើលោកនៅចាំឬទេ ថាតើ សុន សេន, តាម៉ុក បានប្រាប់មេបញ្ជាការរបស់ពួកគាត់ដូចម្ដេច? ថាតើអ្វីជាការណែនាំរបស់គាត់ ជាពាក្យសម្ដី? តើលោកចាំពាក្យសម្ដីដែលគាត់បានប្រើនោះគាត់ប្រើពាក្យអ្វីខ្លះ?

**ឆ៖** ខ្ញុំបានបញ្ជាក់អម្បាញ់មិញហើយថា ជំនាន់ហ្នឹងគឺខ្ញុំអត់ដែលបានជួប សុន សេន ទេបាទអត់ទេ បានជួបតែ តាម៉ុក ទេ។ អ៊ីចឹង តាម៉ុក គាត់ណែនាំថាកងទ័ពយើងតិច ប្រជាជនយើងតិច អាវុធយុទ្ធភណ្ឌយើងតិចនេះ វៀតណាមគេច្រើន អ៊ីចឹងយើងមានអីអត់ធ្លុត់ ហើយខំប្រាស្រ័យទាក់ទងៗ។ មុខសញ្ញាមួយៗខំប្រាស្រ័យទាក់ទងដើម្បីសម្រួលសភាពការណ៍។ ការណែនាំរបស់គាត់គឺអ៊ីចឹង ហើយកងពលក៏ណែនាំអ៊ីចឹងដែរ ហើយអនុវត្តជាក់ស្ដែងគឺខំអត់ធ្មត់ណាស់ បាទអត់ធ្មត់ណាស់។

[១៥:៤៦:២២]

**ស៖** ខ្ញុំនឹងអានជូនលោកស្ដាប់នូវសម្ដីរបស់មេបញ្ជាការអតីតភូមិភាគ<បស្ចិម>ដែលប្រាប់ទៅអ្នកស៊ើបអង្កេត គាត់បានដកស្រង់គឺពាក្យស្ទើរតែគ្រប់ម៉ាត់របស់ តាម៉ុក។ ខ្ញុំអានឱ្យលោកស្ដាប់។ លោកប្រធាន គឺសក្ខីកម្មរបស់ មាស វឿន គឺ E3/8752 គឺ ERN <អង់គ្លេស> 00849511,

<បារាំង> 01309292 ដល់ 93 ហើយជាភាសាខ្មែរ <00733339> ហើយគាត់និយាយ -- មាស វឿន គាត់និយាយថា សូមដកស្រង់ "នៅព្រំដែនគាត់បានណែនាំអំពីខ្ទាំងនៅខាងក្រៅ គាត់និយាយថា សូមដកស្រង់៖ "យើងត្រូវតែការពារទឹកដីរបស់យើង ហើយយើងត្រូវតែមានការអត់ធ្មត់ មិនត្រូវវាយប្រហារត្រឡប់ទៅវិញទេ។ បើគេបាញ់ប្រហារមកយើង យើងគ្រាន់តែការពារ យើងមិនបាញ់តបទៅវិញទេ នៅស្ងប់ស្ងៀម បើគេបាញ់មួយគ្រាប់ពីរគ្រាប់យើងបាញ់ទៅវិញ នោះមានន័យថាយើងបង្កើតបញ្ហាធំហើយ។" បញ្ចប់សេចក្តីដកស្រង់។ តើលោកនៅចាំដែរឬទេ ថាតើ តាម៉ុក និយាយពាក្យសម្តីបែបនេះទេ នៅពេលដែលលោកបានវត្តមាននៅក្នុងការប្រជុំជាមួយគាត់កាលនោះ?

**ឆ៖** ខ្ញុំបានជម្រាបអម្បាញ់មិញហើយ ថា តាម៉ុក ណែនាំឱ្យអត់ធ្មត់ ពីព្រោះប្រទេសយើងតូចតិចអីហ្នឹងបាទ។ អ៊ីចឹងវាស្រដៀងហ្នឹងការណែនាំទៅលោក វឿន អំមិញដែរបាទ ស្រដៀងៗគ្នាទេបាទ។

[១៥:៤៨:៣៧]

**ស៖** សូមអរគុណ។ ដើម្បីឱ្យប្រាកដថា កុំបីឱ្យមានការយល់ច្រឡំខ្ញុំអានជូនលោកស្តាប់នូវៗមេបញ្ជាការយោធាជាន់ខ្ពស់ម្នាក់បាននិយាយនៅក្នុងឆ្នាំ១៩៧៦ គាត់ -- លោកនិយាយថាលោកមិនដែលបានជួប សុន សេន ទេ ប៉ុន្តែខ្ញុំនឹងអានជូនលោកស្តាប់នូវអំពីពាក្យដែល សុន សេន គាត់និយាយប្រាប់ទៅកងពល៩២០ <នៅក្នុងអំឡុងពេលកិច្ចប្រជុំពេញអង្គមួយ> គឺE3/799 គឺERN <អង់គ្លេស> 00184781, 00323916 បារាំង, ខ្មែរ 00083160, សុន សេន បានណែនាំទៅកងពល៩២០ <នៅថ្ងៃទី៧ ខែកញ្ញា> ៧៦ នោះថា "ចំពោះវៀតណាមយើងប្រកាន់ជំហរដូចខាងក្រោមនេះ៖ ១) យើងមិនត្រូវធ្វើជាអ្នកបង្កបញ្ហានោះទេ។ ២) យើងត្រូវតែការពារទឹកដីរបស់យើងឱ្យបានជាដាច់ខាត គឺ ដាច់ខាតមិនឱ្យអ្នកណាយកទឹកដីបាន ឬបំពានបាន។ ៣) បើវៀតណាមឈ្លានពាន យើងនឹងសូមឱ្យគេចាកចេញទៅវិញ បើគេមិនចាកចេញទើបយើងវាយប្រហារ។ គោលជំហររបស់យើងគឺវាយទាំងនយោបាយ វាយទាំងយោធាផងដែរ។" ចប់សេចក្តីដកស្រង់។ ពាក្យទាំងអស់នេះគឺចេញពី សុន សេន ទៅកាន់កងពល ១។ តើពាក្យទាំងអស់នេះ វាឆ្លុះបញ្ចាំងពីគោលនយោបាយរបស់<កងទ័ពបដិវត្តន៍>កម្ពុជា<>ចំពោះប្រទេសវៀតណាមដែរឬទេ?

**ឆ៖** ចំពោះពាក្យពេចន៍នេះគឺ ជាគោលនយោបាយរបស់កម្ពុជានាសម័យនោះហើយបាទ។

[១៥:៥១:០៥]

**ស៖** ខ្ញុំបានយោងពាក្យសម្តីរបស់ តាម៉ុក និង សុន សេន។ <ហើយ>មេបញ្ជាការផ្ទាល់របស់

លោកឈ្មោះ រ៉េន។ តើ រ៉េន នៅពេលដែលគាត់និយាយទៅកាន់កងពលតូច ឬក៏<កងពល>ធំថា តើគាត់និយាយពីខ្លឹមសារដែលមានអត្ថន័យដូចសម្ដីរបស់ តាម៉ុក ឬក៏របស់ សុន សេន ដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា ឈ្មោះ រ៉េន នេះគាត់នយោបាយនេះគាត់និយាយជារួមៗទេ។ ខ្ញុំចង់និយាយថា បើខាងលើណែនាំមកមួយរយ គាត់មកនិយាយតែដប់អីទេ បាទ រួមៗពីរបីម៉ាត់អ៊ីចឹង ហើយគាត់ចូលជ្រៅតែខាងយោធាតែម្ដង ចូលជ្រៅតែខាងយោធាទេ។ ការគ្រប់គ្រងកម្លាំង ការរៀបចំកម្លាំងអីហ្នឹងគាត់ចូលជ្រៅហើយ យុទ្ធវិធី ឯនយោបាយគាត់និយាយគ្រាន់តែរួមៗខាងលើណែនាំមកអ៊ីចេះពីរបីម៉ាត់ៗទេ ហ្នឹងតាមទម្លាប់ដែលខ្ញុំធ្លាប់រស់នៅ ហើយធ្លាប់ប្រជុំគឺនិយាយខ្លីៗអ៊ីចឹងបាទ។

**ស៖** ខ្ញុំយល់ ប៉ុន្តែតើគាត់អនុវត្តនូវការបញ្ជាពី សុន សេន ពីតាម៉ុក ទៅអ្នកក្រោមបង្គាប់របស់គាត់ដែរទេ គឺនិយាយថា "កុំវាយប្រហារ កុំបង្កជម្លោះ ហើយត្រូវរក្សាភាពស្ងប់ស្ងាត់ ជាដើម" តើក្នុងន័យនេះដែរឬដូចម្ដេច?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថាគាត់និយាយក្នុងន័យហ្នឹង ប៉ុន្តែគាត់មិនបានលម្អិតអីវែងឆ្ងាយទេ ដូចខ្ញុំជម្រាបអ៊ីចឹងថា គាត់និយាយនយោបាយហ្នឹង គាត់និយាយតែបីបួនម៉ាត់ៗឈប់ហើយ ថាយើងកុំបង្ករឿង កុំទៅវ៉ៃគេ ហើយការពារទឹកដី គេមកយើងហាមគេមិនស្ដាប់ យើងវ៉ៃតែប៉ុណ្ណឹងបាទ អត់និយាយច្រើនទេ។

[១៥:៥៣:២៩]

**ស៖** សូមអរគុណដែលលោកបានបំភ្លឺលោកសាក្សី។ ចំណុចមួយចុងក្រោយទាក់ទងទៅនឹងប្រធានបទនេះ គឺថាអ្វីដែលយើងបានពិភាក្សានៅពេលនេះ គឺខ្សែសង្វាក់បញ្ជានៃកងយោធា សុន សេន តាម៉ុក នៅខាងលើ គឺចេញបញ្ជាទៅមេបញ្ជាការនានានៅថ្នាក់ក្រោម ហើយបន្ទាប់មកៗដល់រូបលោកកាលនោះ។ តាមពិតគឺ មិនមានៗគេហៅថា <តែ>យោធានោះទេនៅសម័យនោះ គឺថាគេមាន<តាំងពីកម្មាភិបាល ជនស៊ីវិល និង>កម្មាភិបាលក្មេងៗផងដែរ។ តើលោកដឹងដែរឬទេ ទស្សនាវដ្ដីមួយ គេហៅថា "ទង់បដិវត្ត" ឬក៏ "យុវជនបដិវត្ត"?

**ឆ៖** ខ្ញុំសូមជម្រាបថាសម័យនោះគេហៅថា "ទង់បក្ស"។ អ្នកដែលកសាងខ្លួនបានល្អ ធ្វើបានល្អ អ្នកនោះឯងទទួលទង់បក្ស។ នៅតាមមូលដ្ឋានក៏អ៊ីចឹងដែរ ភូមិណា ឃុំណាធ្វើបានល្អមិនប៉ះពាល់ប្រជាជន អ្នកនោះទទួលបានទង់បក្ស។

[១៥:៥៥:១១]

01377069



**ស៖** ខ្ញុំអានជូនលោកស្តាប់សេចក្តីដកស្រង់ចេញពីទស្សនាវដ្តីយុវជន-យុវនារីបដិវត្ត នៅ<ខែសីហា> ឆ្នាំ១៩៧៥ គឺ E3/749, អង់គ្លេស 00532686, ខ្មែរ 00399114, បារាំង 00593942។ នេះគឺទស្សនាវដ្តីយុវជន-យុវនារីបដិវត្តណែនាំកម្មាភិបាលក្មេងៗនៅខែសីហា ឆ្នាំ១៩៧៥៖ "នៅតាមបណ្តោយព្រំដែន ជាដាច់ខាតយើងត្រូវតែប្រុងប្រយ័ត្ន មិនត្រូវធ្វើអ្វីដែលនាំឲ្យមានបញ្ហាទេ ជាពិសេសជាមួយប្រជាជនប្រទេសជិតខាង ហើយក៏ជាចាំបាច់ត្រូវការពារទប់ទល់ ហើយមិនអនុញ្ញាតឲ្យពួកគេបំពារបំពានលើទឹកដីឬប្រជាជនយើងឡើយ។" ចប់សេចក្តីដកស្រង់។ លោកសាក្សីរូបលោកផ្ទាល់ជា<កម្មាភិបាលម្នាក់>របស់បក្សកុម្មុយនីស្តកម្ពុជា តើខ្លឹមសារនេះ ជាខ្លឹមសារដែលគេណែនាំដល់កម្មាភិបាល ជនស៊ីវិល <រួមទាំង>យុវជនយុវនារី <ចេញមកពី>បក្សកុម្មុយនីស្តកម្ពុជានោះ?

**ឆ៖** ខ្ញុំសូមជម្រាបថា ខ្លឹមសារនេះខ្ញុំក៏បានទទួលដែរបាទ ទទួល ហើយប្រឹងប្រែងអនុវត្ត។ ហើយខ្ញុំនិយាយជាក់ស្តែង រហូតដល់ខ្លួនខ្ញុំផ្ទាល់ក៏ទទួលទង់នេះដែរ ទទួលទង់បដិវត្តតែម្តង។ ដោយសារអនុវត្តល្អ ខាងថ្នាក់លើ គឺឲ្យទង់។

**ស៖** សូមអរគុណដែលលោកបំភ្លឺ។ សំណួរ ខ្ញុំសួរ<ថា តើនេះជា>ការណែនាំដល់កម្មាភិបាលក្មេងៗរបស់បក្សកុម្មុយនីស្តកម្ពុជានោះ គឺមិនឲ្យបង្កបញ្ហាជាមួយប្រជាជនប្រទេសជិតខាង ដូចជា វៀតណាម ប្រទេសថៃជាដើម។ តើនេះជាការណែនាំរបស់បក្សកុម្មុយនីស្តកម្ពុជាទៅដល់កម្មាភិបាលស៊ីវិលរបស់ខ្លួនផងដែរឬទេ?

[១៥:៥៧:៤៤]

**ឆ៖** ពិតជាមានការណែនាំ។ ចំណុចនេះ ខ្ញុំគាំទ្រ ព្រោះមានការណែនាំជាទូទៅអ៊ីចឹងតែម្តង។

**ស៖** សំណួរចុងក្រោយមុននឹងសម្រាកថ្ងៃនេះ លោកប្រធាន បន្តពីសំណួររបស់សហព្រះរាជអាជ្ញាពីដើម<ថ្ងៃ>នេះ។ សហព្រះរាជអាជ្ញាបានអានជូនលោកស្តាប់នូវសេចក្តីដកស្រង់ចេញពីការផ្សាយរបស់វៀតណាម វិទ្យុវៀតណាម និយាយសំខាន់ទៅ គឺថាវៀតណាមបានចោទប្រកាន់កម្ពុជាប្រជាធិបតេយ្យថាឈ្លានពាន ហើយក៏គេចោទប្រកាន់កងកម្លាំងបដិវត្តកម្ពុជាថា ចូលវាយឈ្លានពានដោយខុសច្បាប់ ឬក៏ឈ្លានពានព្រំដែន។ តើលោកអាចមានមតិអ្វីជាប្រតិកម្មទៅនឹងការផ្សាយរបស់វៀតណាមបែបនេះ?

**ឆ៖** ចំណុចនេះខ្ញុំសូមបញ្ជាក់ផងដែរថា ជាធម្មតាទេ ការផ្សាយ ពីព្រោះភាគីដែលទំនាស់គ្នា ហើយអត់ដែលផ្សាយថាល្អទេបាទ។ អ៊ីចឹងកម្ពុជាប្រជាធិបតេយ្យផ្សាយថាវៀតណាមឈ្លានពាន ឯវៀត

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ណាមផ្សាយថាកម្ពុជាប្រជាធិបតេយ្យឈ្លានពាន។ អ៊ីចឹង ហៅថាទៅ ទៅមកៗអ៊ីចឹងបាទ។ ប៉ុន្តែការពិតកម្ពុជាជាប្រទេសមួយតូចទេ។ បាទ អាហ្នឹងសូមជម្រាបអង្គជំនុំជម្រះអ៊ីចឹង គឺថាមិនមានលទ្ធភាពអីទៅឈ្លានពានវៀតណាមទេ បាទ មិនមានទេ។ អាហ្នឹងគ្រាន់សូមជម្រាបអ៊ីចឹងទេ។ ជាទស្សនៈខ្ញុំរួមតាំងពីមុនមកក៏អ៊ីចឹងដែរ គ្មានលទ្ធភាពអីទៅវ៉ៃវៀតណាម គ្មានអីទេ ទោះបីអ្នកណាណែនាំខ្ញុំយ៉ាងម៉េចក៏ដោយពីព្រោះខ្ញុំយោធា ខ្ញុំស្គាល់កម្លាំងណាស់ ខ្ញុំស្គាល់អាវុធណាស់បាទ។ អ៊ីចឹងការផ្សព្វផ្សាយនេះ គឺគ្រាន់តែទៅ ហើយនិងមក ដូចខ្ញុំថាអ៊ីចឹង គឺថាវៀតណាមនិយាយថា កម្ពុជាប្រជាធិបតេយ្យឈ្លានពាន ឯកម្ពុជាប្រជាធិបតេយ្យនិយាយថាវៀតណាមឈ្លានពាន។ អ៊ីចឹងសូមឲ្យពិភពលោកទាំងមូលត្រួតពិនិត្យមើលទៅបាទ អ្នកណាឈ្លានពានអ្នកណា ហើយអ្នកណាបាត់ដី ហ្នឹងគ្រាន់តែពិនិត្យបញ្ហាប៉ុណ្ណឹងទេបាទ។

[១៦:០០:១៦]

**ស៖** លោកបានឈរជើងនៅទីនោះនៅពេលនោះ ហើយលោកក៏ជា<ទាហាន>មួយ<រូប>ដែរ<នៅពេលនោះ។ តើ>លោក<យល់ស្របជាមួយ>ខ្ញុំ<ទេថា ការចោទប្រកាន់>របស់វៀតណាមថា<កម្ពុជាប្រជាធិបតេយ្យ>ឈ្លានពានគេនោះ <គឺ>ជាការផ្សាយមិនមានមូលហេតុ ហើយជាការផ្សាយក្លែងក្លាយ<>?

**ឆ៖** ចំណុចនេះខ្ញុំអត់ហ៊ានថាទេបាទ ថាការផ្សាយនេះក្លែងក្លាយ ឬក៏ថាមិនមានមូលហេតុអី ខ្ញុំអត់ហ៊ានថាទេបាទ ពីព្រោះទស្សនៈនិងគោលនយោបាយវាខុសគ្នា បើខ្ញុំថាទៅ ថាវាមិន ខ្ញុំមិនហ៊ានថាបាទ ថាត្រឹមត្រូវក៏មិនហ៊ានថា មិនត្រឹមត្រូវក៏មិនហ៊ានថាដែរបាទ គ្រាន់ថា ភាគីមួយៗគឺផ្សាយអ៊ីចឹងដូចគ្នា ឈ្លានពានដូចគ្នា។ ខាងកម្ពុជាប្រជាធិបតេយ្យ វិទ្យុស្រែកឡើងថា វៀតណាមឈ្លានពាន ដល់វៀត-ណាមស្រែកមកវិញថាកម្ពុជាប្រជាធិបតេយ្យឈ្លានពាន។ ហ្នឹងគ្រាន់ថា ដាក់បញ្ហាហ្នឹងឲ្យអង្គជំនុំជម្រះពិនិត្យពិចារណាចុះបាទ។

[១៦:០១:២៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ អរគុណលោកសាក្សី។ សវនាការនៅថ្ងៃ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី១ ខែវិច្ឆិកា ឆ្នាំ២០១៦ ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះអង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី អៀង ផាន បញ្ចប់ ហើយនិងផ្តើមស្តាប់សាក្ខីកម្ម

សាក្សីដែលមានរហស្សនាម 2-TCW-1065 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោក អៀង ផាន សវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីនៅថ្ងៃនេះមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលទំនងតែមួយព្រឹកទេ ឬក៏មិនដល់មួយព្រឹកផង។

ហើយអរគុណលោក ម៉ម រិទ្ធា មេធាវីប្រឹក្សាសាក្សី។ សវនាការស្តាប់សក្ខីកម្មលោក អៀង ផាន នៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកមកបន្តផ្តល់ប្រឹក្សាសាក្សីរូបនេះនៅថ្ងៃស្អែកទៀត។

ហើយបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោកសាក្សីវិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅ និងឲ្យអញ្ជើញគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកទៀត។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និង លោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែក ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៣ នាទី)*